សូមប្រសិទ្ធពរមហាប្រសើរជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ប្រធានគណបក្សប្រជាជនកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
ក្នុងឱ្យកាសដ៏មហានក្តីត្តិយសក្សត្រនៃទិវាគម្រប់ជន្មាយុ ៦៥ ឈានចូល ៦៦ វស្សារបស់សម្តេច

*យើងខ្ញុំសូមលំអោនកាយគោរពដោយក្តីដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចតេជោ** អគ្គមគ្គទ្ទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជា ដែលបានលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាញាណ ក្នុងការដឹកនាំមាតុភូមិកម្ពុជា សម្រេចបានជោគជ័យ ដ៏ធំធេងជាប្រវត្តិសាស្ត្រជូនជាតិ និងប្រជាជន តាំងពីដំណាក់កាលសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ រហូតមកដល់ដំណាក់កាលសន្តិភាព បង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍នាបច្ចុប្បន្ននេះ ។*

*សូមឧទ្ទិសបួងសួងគុណបុណ្យព្រះរតនត្រ័យ ទេវតាឆ្នាំថ្មី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ព្រមទាំងតេជៈបារមីនៃវិញ្ញាណក្ខន្ធរបស់បុព្វវីរបុរសខ្មែរគ្រប់ៗជំនាន់ សូមជួយប្រោះព្រំ គាំពារ ថែរក្សា **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រាបុត្រី បានប្រកបនូវសុខភាពល្អបរិបូរ កាយពលមាំមួន បញ្ញាញាណភ្លឺថ្លា ដើម្បីបន្តដឹកនាំប្រទេសកម្ពុជាសម្រេចបានជោគជ័យធំៗថ្មីៗទៀត ។*

គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត

ទស្សនាវដ្ដីប្រជាជន

សួស្តីឆ្នាំថ្មី

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ
ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០

សូមប្រសិទ្ធពរ បវរសួស្តី សិរីមង្គល មហាប្រសើរ ថ្វាយ និងជូនសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តមលោកឧកញ៉ា លោក-ជំទាវ លោក លោកស្រី មន្ត្រី-រាជការ កងយោធពលខេមរ-ភូមិន្ទ កងនគរបាលជាតិ ជន រួមជាតិនៅគ្រប់ទិសទី ព្រម ទាំងអង្គទូត និង អង្គការអន្តរ-ជាតិនានា ដែលកំពុងបំពេញ បេសកកម្មនៅព្រះរាជាណា-ចក្រ កម្ពុជា សូមបានប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបី ឃ្លៀងឃ្លាត ឡើយ ។

គោរពជូនពរ

ទស្សនាវដ្ដីប្រជាជន

វិចារណកថា EDITORIAL

ភាពសុខដុមរមនា និងការអភិវឌ្ឍគឺជាផ្លែផ្កាដ៏ត្រចះត្រចង់នៃសន្តិភាព

Harmony and Development – Precious Fruits of Peace

នៅលើពិភពលោកយើងនេះ ស្ទើរគ្រប់ប្រជាជាតិទាំងអស់សុទ្ធតែធ្លាប់បានឆ្លងកាត់នូវជម្លោះផ្ទៃក្នុង ការបែកបាក់ សង្គ្រាមអ៊ុំរ៉ែ ការហែកហួរ និងភាពវិនាសហិនហោច ។ ប្រជាជាតិខ្លះត្រូវបាត់ឈ្មោះ រលត់រលាយទឹកដីពីពិភពលោក ប្រជាជាតិខ្លះក្រោយពីធ្លាក់ក្នុងកលិយុគ ក៏បានងើបមុខឡើងវិញ ហើយឈរយ៉ាងត្រដែតប្រកបដោយមោទនភាព ។

*ចំពោះប្រជាជាតិខ្មែរយើងវិញ ក្រោយពីបានឆ្លងកាត់សម័យអង្គរដ៏រុងរឿងក៏បានធ្លាក់ចុះដុនដាបតាំងពីសតវត្សទី ១៨ មកអាស្រ័យដោយសារតែការបាត់បង់ឯកភាពជាតិ ដោយសារសង្គ្រាមផ្ទៃក្នុង និងជម្លោះមនោគមន៍វិជ្ជាពីខាងក្រៅ ។ បើពិនិត្យនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាជាង ៤ ទសវត្សមកនេះ ផ្តើមពីរដ្ឋប្រហារថ្ងៃ ១៨ មីនា ឆ្នាំ ១៩៧០ ដែលដឹកនាំដោយលោក លន់ នល់ ទម្លាក់សម្តេច **ព្រះនរោត្តម សីហនុ** ដោយមានការគាំទ្រពីសហរដ្ឋអាមេរិក បាននាំប្រទេសកម្ពុជាទាំងមូលឲ្យធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាមយ៉ាងសន្ធោរសន្ធៅបំផុត ។ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩ កម្ពុជាបានបន្តធ្លាក់ក្នុងរបបប្រល័យពូជសាសន៍ បង្ករដោយពួកក្បត់ប៉ុលពត ដែលបានសម្លាប់អាយុជីវិតប្រជាជនអស់ជាង ៣ លាននាក់ និងបំផ្លាញរចនាសម្ព័ន្ធសង្គមជាតិឲ្យរលាយខ្ទេចខ្ទីដល់ឫសគល់ ។ ឆ្លងកាត់សង្គ្រាម ៥ ឆ្នាំ ១ ខែ និងរបបប្រល័យពូជសាសន៍ ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ ប្រជាជនកម្ពុជាយើងបានទទួលរងមហាវិនាសកម្មសោកនាដកម្ម ការនិរាសព្រាត់ប្រាស និងភាពភ័យរន្ធត់ដែលពុំអាចនឹងពណ៌នាបានឡើយពីការសម្លាប់រង្គាលដោយគ្រាប់បែករាប់លានតោន ដោយព្រនង់ ឬស្សី និងត្បូងចប ព្រមទាំងទារុណកម្មដ៏យង់ឃ្នងបំផុតច្រើនរាប់មិនអស់ ដែលបានរុញច្រានឲ្យប្រជាជាតិយើងឈានដល់មាត់រណ្ដៅនៃការរលាយសូន្យ ។ ទឹកដីកម្ពុជាបានប្រែក្លាយទៅជាឋាននរក ប្រជាជនកម្ពុជាបានក្លាយទៅជាទាសករដូចក្នុងយុគសម័យបុព្វកាល ។*

*មហាជ័យជម្នះជាប្រវត្តិសាស្ត្រនៅថ្ងៃ ៧ ខែមករា ឆ្នាំ ១៩៧៩ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានសង្គ្រោះប្រទេសជាតិឲ្យរួចផុតពីរបបប្រល័យពូជសាសន៍បានទាន់ពេលវេលា ។ ប្រជាជនកម្ពុជាបានរស់ឡើងវិញ ហើយខិតខំពួតដៃគ្នាស្តារ និងកសាងប្រទេសជាថ្មីពីចាត់ដៃទទេ ក្នុងស្ថានភាពមានសន្តិភាពផង និងនៅមានសង្គ្រាមផង ។ គណបក្សប្រជាជនកម្ពុជាដែលបានយល់ច្បាស់ពីបំណងប្រាថ្នាដ៏ពិសិដ្ឋបំផុតរបស់ប្រជាជន គឺចង់បានសុខសន្តិភាព និងការរួបរួមជាតិ បានពុះពារជំរុញការអនុវត្តមាគ៌ាមហាសាមគ្គីជាតិ ដើម្បីប្រមែប្រមូលខ្មែរពីគ្រប់និន្នាការនយោបាយ រួបរួមគ្នាបង្កើតសន្តិភាពឡើងវិញលើមាតុភូមិដ៏អភ័ព្វនេះ ។ ថ្ងៃទី ២ ធ្នូ ឆ្នាំ ១៩៨៧ វេទិកាចរចា **សីហនុ-ហ៊ុនសែន** បានចាប់ផ្តើមសំដៅរកដំណោះស្រាយនយោបាយរវាងបណ្តាភាគីខ្មែរបដិបក្ស រហូតសម្រេចបានកិច្ចព្រមព្រៀងក្រុងប៉ារីសនាខែតុលា ឆ្នាំ ១៩៩១ និងឈានទៅដល់ការបោះឆ្នោតជាសកលនៅឆ្នាំ ១៩៩៣ បង្កើតបានរដ្ឋាភិបាលចម្រុះមួយ ។ ប៉ុន្តែដំណោះស្រាយក្រុងប៉ារីសនេះមិនទាន់បាននាំមកនូវសុខសន្តិភាពពេញលេញនៅឡើយទេ ។ រហូតមកដល់ចុងឆ្នាំ ១៩៩៨ តាមរយៈនយោបាយឈ្នះ-ឈ្នះ របស់សម្តេចតេជោ **ហ៊ុន សែន** ដែលបានធ្វើឲ្យរលំរលាយទាំងស្រុងនូវអង្គការចាត់តាំងខាង*

In this world, nearly every nation has passed through internal conflict, division, protracted war, and destruction. Some nations disappeared from this world, while some recovered proudly after falling into havocs. As for Cambodia, after going through the prosperous Angkor era, the country fell since the 14th century because we lost national unity, internal war as well as ideological conflict being brought to bear from outside.

Reviewing the Cambodian history in the past four decades, starting from the coup on 18 March 1970, led by Mr. Lon Nol to overthrow Samdech Preah Norodom Sihanouk, with support from the United States of America, the whole country plunged into a flaming war. Stared from 17 April 1975 through to 6 January 1979, Cambodia continued its fall into the regime of genocide created by the Pol Pot clique who killed over three million people and destroyed social and national infrastructure to their roots.

Having gone through war for five years and one month, and the regime of genocide for three years, eight months and twenty days, the people of Cambodia suffered great holocaust, tragedy, separation and fear beyond description from killings by millions tons of bombs, bamboo sticks, hoes and uncountable forms of torturing methods. They pushed our nation to the brink of an abyss of vanishing. The Cambodian land turned to be hell, in which many Cambodian people became slaves like in ancient time.

The great historic victory of 7 January 1979, under the leadership of the Cambodian People's Party and the National United Front for Salvation of Kampuchea, saved the country from the regime of genocide in a timely manner. The people of Cambodia survived and worked hand in hand to rebuild the country from scratch and at the time when the country was partly in peace and in war. The Cambodian People's Party, understanding clearly people's sacred wish to achieve peace and national reconciliation, strived to implement the path of national great solidarity aimed at mobilizing khmer from every political tendency to recreate peace on our pitiful motherland.

On 2 December 1987, the Sihanouk-Hun Sen. negotiation forum commenced looking for political settlement by Cambodian factions until we achieved Paris Peace Agreement in October 1991. However, the Paris settlement did not realize a full peace yet. It was until 1998, thanks to the win-win policy set out by Samdech Techo Hun Sen that neutralized the Khmer Rouge political and military organization, Cambodia achieved full national and territorial unity, which is unprecedented in its 500 years history.

Started from 1998 through to 2016, in this 17 years period, the people of Cambodia enjoyed sufficient opportune moment in national development and yielded rapid progress in every field, enjoying admiration from international community. As of present,our people have lived in harmony, in equal footing and rights with other nations in the world. Started from scratch and a state of heavily destruction, our people have united to rebuild the country to progress beyond imagination.

Realistically, in the past two decades, Cambodia has been one of the eight countries in the world that realized high economic growth in a rapid manner. Cambodia ranked first, in Asia Pacific region, for its improvement of social indicators. Cambodia is a country that realized its

នយោបាយ និងយោធារបស់ពួកឧទ្ទាមខ្មែរក្រហម ទើបប្រជាជាតិខ្មែរសម្រេចបានសន្តិភាពពេញលេញ ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុងដែលមិនធ្លាប់មានទាល់តែសោះក្នុងរយៈពេលប្រមាណ ៥០០ ឆ្នាំនៃប្រវត្តិសាស្ត្ររបស់ខ្លួន ។

ចាប់ពីចុងឆ្នាំ១៩៩៨មកដល់ឆ្នាំ ២០១៦ គឺមានរយៈពេល ១៧ ឆ្នាំហើយ ដែលប្រជាជនកម្ពុជាមានឱកាសគ្រប់គ្រាន់ក្នុងការអភិវឌ្ឍប្រទេសឲ្យមានការរីកចម្រើនដ៏ឆាប់រហ័សលើគ្រប់វិស័យ ហើយទទួលបានការស្ងើចសរសើរពីសហគមន៍អន្តរជាតិ ។ បច្ចុប្បន្នប្រជាជនយើងបានរស់នៅក្នុងភាពសុខដុមរមនា ដោយភាពស្មើមុខ ស្មើមាត់ ជាមួយបណ្ដាប្រជាជាតិទាំងអស់នៅលើពិភពលោក ។ ចាប់ពីបាតដៃទទេ និងក្នុងស្ថានភាពដែលប្រទេសវិនាសខ្ទេចខ្ទាំ ប្រជាជនយើងបានរួមសាមគ្គីគ្នាកសាងជាតិឡើងវិញឲ្យរីកចម្រើនលូតលាស់ហួសពីការស្មាន ។ ជាក់ស្ដែង ក្នុងអំឡុងពេល ២ ទសវត្សចុងក្រោយនេះ កម្ពុជាបានស្ថិតក្នុងចំណោមប្រទេសទាំង៨លើពិភពលោកដែលសម្រេចបាននូវកំណើនសេដ្ឋកិច្ចលឿនក្នុងអត្រាដ៏ខ្ពស់ ។ កម្ពុជាបានជាប់ចំណាត់ថ្នាក់លេខ ១ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់ការធ្វើឲ្យប្រសើរឡើងនូវសូចនាករសង្គម ហើយក៏ជាប្រទេសមួយដែលបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍ របស់អង្គការសហប្រជាជាតិលើវិស័យសំខាន់មួយចំនួនមុនកាលកំណត់ឆ្នាំ ២០១៥ ព្រមទាំងកំពុងស្ថិតក្នុងដំណើរចេញផុតពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយសង្ឃឹមថានឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ ។ សមិទ្ធផលដ៏មានតម្លៃទាំងអស់នេះ គឺជាផ្លែផ្កាដែលបានមកពីសន្តិភាព ។ មានតែអ្នកធ្លាប់ឆ្លងកាត់ភ្នក់ភ្លើងសង្គ្រាម និងការកាប់សម្លាប់ ផ្ដាច់ផ្ដិលអាយុជីវិត និងអ្នកយល់ដឹងត្រឹមត្រូវអំពីប្រវត្តិសាស្ត្រនោះទេ ទើបស្គាល់ច្បាស់ពីតម្លៃនៃសន្តិភាព ។ ចំពោះក្រុមប្រឆាំង និងមជ្ឈដ្ឋានអគតិនានា ដោយសារតែមហិច្ឆតាណ្ដោតអំណាច និងប្រយោជន៍ផ្ទាល់ខ្លួន ពួកគេមិនខ្លាចនឹងនាំយកភ្លើងសង្គ្រាមមកដុត បំផ្លាញមាតុភូមិកម្ពុជាឲ្យរលាយហិនហោចជាថ្មីម្ដងទៀតនោះឡើយ។ពួកគេញុះញង់ បំបែកបំបាក់ឯកភាពជាតិ បំផ្លាញទំនាក់ទំនងជិតស្និទ្ធរវាងរដ្ឋ និងប្រជាជន បណ្ដុះបណ្ដាលសតិអារម្មណ៍មិនគោរពច្បាប់ មិនគោរពស្ថាប័នរដ្ឋ មិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ដុតបញ្ជេះគំនិតជាតិនិយមជ្រុល និងធ្វើសកម្មភាពប្រឆាំងតាមបែបនិយមជ្រុល។ល។ ដែលទីបំផុត គ្មានអ្វីក្រៅតែពីនាំប្រទេសកម្ពុជាឲ្យវិលត្រឡប់ទៅរកអស្ថេរភាព ការបែកបាក់ និងសង្គ្រាមជាថ្មីទៀតនោះឡើយ ប្រសិនបើឧបាយកលរបស់ពួកគេបានសម្រេចនោះ ។

យើងគប្បីរំលឹកថា ការបង្កើតឲ្យមានសង្គ្រាម គឺអាចធ្វើបានតែក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ ដូចដែលពួកលន់នល់បានអនុវត្តកាលពីឆ្នាំ ១៩៧០ ក៏ប៉ុន្តែការខិតខំស្វែងរកមកវិញនូវសុខសន្តិភាព គឺត្រូវប្រើរយៈពេលយូរណាស់ គឺចាប់តាំងពីឆ្នាំ១៩៧៩ រហូតមកដល់ឆ្នាំ១៩៩៨ទើបបានសម្រេច ។ អាស្រ័យហេតុនេះយើងត្រូវតែថែរក្សា និងការពារជាដាច់ខាតនូវសុខសន្តិភាពដែលយើងទទួលបានមកវិញយ៉ាងលំបាកវេទនានេះ ទោះបីជាត្រូវបង់ដោយតម្លៃណាក្ដី ។ ដើម្បីការពារចីរភាពនៃសុខសន្តិភាព ខ្មែរទាំងអស់គ្នាមិនថាមាននិន្នាការនយោបាយណាឡើយ គប្បីរួបរួមសាមគ្គីគ្នា ក្រោមដំបូលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្ដូរផ្ដាច់ការពារវាល់សមិទ្ធផលនៃសង្គមជាតិ លើកកម្ពស់វប្ប្ធម៌សន្តិភាព និងអហិង្សា គោរពសិទ្ធិសេចក្ដីថ្លៃថ្នូររបស់មនុស្ស ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការអនុវត្តនីតិរដ្ឋ បន្ដជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនឲ្យបានប្រសើរឡើងឥតឈប់ឈរ ។

*គណបក្សប្រជាជនកម្ពុជា ដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខគឺជាកម្លាំងស្នូលដ៏រឹងមាំតែមួយគត់ក្នុងការថែរក្សាសន្តិភាព និងទប់ស្កាត់មិនឲ្យកម្លាំងអមិត្តណាអាចមកបង្កើតភ្លើងសង្គ្រាមជាថ្មីទៀតនៅលើទឹកដីកម្ពុជាបាន។ សម្ដេចតេជោ**ហ៊ុនសែន**បានរំឭកថាសោកនាដកម្មដ៏ធំធេងដែលប្រជាជនកម្ពុជាបានជួបប្រទះ នៅតែបន្ដជិតជាប់ក្នុងអារម្មណ៍ប្រជាជនមិនអាចរលប់បាត់ឡើយ ។ នេះគឺជាការចងចាំដែលមិនអាចបំភ្លេចបាន ហើយក៏ជាការដាស់តឿនក្រើនរំឭកដល់ប្រជាជនទូទៅ អ្នកនយោបាយ និងមជ្ឈដ្ឋានទាំងអស់ក្នុងសង្គម ជាពិសេសស្រទាប់យុវជនអំពីស្មារតីស្នេហាជាតិ បំពេញកាតព្វកិច្ចរួមក្នុងការការពារ និងពង្រឹងសន្តិភាពឲ្យបានគង់វង្សស្ថិតស្ថេរ ហើយប្ដេជ្ញារាំងស្ទាត់មិនឲ្យប្រវត្តិសាស្ត្រដ៏ឈឺចាប់អាចកើតមានជាថ្មីទៀត នៅលើមាតុភូមិយើងបានឡើយ ។*

ទស្សនាវដ្ដីប្រជាជន

UN millennium development goals in many sectors before 2015 and is in its departure from a low-income country to a lower middle-income country, and hope to become a country of middle-income status by the year 2030.These valuable achievements are the fruits of peace.

Only those who went through the flame of war and killings, had correct knowledge of history, would know clearly the value of peace. Those in the opposition and ill-willed circles, because of their ambition of power and personal interest, would not be afraid to bring in the flame of war to put the motherland in destruction again. They instigated, caused division of national unity, damaged close relation between state and people, educated people to abide by no law, to have no respect for state institutions, recognize no elections results, inflamed patriotic extremism, and conducted opposition action in an extremist manner, etc. In the end, all they did would only bring Cambodia to return to instability, division, and war once again, should they realized their tricks.

We should remind that to create war one would need a short time like what the Lon Nol group had done in 1970. However, to strive for peace would take a long time as in the past it had taken us from 1979 through to 1998 to achieve it. Therefore, we must resolutely maintain and defend peace, at whatever price it may take, that we have realized with hardships. To ensure sustainable peace, every Cambodian, no matter what tendency they may belong to, should unite and keep solidarity under the Constitution of the Kingdom of Cambodia, while determinedly protect social achievements, raise high culture of peace and non-violence, respect of human rights and dignity, strengthen democracy and rule of law, continue to strive socio-economic development. Steadfast improvement of people's living condition is also important.

The Cambodian People's Party, headed by Samdech Akka Moha Sena Padei Techo Hun Sen, is the only firm central force in keeping peace and preventing hostile forces from making fire of war again on the land of Cambodia. Samdech Techo Hun Sen reminded that the greatest tragedy that the Cambodian people encountered continues to live in their memories. It is a remembrance that is unforgettable and advisory to people as a whole, politicians, and social circles, especially youth strata, on patriotism and to fulfill common obligation in keeping and strengthening lasting peace. They should be determined to prevent the bitter history from recurring on the Cambodian motherland./.

THE PRACHEACHUN MAGAZINE

សម្តេចចក្រី ហេង សំរិន ក្នុងដំណើរទស្សនកិច្ចជាមិត្តភាព នៅប្រទេសអូស្ត្រាលី

*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជួបសំណេះសំណាលជាមួយនិស្សិតខ្មែរដែលកំពុងសិក្សានៅប្រទេសអូស្ត្រាលី*

*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះ-រាជាណាចក្រកម្ពុជា អញ្ជើញទស្សនាសារមន្ទីរជាតិរបស់ប្រទេសអូស្ត្រាលី NGA (National Gallery of Australia) ។ សារមន្ទីរជាតិអូស្ត្រាលីនេះ(NGA)ក៏មានកិច្ចសហប្រតិបត្តិការជាមួយសារមន្ទីរជាតិកម្ពុជាតាំងពីឆ្នាំ ១៩៩០*

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០១៦ បានបញ្ចប់ដំណើរទស្សនកិច្ចជាផ្លូវការ និងជាមិត្ត-ភាពរយៈពេល ៤ ថ្ងៃ នៅប្រទេសអូស្ត្រាលី ប្រកបដោយជោគជ័យ ហើយបានធ្វើមាតុភូមិនិវត្តន៍មកដល់មាតុប្រទេសវិញដោយសុវត្ថិភាព ។

ឯកឧត្តម **ញ៉ែម ថ្ងាវ** សមាជិករដ្ឋសភា និងជាតំណាងរាស្ត្រ មណ្ឌលកំពង់ធំ ដែលអមដំណើរក្នុងគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជាទៅទស្សនកិច្ចនៅប្រទេសអូស្ត្រាលី ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៦ នោះ បានមានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មាន នៅព្រលានយន្តហោះអន្តរ-ជាតិភ្នំពេញ ក្រោយពីវិលត្រឡប់មកពីប្រទេសអូស្ត្រាលីវិញថា ដំណើរទស្សនកិច្ចនេះក្នុងគោលបំណងពង្រឹងទំនាក់-ទំនង រវាងសភាជាតិនៃប្រទេសទាំងពីរ កម្ពុជា-អូស្ត្រាលី ។

ឯកឧត្តម **ញ៉ែម ថ្ងាវ** បានបញ្ជាក់ថា នេះជាដំណើរទស្សនកិច្ចលើកទី ១ ដែលប្រធានរដ្ឋសភាកម្ពុជាបានទទួលការអញ្ជើញពីសំណាក់ប្រធានរដ្ឋសភាអូស្ត្រាលី ។ ក្នុងដំណើរទស្សនកិច្ចនៅប្រទេសអូស្ត្រាលីនេះ សម្តេចពញាចក្រី **ហេង សំរិន** បានជួបសវនាការជាមួយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភាអូស្ត្រាលី ដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារនៅក្នុងព្រឹទ្ធសភា រដ្ឋសភានៃប្រទេសទាំងពីរផងដែរ ។

នៅក្នុងឱកាសនោះដែរ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ព្រមទាំងគណៈប្រតិភូអមដំណើរក៏បានចូលរួមតាមការអញ្ជើញរបស់ព្រឹទ្ធសភា រដ្ឋសភាអូស្ត្រាលី ដើម្បីជជែកវែកញែកពីរបៀបដេញដោល នៃដំណើរការអនុម័ត ច្បាប់នានារបស់សភាអូស្ត្រាលី និងបានអញ្ជើញទស្សនាពិព័ណ៌វិចិត្រសាលរបស់ប្រទេសអូស្ត្រាលី សម្រាប់ជាបទ-ពិសោធន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមក ។

កិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង លើកទី ១ និងវេទិកាប៊ីអាវ បានផ្ដល់សារប្រយោជន៍យ៉ាងសំខាន់ដល់កម្ពុជា



*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជួបជាមួយឯកឧត្ដម **លី ក៏ឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន*

ថ្នាក់ដឹកនាំនៅក្នុងកិច្ចប្រជុំកំពូល មេគង្គ-ឡានឆាង លើកទី ១ នៅសាធារណរដ្ឋប្រជាមានិតចិន

ចាប់ពីថ្ងៃទី២២-២៤ ខែមីនា សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋ-មន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង លើកទី ១ និងវេទិកាប៊ីអាវស្ដីពី "អនាគតអាស៊ី: សក្តានុពលថ្មីនិងចក្ខុវិស័យថ្មី" នៅសាធារណរដ្ឋប្រជាមានិតចិន ។

កិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង លើកទី ១ ក្រោមប្រធានបទ " ការចែករំលែកទន្លេ-ការចែករំលែកអនាគត" បានប្រារព្ធឡើងនៅព្រឹកថ្ងៃទី២៣មីនា នាមជ្ឈមណ្ឌលតាំងពិព័រណ៍អន្តរជាតិ Yalong Bay ក្នុង ទីក្រុង Sanya ខេត្ត Hainan សាធារណរដ្ឋប្រជាមានិតចិន ក្រោមវត្តមាននៃការអញ្ជើញជាអធិ-បតីដ៏ខ្ពង់ខ្ពស់ ឯកឧត្ដម **លី ក៏ឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន សម្ដេចអគ្គមហាសេនា បតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្ដមឧត្ដមសេនីយ៍ **ប្រាយុទ្ធ ចាន់អូតា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ ឯកឧត្ដម **ថុងស៊ីន ម៉ាម៉ាវង្ស** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឯកឧត្ដមអនុប្រធានាធិបតីនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ឯកឧត្ដមឧបនា-យករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសវៀតណាម ។

បណ្ដាមេដឹកនាំនៃប្រទេសមេគង្គទាំង ៥ រួមទាំងប្រទេសចិនបានធ្វើការពិនិត្យឡើងវិញលើវឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងដំណើរឆ្ពោះទៅរកការអភិវឌ្ឍនាពេលអនាគត។ កិច្ចប្រជុំបានផ្ដោតការយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងដោយផ្ដោតលើវិស័យជាអាទិភាព គន្លឹះចំនួន ៥ រួមមាន ៖ ការតភ្ជាប់សមត្ថភាពផលិតកម្ម កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងដែន ធនធានទឹក កសិកម្ម និងការកាត់បន្ថយភាពក្រីក្រ។ ពង្រឹងកិច្ចសហប្រតិបត្តិការប្រឆាំងនឹងការគំរាមកំហែងសន្តិសុខមិនប្រពៃណី រួមមានភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន គ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ ជំនួយមនុស្សធម៌ ការធានាសន្តិសុខស្បៀង ទឹក និងថាមពល ។ បង្កើតការតភ្ជាប់ទាំងផ្នែករឹង និងផ្នែកទន់ រវាងប្រទេសមេគង្គ-ឡានឆាង ។ ការធ្វើឲ្យប្រសើរឡើងទន្លេមេគង្គ និងទន្លេឡានឆាង បណ្ដាញផ្លូវគោក និងផ្លូវដែក និងជំរុញការអនុវត្តគម្រោងគន្លឹះ ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវហាយវ៉ៃ ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងផ្លូវអាកាស ក្នុងតំបន់មេគង្គ-ឡានឆាង ព្រមទាំងពន្លឿនការសាងសង់បណ្ដាញថាមពល ទូរគមនាគមន៍ និងអ៊ីនធើណែត។ ពង្រីកកិច្ច-សហប្រតិបត្តិការសមត្ថភាពផលិតកម្មក្នុងវិស័យនានា ដូចជា វិស្វកម្ម ផលិតកម្ម សំភារសំណង់ គាំទ្រឧស្សាហកម្មគ្រឿងចក្រ គ្រឿងបរិក្ខារ និងថាមពល។ ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកវិទ្យា និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ច នៅតាមព្រំដែនតំបន់ឧស្សាហកម្ម និងសួនបច្ចេក-វិទ្យាវិទ្យាសាស្ត្រ។ ពង្រឹងកិច្ចសហប្រតិបត្តិការរវាងវិស័យធនធានទឹកតាមរយៈការបង្កើតមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹក ឡានឆាង-មេគង្គ នៅក្នុងប្រទេសចិន។ ការអនុវត្តគំនិតផ្ដួចផ្ដើមកិច្ចសហប្រតិបត្តិការស្ដីពីការកាត់បន្ថយភាពក្រីក្រនៅអាស៊ីបូព៌ា និងការបង្កើតមូលដ្ឋានគ្រឹះគំរូនៃការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសមេគង្គ ។ ជាមួយគ្នានេះមេដឹក-នាំនៃប្រទេសមេគង្គ និងប្រទេសចិន បានលើកទឹកចិត្តដល់ការអភិវឌ្ឍប្រកបដោយចីរភាពនិងលើកស្ទួយការគាំពារបរិស្ថាននិងការគ្រប់គ្រងធន-ធានធម្មជាតិ ។ ជំរុញការចរចាភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ឲ្យសម្រេចបានក្នុងឆ្នាំ២០១៦ និងជំរុញសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការសម្របសម្រួលការវិនិយោគក្នុងតំបន់អាស៊ីបូព៌ា។ ពង្រឹងកិច្ចសហប្រតិ-បត្តិការវិស័យវប្ប៉ធម៌រវាងប្រទេសមេគង្គ-ឡានឆាង។ ពង្រីកកិច្ចសហប្រតិ-បត្តិការលើវិស័យសុខភាពសាធារណៈ ជាពិសេសការទប់ស្កាត់ និងការ-ពាររួមគ្នានូវជំងឺឆ្លង បច្ចេកវិទ្យា និងគ្រឿងបរិក្ខារ និងការបណ្ដុះបណ្ដាលមន្ត្រីជំនាញ ការពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ។ សម្ដេចតេជោ **ហ៊ុន សែន** បានថ្លែងថា កិច្ចប្រជុំកំពូលរបស់យើងនៅថ្ងៃនេះ បានឆ្លុះបញ្ចាំងអំពីដំណើរការវិវឌ្ឍន៍ជាវិជ្ជមានទាំងវិសាលភាព និងជម្រៅនៃកិច្ចសហប្រតិបត្តិការអនុតំបន់ រវាងប្រទេសទាំង ៦ និងការប្ដេជ្ញាចិត្តរួមគ្នាដ៏មោះមុតរបស់យើង លើដំណើរអភិវឌ្ឍន៍ឆ្ពោះទៅកវិបុលភាពរួមគ្នា ។ សម្ដេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍បញ្ជាក់ដែរថា កិច្ចប្រជុំកំពូលរបស់យើងនៅពេលនេះក៏ជាវេទិកាដ៏មានតម្លៃ និងសមស្របបំផុតសម្រាប់ការចូលរួមចំណែកកសាងមហាអនុតំបន់មួយរឹងមាំ តាមរយៈការជំរុញ ១.កិច្ចសហប្រតិបត្តិការនយោបាយ និងសន្តិសុខ ២.កំណើនសេដ្ឋ-

ថ្នាក់ដឹកនាំនៅក្នុងវេទិកាប៊ូអាវ នៅទីក្រុងប៊ូអាវ ខេត្តហៃណាន នៃសាធារណរដ្ឋប្រជាមានិតចិន

កិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព និង៣.ការផ្លាស់ប្ដូរសង្គម វប្ប‌ធ‌ម៌ និងទំនាក់ទំនងរវាងប្រជាជន និងប្រជាជនដែលនឹងបម្រើឲ្យផលប្រយោជន៍ របស់ប្រជាជនទាំងអស់ ក្នុងមហាអនុតំបន់មេគង្គ-ឡានឆាង ។ ជាមួយគ្នានេះ សម្ដេចសូមគាំទ្រចំពោះសេចក្ដីថ្លែងការណ៍ និងសេចក្ដីប្រកាសរួមទីក្រុងសានយ៉ា ដែលមានគោលដៅចំនួន ២៦ ចំណុចក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការនៃប្រទេសមេគង្គ-ឡានឆាង។ សម្ដេចតេជោនាយករដ្ឋ-មន្ត្រីបានគាំទ្រចំពោះការរៀបចំឲ្យមានកិច្ចប្រជុំកំពូលឡានឆាង-មេគង្គ ចំនួន ២ ឆ្នាំម្ដង ដែលក្នុងនោះកម្ពុជានិងធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង នៅឆ្នាំ ២០១៨ ខាងមុខ។ ការលើកឡើងរបស់សម្ដេចតេជោ នាយករដ្ឋមន្ត្រីត្រូវបានទទួលនូវការគាំទ្រពីប្រទេសមេគង្គទាំង ៦ ផងដែរ។

ថ្លែងទៅកាន់មេដឹកនាំនៃប្រទេសមេគង្គទាំង ៥ ក៏ដូចជាបណ្ដាញអ្នកសារព័ត៌មានអន្ដរជាតិនានា ឯកឧត្ដម **លី ក៏ឈាង** នាយករដ្ឋមន្ត្រីចិនមានប្រសាសន៍ថា ប្រទេសចិននិងប្រទេសមេគង្គទាំង ៥ មានលក្ខណៈស្និទ្ធ-ស្នាលគ្នាខ្លាំងណាស់ គឺប្រៀបបានអណ្ដាត និងធ្មេញ ដោយមិនអាចអត់នរណាមួយបាន ។ ពាក់ព័ន្ធនឹងការកសាងទន្លេឡានឆាង-មេគង្គ ឲ្យទៅជាសហគមន៍រួមគ្នាដើម្បីចែករំលែកបទពិសោធន៍ផង និងជំរុញកិច្ចសហប្រតិ-បត្តិការឈ្នះឈ្នះ និងជំរុញការតភ្ជាប់ក៏ចូជាសមាសភាពនៃការផលិត ឯក-ឧត្ដមនាយករដ្ឋមន្ត្រីចិន **លី ក៏ឈាង** មានប្រសាសន៍ថា យើងត្រូវតែមានការអនុវត្តជាក់ស្ដែងទៅលើគម្រោងនានាដែលយើងបានឯកភាពគ្នា ក្នុងនោះ ឯកឧត្ដមនាយករដ្ឋមន្ត្រីបានប្រកាសផ្ដល់ទឹកប្រាក់ចំនួន ១០ ពាន់លានយ័នសម្រាប់ប្រើប្រើប្រាស់ក្នុងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងថវិកាចំនួន១០ពាន់លានដុល្លាផ្សេងទៀតដែលក្នុងនោះទឹកប្រាក់ចំនួន ៥ ពាន់លានដុល្លារ សម្រាប់ការទិញទំនិញ និង ៥ ពាន់លានដុល្លារទៀត ជាមូលនិធិពិសេសសម្រាប់ប្រើប្រាស់ ក្នុងក្របខណ្ឌនៃបណ្ដាប្រទេសមេ-គង្គ ឡានឆាង។ ជាមួយគ្នានេះប្រទេសចិននឹងផ្ដល់ថវិកាចំនួន ២៥០លានដុល្លារសម្រាប់កិច្ចសហប្រតិបត្តិការប្រទេសត្បូង ត្បូង។ ប្រទេសចិនក៏បានប្រកាសពីការផ្ដល់អាហារូបករណ៍ដល់និស្សិតនៃប្រទេសមេគង្គទាំង ៥ ដែលមានចំនួនរហូតដល់ ១ ម៉ឺន ៨ ពាន់ អាហារូបករណ៍ និង ៥ ពាន់អា-ហារូបករណ៍ផ្សេងទៀត សម្រាប់ការបណ្ដុះបណ្ដាលធនធានមនុស្ស ។ នៅក្នុងសន្និសីទកាសែតរួមគ្នានោះ មេដឹកនាំនៃប្រទេសមេគង្គទាំង៦ បានឯក-ភាពគ្នាលើសេចក្ដីថ្លែងការណ៍រួមទីក្រុងសានយ៉ា ស្ដីពីកិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងសេចក្ដីប្រកាសរួម ស្ដីពីកិច្ចសហ-ប្រតិបត្តិការសមត្ថភាពផលិតនៅបណ្ដាប្រទេសមេគង្គ-ឡានឆាង។

នៅថ្ងៃទី ២៤ ខែមីនា វេទិកាប៊ូអាវបានប្រារព្ធឡើងនៅទីក្រុងប៊ូអាវ ខេត្ត ហៃណាន ក្រោមប្រធានបទ "អនាគត អាស៊ី : សក្តានុពលថ្មី និង ចក្ខុវិស័យ ថ្មី" ដែលមានប្រមុខដឹកនាំ និងតំណាងប្រទេសព្រមទាំងភ្ញៀវជាតិនិងអន្ដ-ជាតិជាង ២០០០ ដែលមកពី ៦០ ប្រទេស បានលើកទឹកចិត្ត គាំទ្រ និងជំរុញដល់ប្រទេសទាំងអស់ ផ្ដោតការយកចិត្តទុកដាក់លើកកម្ពស់ដល់ជីវ-ភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង ដែលក្នុងនោះគឺរួមមាន មុខរបរ និងការងារ ការសិក្សាអប់រំ ការថែទាំសុខភាពមនុស្សចាស់ជរា និងជម្រកស្នាក់នៅ ។ អង្គប្រជុំក៏មានការពិភាក្សាលើបញ្ហាម៉ាក្រូសេដ្ឋកិច្ច នយោបាយ សហគ្រិនភាព បច្ចេកវិទ្យាអ៊ីនធឺណិត សុខុមាលភាពសាធារ-ណៈ និងវប្ប‌ធ‌ម៌ជាដើម។ អង្គប្រជុំក៏បានគាំទ្រ និងជំរុញឲ្យប្រទេសក្នុងអា-ស៊ីជាមិត្តល្អជាមួយប្រទេសជិតខាងផងគ្នា ដោយមិនរើសអើង ឬប្រកាន់ទៅលើកម្រិតនៃការរីកចម្រើន ហើយរួមគ្នាថែរក្សាការពារសន្តិភាព ស្ថេ-រភាពក្នុងតំបន់ សហប្រតិបត្តិការជាមួយគ្នា ដើម្បីជំរុញការរីកចម្រើនដែលជាគន្លឹះដ៏សំខាន់នៃការរីកចម្រើនរបស់អាស៊ីទាំងមូល ដែលជាគន្លឹះនៃការលូតលាស់សេដ្ឋកិច្ចពិភពលោកផងដែរ ។ វេទិកាប៊ូអាវបានជួយជំរុញកម្ពុជាឆ្ពោះទៅរកការរីកចម្រើនព្រមគ្នា ជាមួយបណ្ដាប្រទេសអាស៊ាននានាដែលជាបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ ជាពិសេសយុវជនខ្មែរទូទាំងប្រទេស ។

ក្នុងឱកាសនៃការស្នាក់អាស្រ័យនៅប្រទេសចិននោះដែរ សម្ដេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឲ្យឯកឧត្ដម ArkadyDvorkovich ឧបនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសហព័ន្ធរុស្ស៊ី ចូលជួបសំដែងការគួរសម និងពិភាក្សាការ-ងារ ។ សម្ដេចតេជោ និងឯកឧត្ដម ArkadyDvorkovich បានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ អំពីការត្រៀមនូវដំណើរបំពេញទស្សនកិច្ចរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី ដែលនឹងអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋសហព័ន្ធរុស្ស៊ីក្នុងខែឧសភាខាងមុខ ។ សម្ដេចតេជោ **ហ៊ុន សែន** និងឯកឧត្ដមឧបនាយករដ្ឋមន្ត្រី ក៏បានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ទាក់ទងការដោះស្រាយបំណុលដ៏លែកមុពជាហានជំពាក់អតីតសហភាពសូវៀតកាលពីពេលកន្លងមក។ សម្ដេចតេជោ និងឯកឧត្ដមឧបនាយករដ្ឋមន្ត្រីរុស្ស៊ីបានសម្ដែងនូវការវាយតម្លៃខ្ពស់ ចំពោះក្រុមការងារនៃប្រទេសទាំងពីរដែលបានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ ពីការដោះស្រាយបំណុល ហើយដែលបានឈានឆ្ពោះទៅមុខមានលក្ខណៈអំណោយផលជាច្រើន ពោលគឺធ្វើយ៉ាងណាឲ្យបំណុលកម្ពុជាពីអតីត-កាលត្រូវបានដោះស្រាយក្នុងពេលឆាប់ៗខាងមុខ តាមរយៈការដោះស្រាយលើការវិនិយោគក្នុងប្រទេសកម្ពុជា ដែលជាដំណោះស្រាយមួយស្របតាមកិច្ចព្រៀមព្រៀងសន្តិភាពទីក្រុងប៉ារីស។ សម្ដេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍បញ្ជាក់ថា អ្វីដែលរូបសម្ដេច និងប្រជាជនកម្ពុជាចង់បាននោះគឺការខិតខំដោះស្រាយបំណុលទាំងអស់នោះឲ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន ។ ជាការឆ្លើយតប ឯកឧត្ដម ArkadyDvorkovich មាន

*សម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាថ្លែងសុន្ទរកថានៅក្នុងវេទិកាប៉ូអាវ*

ប្រសាសន៍ថាប្រទេសរុស្សីមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះដំណោះស្រាយបំណុលរបស់កម្ពុជា តាមរយៈការប្រែក្លាយបំណុលមកការវិនិ-យោគ ហើយដែលភាគីទាំងពីរត្រូវបន្តពិភាក្សាគ្នាជាលម្អិតទៅទៀត រួមទាំងបញ្ហាបច្ចេកទេសផងដែរ។ សម្តេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍លើកឡើងពីលទ្ធភាពនៃការដោះស្រាយបំណុល តាមរយៈការជួយទិញកសិផលរបស់កម្ពុជានាំចូលទៅកាន់ប្រទេសរុស្សី។ សម្តេចតេជោនាយក-រដ្ឋមន្ត្រីមានប្រសាសន៍ដែរថា ដោយសារតែកំណើននៃភ្ញៀវទេសចររុស្សីបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជាជាង១០ម៉ឺននាក់ ដែលភាគច្រើនពួកគេធ្វើដំណើរតាមប្រទេសជិតខាងនោះ កម្ពុជាស្នើដល់ភាគីរុស្សីបើកឲ្យមានការហោះហើរត្រង់ពីរុស្សីមកកាន់កម្ពុជា ដើម្បីជំរុញកំណើនទេសចរណ៍ និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ នៃប្រទេសទាំងពីរឲ្យកាន់តែមានសក្តានុពលខ្ពស់ថែមទៀត។ សម្តេចតេជោនាយករដ្ឋមន្ត្រី និងឯកឧត្តម ArkadyDvorkovich ក៏បានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ក្នុងការពង្រីកកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន និងរុស្សី ដែលសារតែបច្ចុប្បន្នរុស្សីគឺជាដៃគូចរចាររបស់អាស៊ាន សំដៅធ្វើយ៉ាងណាជំរុញឲ្យមានកិច្ចប្រជុំកំពូលអាស៊ានរុស្សីកើតឡើងក្នុងពេលអនាគត។ ជាមួយគ្នានេះសម្តេចតេជោ និងឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានធ្វើការពិភាក្សាពីបញ្ហាតំបន់ និងអន្តរជាតិ ដែលប្រទេសទាំងពីរកំពុងមានការយកចិត្តទុកដាក់ដូចគ្នា ។

សម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុនសែន**នាយករដ្ឋមន្ត្រីនៃព្រះរា-ជាណាចក្រកម្ពុជា ក៏បានអញ្ជើញចូលជួបពិភាក្សាទ្វេភាគី ជាមួយឯកឧត្តម **លី ក៏ឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិនផងដែរ ។ ឯកឧត្តមនាយករដ្ឋមន្ត្រីចិន បានសម្តែងការរីករាយខ្លាំងណាស់ដោយបានជួបសម្តេចតេជោនាយករដ្ឋមន្ត្រីជាថ្មីទៀត នៅកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង ហើយសង្ឃឹមថាឯកឧត្តមនឹងអញ្ជើញ មកចូលរួមកិច្ចប្រជុំកំពូលមេ-គង្គ-ឡានឆាង ក្នុងប្រទេសកម្ពុជានាឆ្នាំ ២០១៨ ខាងមុខ។ សម្តេចតេជោបានសម្តែងនូវការរីករាយចំពោះភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនៃប្រទេសទាំងពីរ កម្ពុជា ចិន ដែលបានចាប់ផ្តើមពីឆ្នាំ ២០១០ រហូតមកដល់បច្ចុប្បន្ន។ កម្ពុជាពិតជាបានទទួលនូវផលប្រយោជន៍យ៉ាងខ្លាំងពីការដាក់ចេញនូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនោះ ពិសេសការជួយផ្តល់ជំនួយរបស់ប្រទេសចិនដល់ប្រទេសកម្ពុជា ពិតជាបានរួមចំណែកដល់ការពង្រឹងនូវឯករាជ្យភាពរបស់កម្ពុជា ក្នុងការចូលរួមកសាងសេដ្ឋកិច្ច និងការជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ សម្តេចតេជោ **ហ៊ុន សែន** បានស្នើដល់សមភាគីចិនបន្តពិនិត្យលទ្ធភាព ក្នុងការបន្តជួយដល់ប្រទេសកម្ពុជាបន្ថែមទៀត សំដៅធ្វើយ៉ាងណាឲ្យទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរកើនដល់ ៥ពាន់លានដុល្លារនៅឆ្នាំ២០១៧។ ដើម្បីឲ្យមានការកើនឡើងនូវទំហំពាណិជ្ជកម្មរបស់ប្រទេសទាំងពីរ សម្តេចតេជោនាយករដ្ឋមន្ត្រីបានស្នើដល់ភាគីចិនបន្តនាំចូលបន្ថែមទៀតនូវកសិផល និងផលិតផលពីប្រទេសកម្ពុជា ពិសេសធ្វើយ៉ាងណាកុំឲ្យកំណត់កូតា និងពន្ធនាំចូលទៅកាន់ប្រទេសចិន និងជួយជំរុញអ្នកវិនិយោគចិនមកបណ្តាក់ទុនក្នុងប្រទេសកម្ពុជាឲ្យកាន់តែច្រើនឡើងថែមទៀត ពិសេសការវិនិយោគទៅលើការផលិតកសិផលកសិកម្មសម្រាប់នាំចេញទៅកាន់ប្រទេសចិន ឬទៅកាន់ប្រទេសទី ៣ បន្ថែមទៀត។ ក្នុងនោះសម្តេចតេជោក៏បានស្នើឲ្យមិត្តចិនជួយពិនិត្យ និងសម្រេចឲ្យបានឆាប់លើគម្រោងសាងសង់ពហុកីឡាដ្ឋានមរតកតេជោ គម្រោងសាងសង់មន្ទីរពេទ្យចំនួន ២ និងវិទ្យាស្ថានធនធានទឹកដែលមិត្តចិនបានសម្រេចរួចហើយ ។ ទន្ទឹមនឹងនេះ សម្តេចតេជោ **ហ៊ុន សែន** បានស្នើសុំឲ្យមិត្តចិនជួយក្នុងការសាងសង់ផ្លូវល្បឿនលឿន (Express Way) ពីភ្នំពេញទៅក្រុងព្រះសីហនុ និងព្រលានយន្តហោះថ្មីនៅខេត្តសៀមរាប ។ មិត្តចិនបានគាំទ្រដល់សំណើទាំងអស់ដែលបានលើកឡើងដោយសម្តេចតេជោ ហើយនឹងពិនិត្យលើឯកសារឲ្យបានរហ័សដើម្បីគម្រោងទាំងអស់នេះចាប់ដំណើរការសាងសង់ក្នុងពេលឆាប់ៗខាងមុខ។ ជាមួយគ្នានេះ សម្តេចតេជោបានស្នើដល់ភាគីចិនជួយជួសជុលប្រាសាទព្រះវិហារដ៏ចំណាស់របស់កម្ពុជា ។ ជាការឆ្លើយតបឯកឧត្តមនាយករដ្ឋ-មន្ត្រីចិន **លី ក៏ឈាង** មានប្រសាសន៍ថា ដោយសារតែជំនឿ និងកម្រិតនយោបាយនៃប្រទេសទាំងពីរកម្ពុជា ចិនកាន់តែមានសន្ទុះកើនឡើងខ្ពស់នោះ ចិននឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសកម្ពុជាឲ្យកាន់តែរឹងមាំទ្វេឡើងថែមទៀត ពិសេសក្នុងក្របខណ្ឌដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយដែលយើងបានរួមគ្នាបង្កើតឡើង។ ភាគី ចិននឹងបន្តជួយដល់គម្រោងនានាដែលភាគីកម្ពុជាបានស្នើឡើង ពិសេសទៅទៀតនោះ រដ្ឋាភិ-បាលចិន នឹងលើកទឹកចិត្តឲ្យក្រុមហ៊ុនចិនមកបណ្តាក់ទុនក្នុងប្រទេសកម្ពុជា តាមរយៈការស្នើឲ្យភាគីកម្ពុជាផ្តល់នូវកត្តាអំណោយផលដល់បណ្តាក្រុមហ៊ុនចិនដែល បាន និងកំពុងបណ្តាក់ទុកក្នុងប្រទេសកម្ពុជា ។ ពាក់ព័ន្ធទៅនឹងការជួសជុលប្រាសាទព្រះវិហារឡើងវិញ ឯកឧត្តមនាយក-រដ្ឋមន្ត្រីចិនបានសម្តែងនូវការរីករាយ ក្នុងការជួយដល់គម្រោងជួសជុលឡើងវិញប្រាសាទព្រះវិហារ ពោលគឺជួយទាំងបច្ចេកទេស និងជួយទាំងហិរញ្ញវត្ថុដល់គម្រោងទាំងមូលផងដែរ។ ក្នុងជំនួបពិភាក្សាគ្នានោះ ឯក-ឧត្តមនាយករដ្ឋមន្ត្រីចិនបានឆ្លើយតបតាមការអញ្ជើញរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា ដើម្បីអញ្ជើញមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងពេលវេលាដ៏សមស្របក្នុងឆ្នាំ២០១៦នេះ ព្រមទាំងបានអញ្ជើញសម្តេចតេជោនាយករដ្ឋមន្ត្រីទៅបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណ-រដ្ឋប្រជាមានិតចិនផងដែរ ។៖

សម្ដេចតេជោ : កម្ពុជាមានមហិច្ឆតាក្នុងការបញ្ជូនកម្លាំងទៅចូលរួមក្នុងបេសកកម្មរក្សាសន្ដិភាពកាន់តែច្រើន

❋ការកែសម្រួលសមាសភាពគណៈរដ្ឋមន្ដ្រី គឺដើម្បីប្រសិទ្ធភាពការងារ

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្ដិភាពរបស់ អ.ស.ប រយៈពេល ១០ ឆ្នាំ (២០០៦ -២០១៦) នៅវិមានសន្ដិភាព*

នៅក្នុងខែមីនាឆ្នាំ ២០១៦ កន្លងមកនេះ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**នាយករដ្ឋមន្ដ្រីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសំខាន់ៗមួយចំនួននៅក្នុងប្រទេស ។ សម្ដេចតេជោបានផ្ដល់អនុសាសន៍ជាច្រើនដែលបង្ហាញពីឆន្ទៈ និងទស្សនវិស័យរបស់រាជរដ្ឋាភិបាល ។

❋រសៀលថ្ងៃទី ១ ខែមីនា សម្ដេចតេជោនាយករដ្ឋមន្ដ្រីបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្ដិភាពរបស់ អ.ស.ប រយៈពេល ១០ ឆ្នាំ (២០០៦ -២០១៦) នៅវិមានសន្ដិភាព ។ នាឱកាសនោះ សម្ដេចតេជោបានបង្ហាញអំពីមហិច្ឆតាក្នុងការបញ្ជូនកងកម្លាំងរបស់កម្ពុជាកាន់តែច្រើនថែមទៀត ទៅចូលរួមក្នុងសកម្មភាពសន្ដិភាពក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ(អ.ស.ប)។

សម្ដេចតេជោមានប្រសាសន៍បញ្ជាក់ទៅកាន់លោកស្រី Claire Van Der Vaeren មន្ដ្រីសម្របសម្រួល អ.ស.ប ប្រចាំកម្ពុជាដែលជាតំណាងរបស់លោកអគ្គលេខាធិការ អ.ស.ប ចូលរួមក្នុងពិធីនេះថា "ខ្ញុំពិតជាមានមហិច្ឆតាធំណាស់។ អម្បាញ់មិញខ្ញុំបានប្រាប់ថាខ្ញុំមានផែនការពង្រីកការបញ្ជូនកម្លាំងទៅក្រៅប្រទេស ។ ឥឡូវកម្ពុជាកំពុងស្ថិតនៅក្នុងប្រទេសជាប្រព័ន្ធដែលរៀបកម្លាំងរហ័ស ។ យើងនឹងពិនិត្យបន្ដនៅក្នុងការចូលរួមចំណែកប្រតិបត្ដិការទៅក្នុងប្រទេសមួយចំនួនទៀត នៅពេលដែលមានសំណូមពរពីអ.ស.ប។ ខ្ញុំមានមហិច្ឆតាដើម្បីចូលរួមព្រោះមិត្ដភក្ដិបានជួយមកដល់យើងៗក៏ត្រូវជួយទៅដល់មិត្ដភក្ដិវិញដែរ ពិតមែនតែកម្ពុជាក្រទ្រព្យសម្បត្ដិ យើងក្រប្រាក់កាស ក៏ប៉ុន្ដែយើងខ្ញុំមិនក្រផ្លូវចិត្ដនោះទេ" ។

សម្ដេចតេជោបន្ដថា បន្ដិចម្ដងៗកម្ពុជាក៏បានត្រៀមខ្លួនបញ្ជូនជំនួយខ្លះទៅកាន់ប្រទេសអាហ្វ្រិក ដែលបានលើកសំណូមពរចំពោះសម្ដេចរួចមកហើយ ។ យើងកំពុងគិតគូរបញ្ហានេះដែលអាចធ្វើសកម្មភាពនៅពេលខាងមុខ ។ សម្ដេចបញ្ជាក់ថា"ប្រសិនបើកម្ពុជាជាប្រទេសអ្នកមានវិញនោះ កម្ពុជានឹងបញ្ជូនជំនួយទៅក្រៅប្រទេសឲ្យបានក្នុងរង្វង់ ៧% នៃផលិតផលសរុបរបស់ប្រទេស។ ក៏ប៉ុន្ដែកម្ពុជានៅជាប្រទេសក្រីក្រនៅឡើយ តែកម្ពុជាមានទឹកចិត្ដក្នុងការជួយដល់ប្រទេសជាមិត្ដកម្ពុជា នឹងបន្ដបញ្ជូនកងកម្លាំងទៅជួយប្រទេសជាមិត្ដបន្ដទៀត" ។

សម្ដេចតេជោបានរំលឹកថាកាលពី ១០ ឆ្នាំមុននេះ សម្ដេចបានជូនដំណើរដល់កងវរៈសេនាធំបោសសម្អាតមីនកម្ពុជាដែលត្រូវបំពេញបេសកកម្មនៅប្រទេសស៊ូដង់ក្រោមឆ័ត្ររបស់ អ.ស.ប ។ បេសកកម្មជាលើកដំបូងបង្អស់របស់កងទ័ពមួកខៀវកម្ពុជានាពេលនោះ បានបើកទំព័រប្រវត្ដិសាស្ដ្រនៃការរួមចំណែករបស់កម្ពុជា ក្នុងបេសកកម្មរក្សាសន្ដិភាពរបស់ អ.ស.ប ។ ការសម្រេចចាត់បញ្ជូនកងទ័ពបោសសំអាតមីនរបស់កម្ពុជានាពេលនោះ គឺជាការឆ្លើយតបទៅនឹងការអំពាវនាវរបស់ឯកឧត្ដមអគ្គលេខាធិការ អ.ស.ប ហើយត្រូវបានធ្វើឡើងក្នុងខណៈដែលកម្ពុជាខ្លួនឯងកំពុងប្រឈមនឹងបញ្ហាគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមដែលបង្ក ឲ្យប្រជាពលរដ្ឋស្លូតត្រង់របស់យើងស្លាប់ , របួស និងពិការប្រមាណ ៨០០ នាក់ក្នុងមួយឆ្នាំ ។ ។

សម្ដេចបានថា កម្ពុជាអាចបញ្ជូនកងទ័ពរបស់ខ្លួនទៅចូលរួមបេសកកម្ម អ.ស.ប នៅពេលនេះបាន ក៏ដោយសារស្ថានភាពប្រទេសមានសុខសន្ដិភាព,ស្ថិរភាពនយោបាយ,ឯកភាពជាតិ និងទឹកដីទាំងស្រុងដែលបានផ្ដើមចេញពីនយោបាយឈ្នះ-ឈ្នះ ដើម្បីបង្រួបបង្រួម ផ្សះផ្សាជាតិ និងការរួមរស់ជាមួយគ្នាដោយសេចក្ដីសុខសាន្ដ ។

❋ព្រឹកថ្ងៃទី ៥ ខែមីនា សម្ដេចតេជោនាយករដ្ឋមន្ដ្រីបានអញ្ជើញជាអធិបតីនៅក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការភូមិកុមារអេស អូ អេស នៅខេត្ដកំពត ដែលនៅទីនោះ សម្ដេចបានធ្វើការអំពាវនាវមួយឲ្យមានការគាំទ្រ និងប្រើប្រាស់ផលិតផលអំបិលក្នុងស្រុក ។

សម្ដេចតេជោមានប្រសាសន៍ថា ឥឡូវនេះអំបិលនៅសល់មិនដឹងថាត្រូវនាំចេញទៅណាទៀត ។ ដូចនេះ សូមអំពាវនាវចំពោះប្រជាពលរដ្ឋនៅទូទាំងប្រទេសសូមប្រើប្រាស់អំបិលក្នុងស្រុករបស់ខ្លួន ជាជាងប្រើប្រាស់អំបិលដែលនាំចូលពីបរទេស ។ អំបិលរបស់កម្ពុជាគឺជាអំបិលដែលធានាសុវត្ថិភាពខ្ពស់ ។ អំបិលកម្ពុជាមិនមែនជាអំបិលដែលជីកពីភ្នំមកទេ។ អំបិលដែលនាំចូលពីក្រៅប្រទេសមកជាអំបិលដែលគេជីកមកពីភ្នំ វាខុសពី

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នកាត់ខ្សែបូសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការភូមិកុមារអេស អូ អេស នៅខេត្តកំពត*

អំបិលដែលធ្វើពីទឹកសមុទ្រ ។ មួយទៀតអំបិលកម្ពុជាបានលាយនូវសារ-ធាតុអ៊ីយ៉ូដ ដែលជួយកុំឲ្យមានកុមារកម្ពុជាកុំឲ្យកើតជំងឺពកកទៀតផង ។

គួរបញ្ជាក់ថាតម្រូវការអំបិលក្នុងស្រុកមានប្រមាណ១០ម៉ឺនតោនក្នុងមួយឆ្នាំ ខណៈដែលមណ្ឌលផលិតអំបិលទាំង៧ក្នុងខេត្តកំពតនិងខេត្តកែបផលិតបានដល់ទៅជាង ២០ម៉ឺនតោនក្នុងមួយឆ្នាំ ។ បូកជាមួយអំបិលដែលសល់ពីឆ្នាំមុនផងនោះ បានធ្វើឲ្យអំបិលកម្ពុជានៅសល់ក្នុងឃ្លាំងជិត ៣០ ម៉ឺនតោន នាពេលបច្ចុប្បន្ន ។ ដូច្នេះ កម្ពុជានៅសល់បរិមាណអំបិលដ៏ច្រើនស្ដុកទុកនៅក្នុងឃ្លាំង ហើយដោយសារតែអំបិលកម្ពុជាមិនអាចនាំចេញទៅក្រៅប្រទេសបាន ។

❋ ព្រឹកថ្ងៃទី ៧ ខែមីនា សម្ដេចតេជោបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី ១០ ស្ដីពី "ជំរុញការ-ងារទៅមុខ : ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស និងក្នុងតំបន់ និងឡូជីស្ទីកសម្រាប់ការតភ្ជាប់កំណើន និងអភិវឌ្ឍន៍" នៅសណ្ឋាគារសូហ្ស៊ីតែលភ្នំពេញ ភូគីត្រា ។ សន្និសីទនេះរៀបចំដោយវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ។

សម្ដេចតេជោ បានមានប្រសាសន៍ថា "រហូតមកដល់បច្ចុប្បន្នកម្ពុជាសម្រេចបាននូវវឌ្ឍនភាពយ៉ាងធំធេង ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដោយសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងល្អប្រសើរជាប្រចាំ និងរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង ។ ក្នុងនោះផលទុនជាតិឬទំហំសេដ្ឋកិច្ចដែលវាស់ដោយផលិតផលក្នុងស្រុកសរុប (ផ.ស.ស) បានកើនឡើងពីប្រមាណ ២.៥០០ លានដុល្លារអាមេរិកនៅឆ្នាំ ១៩៩៣ ដល់ប្រមាណ ១៨.៤០០ លានដុល្លារនៅឆ្នាំ ២០១៥ ឬបានកើនឡើងប្រមាណជាង ៧ ដង " ។ សម្រាប់ចក្ខុវិស័យរបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ ២០១៦ កាលពីខែមីនាឆ្នាំ ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ដែលបានផ្ដោតលើការតម្រង់ទិសទីផ្សារ និងបរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម ។

❋ ព្រឹកថ្ងៃទី ៩ ខែមីនា សម្ដេចតេជោបានអញ្ជើញជាអធិបតីក្នុងពិធីចែកសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី ១ និងទី២. សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្ដមជំនាន់ទី ២០ និងសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសភាសាបារាំង ខ្មែរជំនាន់ទី១៧ចំនួន ១.២៥៦ នាក់ នៅវិទ្យាស្ថានជាតិអប់រំ ។ ក្នុងពិធីនេះសម្ដេចបានលើកឡើងអំពីការទប់ស្កាត់អំពើពុករលួយ តាមរយៈការបើកប្រាក់បៀវត្សរ៍នៅធនាគារ និងការដំឡើងប្រាក់ខែ ។

សម្ដេចតេជោមានប្រសាសន៍ថារាជរដ្ឋាភិបាលបានសម្រេចប្រើប្រាស់បច្ចេកវិទ្យាក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ករណីបើកប្រាក់ខែមន្ត្រីរាជការតាមធនាគារជាចំណាត់ការមួយលុបបំបាត់ "មន្ត្រីខ្មោចបើកប្រាក់ខែ " និងអំពើពុករលួយរបស់មន្ត្រីពន្ធដារ ។

សម្ដេចតេជោបន្ថែមថា គ្រាន់តែបានបើកប្រាក់ខែមុនដំណាច់ខែ គឺជារឿងល្អណាស់ទៅហើយដែលមុននោះវាលំបាកណាស់ ។ ឆ្នាំ ១៩៩៦, ១៩៩៨ រដ្ឋជំពាក់ប្រាក់ខែមន្ត្រីរាជការ ២ខែ ៣ខែ រហូតដល់មន្ត្រីរបស់យើងលើកឡើងថានៅកម្ពុជាមួយខែមាន ៦០ ថ្ងៃ គឺលំបាកខ្លាំងណាស់នៅពេលរដ្ឋាភិបាលគ្មានសាច់ប្រាក់ ប៉ុន្តែយើងបានកែទម្រង់ហើយឈានមកបើកបៀវត្សរ៍បានមុនដំណាច់ខែ ។ ការបើកបៀវត្សរ៍តាមធនាគារគ្រាន់តែធ្វើប៉ុណ្ណឹងកាត់បន្ថយបាននូវអំពើពុករលួយ ពាក់ព័ន្ធនឹងការបើកប្រាក់នេះ តាមរយៈកាត់កង និងមួយទៀតមន្ត្រីខ្មោច ។

សម្ដេចតេជោបន្ដថា ឥឡូវរាជរដ្ឋាភិបាលចូលទៅដល់ដែលគេហៅថាប្រើបច្ចេកវិទ្យាព័ត៌មានដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ឬអំពើមិនប្រក្រតី ។ ប្រើប្រាស់ប្រព័ន្ធធនាគារបង់ពន្ធក៏អញ្ចឹងដែរ ។ កុំឲ្យមន្ត្រីពន្ធជួបជាមួយអ្នកបង់ពន្ធក្រែងលោកាត់កងគ្នា បង់តាមធនាគារអញ្ចឹងអត់កាត់កងគ្នាបានទេ... ។ នេះគឺប្រើបច្ចេកវិទ្យាព័ត៌មានដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ និងភាពមិនប្រក្រតី ។

ទាក់ទងទៅនឹងបញ្ហាប្រាក់បៀវត្សរ៍គ្រូបង្រៀនសម្ដេចបញ្ជាក់ថាគោលដៅរបស់យើងឆ្នាំនេះ គឺសម្រេចឲ្យបានទាបបំផុតប្រាក់ខែសម្រាប់គ្រូមត្តេយ្ય និងគ្រូបឋមថ្មីថ្មោងត្រឹម ៨០ ម៉ឺនរៀល ប្រហាក់ប្រហែល ២០០ ដុល្លារអាមេរិក ។ ប៉ុន្តែគោលដៅឆ្នាំ ២០១៨ គឺត្រូវសម្រេចទាបបំផុតមួយលានរៀល ។

សម្ដេចតេជោអះអាងថាក្នុងរយៈពេល ២ ខែដើមឆ្នាំនេះរាជរដ្ឋាភិបាលបានធ្វើការសាកល្បងនៃចំណូល និងចំណាយរបស់រដ្ឋឃើញថា អាចស្ទុះរួច ហើយសម្ដេចក៏កំពុងឲ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងក្រសួងមុខងារសា-ធារណៈ ពិនិត្យមើលអំពីលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភសម្រាប់ប្រពន្ធ កូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ។ ចំណុចទាំងអស់នេះវាជាចង្កោមបញ្ហា មិនមែនជារឿងដាច់ដោយឡែកនោះទេ ។

❋ ព្រឹកថ្ងៃទី ១៤ ខែមីនា សម្ដេចតេជោ បានអញ្ជើញជាអធិបតីនៅក្នុងពិធីបើក "សន្និសីទជាតិស្ដីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា " ដែលបានប្រារព្ធនៅវិមានសន្តិភាពទីស្ដីការនាយករដ្ឋមន្ត្រី ។ ក្នុងពិធីនេះ សម្ដេចបានលើកឡើងនូវការកត់សម្គាល់មួយចំនួនទាក់ទងទៅនឹងការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។

សម្ដេចតេជោមានប្រសាសន៍ថាមានកត្តាសំខាន់ចំនួន ៤ ដែលជាកត្តាពន្លឿនកំណើនវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្នុងនោះមាន៖ ទី១.គោល-នយោបាយគាំពារ និងលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ។ ទី២.ក្របខ័ណ្ឌ

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ចែកសញ្ញាបត្ដ ដល់និស្សិតសាកលវិទ្យាល័យន័រតុន*

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អញ្ជើញជាអធិបតី ក្នុងពិធីប្រកាសដាក់ឲ្យអនុវត្ដដំណាក់កាលទី ៣ និងកិច្ចប្រជុំត្ដួតពិនិត្យ វាយតម្លៃវឌ្ឍនភាពប្រចាំឆ្នាំ ២០១៥ នៃកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

បទប្បញ្ញត្ដិ និងការត្ដួតពិនិត្យដោយប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ។ ទី៣.ភាពរស់រវើក និងការច្នៃប្រឌិតរបស់ប្រតិបត្ដិករមីក្រូហិរញ្ញ-វត្ថុ និងទី៤.តម្រូវការ និងការគាំទ្ររបស់អតិថិជនដោយយល់ឃើញពីសារ-សំខាន់នៃវិស័យមីក្រូហិរញ្ញវត្ថុក្នុងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ។

សម្ដេចនាយករដ្ឋមន្ដ្រីបានបញ្ជាក់ទៀតថា រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងបន្ដខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ ទន្ទឹមគ្នានឹងការជំរុញអភិវឌ្ឍន៍វិស័យធនាគារ និងហិរញ្ញវត្ថុនិយាយជារួម និងវិស័យមីក្រូហិរញ្ញវត្ថុនិយាយដោយឡែក ដើម្បីចូលរួមចំណែកជំរុញ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការដាក់ចេញនូវវិធានការគោលនយោ-បាយ និងការបង្កនូវបរិស្ថានអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសការបន្ដប្រកាន់ខ្ជាប់នូវគោលការណ៍ត្រឹះនៃសេដ្ឋកិច្ច ។

*ព្រឹកថ្ងៃទី ១៧ ខែមីនា សម្ដេចតេជោនាយករដ្ឋមន្ដ្រីបានអញ្ជើញជាអធិបតីក្នុងពិធីចែកសញ្ញាបត្ដដល់និស្សិតសាកលវិទ្យាល័យន័រតុន ដែលធ្វើឡើងនៅមជ្ឈមណ្ឌលសន្ដិសីទ និងពិព័រណ៍កោះពេជ្រ។ ក្នុងពិធីនេះ សម្ដេចបានលើកឡើងអំពីសំណើ កែសម្រួលសមាសភាពគណៈរដ្ឋមន្ដ្រី ដែលសម្ដេចបានស្នើទៅកាន់រដ្ឋសភាកាលពីថ្ងៃទី ១៦ ខែមីនាកន្លងទៅ ។

សម្ដេចតេជោបានមានប្រសាសន៍ថា ការកែសម្រួលគណៈរដ្ឋមន្ដ្រី ដែលនឹងធ្វើនៅថ្ងៃទី ៤ ខែមេសាខាងមុខនេះគឺដើម្បីប្រសិទ្ធភាពការងារ។ មិនមែនមានរដ្ឋមន្ដ្រីអាក្រក់ទាំងអស់ទេ ប៉ុន្ដែមានរដ្ឋមន្ដ្រីស្នក់ស្រពន់មួយ ចំនួនដែលត្រូវផ្លាស់ប្ដូរសម្រួល ដើម្បីឲ្យការងារប្រទេសជាតិកាន់តែមាន ប្រសិទ្ធភាពខ្ពស់ ។

សម្ដេចបញ្ជាក់ថា នេះជាការពង្រឹងនូវប្រសិទ្ធភាពការងារ។មិនមែនរដ្ឋ មន្ដ្រីទាំងនោះជាមនុស្សត្រូវកម្ចាត់ចោលទេ ។ សម្ដេចបានស្នើដល់រដ្ឋមន្ដ្រី ដែលបានដឹងខ្លួនថាទទួលការផ្លាស់ប្ដូរឲ្យបន្ដការងាររហូតដល់ពេលមាន ព្រះរាជក្រឹត្យពីព្រះមហាក្សត្រតែងតាំង ។

សម្ដេចតេជោបានបន្ថែមថាមានអភិបាលខេត្ដចំនួន ៤ ដែលត្រូវបញ្ចប់ ការងារមុនអាណត្ដិក្នុងនោះមានលោក **គោស៊ុំ សារ៉ឿត** អភិបាលខេត្ដ បន្ទាយមានជ័យ,លោក **អ៊ូ សំអ្នន** អភិបាលខេត្ដកំពង់ស្ពឺ,លោក **ខ្ចយ ឃុនហ៊ីរ**អភិបាលខេត្ដកំពតនិងលោក**ជ្ងៀងអ**ំអភិបាលខេត្ដស្វាយរៀង ដោយសារតែមន្ដ្រីទាំងនេះក៏ជិតដល់អាយុដែលត្រូវចូលនិវត្ដន៍ដែរ។ប៉ុន្ដែ មន្ដ្រីទាំងនេះក៏នឹងត្រូវបញ្ចូលមកក្នុងរាជរដ្ឋាភិបាល ។

*ព្រឹកថ្ងៃទី ២១ ខែមីនាសម្ដេចតេជោបានអញ្ជើញជាអធិបតីក្នុងពីធី ប្រកាសដាក់ឲ្យអនុវត្ដដំណាក់កាលទី ៣ និងកិច្ចប្រជុំត្ដួតពិនិត្យវាយតម្លៃ វឌ្ឍនភាពប្រចាំឆ្នាំ ២០១៥ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសា-ធារណៈ ។ ខណៈនោះសម្ដេចបានថ្លែងបញ្ជាក់ជាថ្មីម្ដងទៀតអំពីសារសំខាន់ និងការប្ដេជ្ញាចិត្ដរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់ ។

សម្ដេចតេជោបានមានប្រសាសន៍ថា សម្ដេចធ្លាប់បានរំលឹកជារឿយៗ ថា ទង្វើ និងសមិទ្ធផលរបស់យើងក្នុងរយៈកាលកន្លងទៅបានបង្ហាញយ៉ាង ច្បាស់ថា រាជរដ្ឋាភិបាលពិតជាមានឆន្ទៈយ៉ាងមោះមុតតតាវថយ, ប្រកប ដោយភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្ដការកែទម្រង់ លើគ្រប់វិស័យ និងកាន់តែស៊ីជម្រៅ ។ ការកែទម្រង់ កើតចេញមកពីការ យល់ឃើញដ៏ត្រឹមត្រូវរបស់យើងដោយខ្លួនឯង គឺមិនមែនជាការធ្វើតាម ការបង្គាប់បញ្ជារបស់អ្នកណានោះទេ ។ មានន័យថាយើងបានដាក់ចេញ និងជំរុញអនុវត្ដកិច្ចការកែទម្រង់ទាំងអស់របស់យើង ដោយឈរលើហេតុ-ផល និងវិចារណភាពច្បាស់លាស់ ព្រមទាំងប្រកបដោយភាពជាម្ចាស់ និងវីរភាព, ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ, ហើយធ្វើជាជំហានៗ និងជា ដំណាក់កាលៗ, ទៅតាមលទ្ធភាព និងសមត្ថភាពជាក់ស្ដែងរបស់យើង ។

សម្ដេចបានសង្កត់ធ្ងន់ថា ការកែទម្រង់គឺជាការងារស្លាប់រស់របស់ កម្ពុជា ។ យើងពិតជាគ្មានថ្ងៃស្ដុបស្ដល់នឹងកិច្ចការនេះទេ ។ ផ្ទុយទៅវិញ យើងនឹងបន្ដចាត់ទុកថា ការកែទម្រង់គឺជាការងារប្រចាំថ្ងៃរបស់យើងដែល យើងត្រូវបន្ដកែលម្អ,ពង្រឹង,ធ្វើឲ្យកាន់តែស៊ីជម្រៅ,បង្កើន និងពង្រីកសមត្ថ ភាព និងលទ្ធភាពរបស់យើងសំដៅប្រើប្រាស់ឲ្យបានកាន់តែប្រសើរបំផុត នូវសក្ដានុពល និងកាលានុវត្ដភាពទាំងឡាយដែលយើងមានក្នុងគោល ដៅតាមឲ្យទាន់សភាពការណ៍ និងដំណើរវិវត្ដន៍នៃសង្គម,សេដ្ឋកិច្ច,និង នយោបាយទាំងនៅក្នុងក្របខ័ណ្ឌប្រទេស, ក្របខ័ណ្ឌតំបន់ ក៏ដូចជាក្រប-ខ័ណ្ឌពិភពលោក ។

សម្ដេចក្រឡាហោម ស ខេង ៖ ការតែងតាំង និងប្រគល់ភារកិច្ចដឹកនាំជូនមន្ត្រីវ័យក្មេងដែលមានបទពិសោធន៍ ជាគោលការណ៍កែទម្រង់ថ្មី

*សម្ដេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្ដីទី អញ្ជើញជាអធិបតីក្នុងពិធីផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងអភិបាលខេត្តកំពត និងខេត្តកំពង់ស្ពឺ*



នៅព្រឹកថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០១៦ សម្ដេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្ដីទី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីក្នុងពិធីផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងអភិបាលខេត្តកំពតនៅសាលប្រជុំរបស់សាលាខេត្តកំពត។ រាជរដ្ឋាភិបាលបានតែងតាំងឯកឧត្ដម **ចាន់ ចេស្ដា** ជាអភិបាលខេត្តកំពតជំនួសឯកឧត្ដម **ខូយ ឃុនហ៊ីរ** ដែលត្រូវបានផ្ទេរភារកិច្ចទៅបម្រើការងារនៅទីស្ដីការគណៈរដ្ឋមន្ត្រី ។

សម្ដេចក្រឡាហោមបានមានប្រសាសន៍ថា ការផ្ទេរភារកិច្ច និងតែងតាំងថ្នាក់ដឹកនាំដើម្បីគ្រប់គ្រងរដ្ឋបាលជារឿងធម្មតា ទៅតាមពេលវេលាកំណត់។ នាដំណាក់កាលចុងក្រោយនេះការតែងតាំងនិងប្រគល់ភារកិច្ចដឹកនាំជូនមន្ត្រីវ័យក្មេង ដែលមានបទពិសោធន៍ជាគោលការណ៍កែទម្រង់ថ្មីដើម្បីប្រសិទ្ធភាព និងនិរន្តរភាពការងារ។ សម្ដេចក្រឡាហោមបានបន្ដថា ថ្នាក់ដឹកនាំកំពុងគិតគូផងដែរអំពីការត្រៀមបញ្ចូលអ្នកវ័យក្មេងពោរពេញដោយបទពិសោធន៍ការងារសម្រាប់ស្ថាប័នដទៃទៀត ។ វិធីនេះនឹងអនុវត្ត ដូចគ្នាសម្រាប់ការដាក់បញ្ចូលបេក្ខភាពដើម្បីឱ្យឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នាពេលខាងមុខ។ បញ្ហាសំខាន់គឺចម្រាញ់ជ្រើសរើសឱ្យអស់លទ្ធភាពចំពោះមន្ត្រីនៅនឹងកន្លែងនៅមូលដ្ឋានផ្ទាល់។ ប៉ុន្តែបើរកមិនបានហើយតម្រូវឱ្យមានជំនួយពីក្រៅនោះថ្នាក់ដឹកនាំនឹងគិតគូរតាមនោះ។

សម្ដេចក្រឡាហោមបានណែនាំអភិបាលខេត្តទើបទទួលតំណែងថ្មីឱ្យខិតខំថែរក្សាសមិទ្ធផល និងយកបទពិសោធន៍ល្អៗរបស់អភិបាលខេត្តចាស់ ដើម្បីអនុវត្តក្នុងការដឹកនាំបន្ត ពិសេសលើការងារផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការងារអត្តសញ្ញាណកម្ម និងត្រៀមរិះរកវិធីឆ្លើយតបទៅនឹងបញ្ហាបម្រែបម្រួលអាកាសធាតុដែលកំពុងចោទជាបញ្ហានេះ ។

គួរបញ្ជាក់ថា សម្ដេចក្រឡាហោម **ស ខេង** ក៏បានអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីផ្ទេរតំណែងអភិបាលខេត្តកំពង់ស្ពឺនៅល្ងាចថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០១៦ និងផ្ទេរតំណែងអភិបាលខេត្តស្វាយរៀងនៅថ្ងៃទី២៤ ខែមីនា ផងដែរ ។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាសាងសង់រោងចក្រផលិតស៊ីម៉ង់ត៍របស់ក្រុមហ៊ុន ជីប ម៉ុង អ៊ិនស៊ី ស៊ីមេន ខបភើរេសិន ស្ថិតនៅក្នុងភូមិព្រៃតាព្រិត ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិ-ធីបញ្ចុះបឋមសិលាសាងសង់រោងចក្រផលិតស៊ីម៉ង់ត៍របស់ក្រុមហ៊ុន ជីប ម៉ុង អ៊ិនស៊ី ស៊ីមេន ខបភើរេសិន ដែលស្ថិតនៅក្នុងភូមិព្រៃតាព្រិត ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត ។

*សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាសាងសង់រោងចក្រផលិតស៊ីម៉ង់ត៍របស់ក្រុមហ៊ុន ជីប ម៉ុង អ៊ិនស៊ី ស៊ីមេន ខបភើរេសិន ក្នុងស្រុកបន្ទាយមាស ខេត្តកំពត*

មានប្រសាសន៍ក្នុងឱកាសនោះ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានថ្លែងអបអរសាទរចំពោះក្រុមហ៊ុន ជីប ម៉ុង អ៊ិនស៊ី ស៊ីមេន ខបភើរេសិន ដែលបានចូលរួមវិនិយោគលើគម្រោងសាងសង់រោងចក្រស៊ីម៉ង់ត៍ដ៏ធំ និងទំនើបនៅកម្ពុជា ។ សម្តេចមានប្រសាសន៍បន្ថែមថា រោងចក្រផលិតស៊ីម៉ង់ត៍ដ៏ធំនេះ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ផ្តល់ឱកាសការងារ និងអត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសសម្រាប់បងប្អូនប្រជាពលរដ្ឋក្នុងខេត្តកំពតនេះតែម្តង ។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ក៏សូមអបអរសាទរ និងថ្លែងកោតសសើរចំពោះសមិទ្ធផលទាំងឡាយដែលខេត្តកំពតសម្រេចបាន នារយៈពេលកន្លងមក ដែលបានឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពល-រដ្ឋ ជាពិសេសគឺសក្តានុពលសេដ្ឋកិច្ច ដែលរួមមានកត្តាភូមិសាស្ត្រ និងអំណោយផលជាធនធានធម្មជាតិដ៏សម្បូណ៌បែបមាននៅក្នុងខេត្ត ដែលជាប្រភពទុនអាចទាក់ទាញការចាប់អារម្មណ៍ពីវិនិយោគិនជាតិ អន្តរជាតិ ឲ្យចូលមកដាក់ទុន វិនិយោគ រួមចំណែកយ៉ាងខ្លាំងក្លា និងជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់របស់ប្រទេសជាតិ ។

សម្តេចពិតជាមានមោទនភាពដែលបានមកកាន់ទីនេះដើម្បីធ្វើកិច្ចការដែលមានសារៈសំខាន់សម្រាប់អនាគតនៃប្រទេសជាតិរបស់យើង ។ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាត្រូវបានទទួលស្គាល់ថាមានការផ្លាស់ប្តូរយ៉ាងល្អប្រសើរគួរឲ្យកត់សម្គាល់ ទាំងទិដ្ឋភាពនយោ-បាយ សន្តិសុខ សេដ្ឋកិច្ចសង្គម ពាណិជ្ជកម្ម និងវិនិយោគ... ស្ថានភាពនយោបាយនៅកម្ពុជាមានលក្ខណៈល្អប្រសើរ និងកំពុងមានការអភិវឌ្ឍលើគ្រប់វិស័យ ហើយសេដ្ឋកិច្ចនៅតែបន្តរីកចម្រើន ។ ប៉ុន្តែយើងនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើនៅក្នុងតំណាក់កាលថ្មីនេះ ដើម្បីទាញយកអត្ថប្រយោជន៍ពីសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសមាហរណកម្ម ក្នុងតំបន់កាន់តែទូលំទូលាយ ព្រមទាំងធ្វើពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់យើងក្នុងសេដ្ឋកិច្ចពិភពលោក ។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានមានប្រសាសន៍ថា សម្តេចពិតជាមានការរីករាយចំពោះសមិទ្ធផលទាំងអស់នេះដែលបានចេញមកពីការខិតខំរួមគ្នាពីស្មារតីសាមគ្គីភាព និងការយោគយល់គ្នា ហើយក្នុងនោះការចូលរួមរបស់វិស័យឯកជន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ តួយ៉ាងដូចជាការបោះទុនវិនិយោគរួមគ្នារបស់ក្រុម-ហ៊ុន ជីប ម៉ុង គ្រុប ដែលជាក្រុមហ៊ុនក្នុងស្រុករបស់យើងជាមួយនឹង ក្រុម-ហ៊ុន ស៊ីយ៉ាម ស៊ីធី ស៊ីមេន ផាប់ប្លិក ខមភ្រេនី លីមីតធីត ដែលជាក្រុមហ៊ុនវិនិយោគទុនបរទេសមួយ មានបទពិសោធន៍ជាយូរឆ្នាំណាស់មកហើយក្នុងការផលិតស៊ីម៉ង់ត៍ធំជាងគេនៅក្នុងតំបន់អាស៊ាន ។ ដូច្នេះការចាប់ផ្តើមអនុវត្តគម្រោងសាងសង់រោងចក្រស៊ីម៉ង់ត៍ដ៏ធំនៅក្នុងខេត្តកំពត នាពេលនេះ គឺជាការចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ក៏ដូចជាការវិនិយោគលើអនាគតរបស់កម្ពុជាផងដែរ ។ តាមរយៈស្នាដៃ និងបទពិសោធន៍ដែលធ្លាប់មាន សម្តេចមានទំនុកចិត្តថា រោងចក្រស៊ីម៉ង់ត៍ដ៏ធំដែលនឹងត្រូវបញ្ចុះបឋមសិលាក្នុងពេលបន្តិចទៀតនេះ នឹងទទួលបានជោគជ័យតាមការគ្រោងទុកជាក់ជាមិនខាន ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៦ សម្តេចក្រឡាហោម **ស ខេង** អនុប្រធានគណបក្ស ប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អមដំណើរដោយឯកឧត្តម **ច័ន្ទ សុផល** អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធ កាត់ឫសសីមាព្រះវិហារថ្មី វត្តគីរីរម្យសន្តិភាព ហៅវត្តអូរចោត ស្ថិតក្នុងភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

*ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** អនុប្រធានគណបក្ស ប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសពលោកអនុសេនីយ៍ឯក យ៉ាវ ប៉ូ៉ា មន្ត្រីនគរបាលចរាចរ ដែលបានទទួលមរណភាពក្នុងពេលបំពេញបេសកកម្មកាលពីថ្ងៃអាទិត្យទី ១៣ ខែមីនា ឆ្នាំ ២០១៦ ក្នុងជន្មាយុ ៥៤ ឆ្នាំ ដែលក្នុងឱកាសនោះ សម្តេចភក្តីក៏បានឧបត្ថម្ភគ្រួសារសពចំនួន ៣ លានរៀល ផងដែរ ។*

ក្នុងខែមីនា ឆ្នាំ ២០១៦ នេះ ឯកឧត្តមបណ្ឌិត **ឌួន ញ៉ិល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី ២ រដ្ឋសភា ប្រធានក្រុមការងារថ្នាក់កណ្ដាលចុះខេត្តកំពង់ធំ បានអញ្ជើញចុះបំពេញការងារនៅខេត្តកំពង់ធំ ដែលក្នុងនោះ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ម៉ុ តាំងយឿ** ភរិយាឯកឧត្តម **អ៊ុ សឿង** នាយករងឧទ្ធកាល័យ ឯកឧត្តមបណ្ឌិតអនុប្រធានទី២រដ្ឋសភា,អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយគណៈអចិន្ត្រៃយ៍គណបក្សខេត្តកំពង់ធំ និងគណៈអចិន្ត្រៃយ៍គណបក្សស្រុកសន្ទុក អំពីករណីពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋ និងគណបក្សឃុំបឹងល្ងា ស្រុកសន្ទុក ខេត្តកំពង់ធំ អំពីបញ្ហាទំនាស់ដីធ្លី និងបញ្ហាសន្តិសុខ,បានអញ្ជើញចុះពិនិត្យសមិទ្ធផលនានានៅវត្តឥន្ទ្ររង្សី (ហៅវត្តហាប់) ស្ថិតក្នុងភូមិទទាឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ , សមិទ្ធផលនានាក្នុងវត្តក្ដីអណ្ដែត សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដែលឯកឧត្តមបណ្ឌិតនឹងជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលទាំងនោះមុនពេលចូលឆ្នាំខ្មែរខាងមុខ ។ ក្នុងការចុះបំពេញការងារនោះ ឯកឧត្តមបណ្ឌិត **ឌួន ញ៉ិល** បានចំណាយថវិកាចំនួន ១៤.២០០$។

*ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ សម្តេចចៅហ្វាវាំង **គង់ សំអុល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រួមដំណើរដោយឯកឧត្តម **ប៉ា សុជាតិវង្ស** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលរាជធានីភ្នំពេញ បានអញ្ជើញពិនិត្យការដ្ឋានសាងសង់ច្រាំងទន្លេ និងផ្លូវថ្មីរជើងស្រុបមាត់ទន្លេចាប់ពីបញ្ជរព័ត៌មានទេចរណ៍រហូតដល់ស្ពានភ្លោះកោះពេជ្រ ។*

ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៦ លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានប្រគល់ថវិការបស់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ជូនលោកស្រី គង់ សារឿន អតីតជាមេបញ្ជាការកងអនុសេនាធំនារីដោះមីន ខេត្តស្វាយរៀង ដែលសព្វថ្ងៃនេះ លោកស្រីមានអាយុ ៥៩ ឆ្នាំ មានជំងឺស្ពឹកផ្នែកខាងឆ្វេងមួយចំហៀងខ្លួន ដែលធ្វើឲ្យងងឹតភ្នែកត្រចៀកថ្លង់ ហើយដៃ ជើង ពិបាកក្នុងការធ្វើចលនា ហើយបច្ចុប្បន្នរស់នៅភូមិអូរក្អាម ឃុំសំបួរ ស្រុកស្វាយទៀប ខេត្តស្វាយរៀង ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តម **ទេព ១ន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី២ ព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តមចុះពិនិត្យជំងឺដោយឥតគិតថ្លៃ និងចែកអំណោយជូនប្រជាពលរដ្ឋនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

ថ្ងៃទី ១៩ ខែមីនា ឯកឧត្តម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាប្រធានក្រុមការងារចុះជួយស្រុកសន្ទុក ខេត្តកំពង់ធំ និងលោកជំទាវ បានអញ្ជើញជាអធិបតីភាពក្នុងពិធីកាត់ឫសសីមាព្រះវិហារថ្មី និងសម្ពោធនូវសមិទ្ធផលនានាក្នុងវត្តរុក្ខាសត្ថារាម ហៅវត្ត ផ្ទុង នៅស្រុកសន្ទុក ខេត្តកំពង់ធំ ។

ថ្ងៃទី៥ ខែមីនា ឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជាអគ្គមេបញ្ជាការរង នាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ បានអញ្ជើញសម្ពោធផ្លូវក្រាលកៅស៊ូមួយខ្សែចូលទៅទីបញ្ជាការកងពលតូចអន្តរាគមន៍លេ ខ៩ ដែលមានទីតាំងស្ថិតនៅចំណុចភូមិសែនរុងរឿងមួយឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តម **ស៊ុយ សែម** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងលោកជំទាវ **ជា ១១** បានអញ្ជើញកាត់ខ្សែបូណ៌ និងបញ្ចុះខ័ណ្ឌសីមាព្រះវិហារថ្មី វត្តពោធិ៍ដុះ ហៅវត្តពោធិ៍ល្ងុំ ស្ថិតក្នុងឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

ថ្ងៃទី ០៦ ខែមីនា ឆ្នាំ ២០១៦ ឯកឧត្តម **ជា សុផារ៉ា** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទបានអញ្ជើញជាអធិបតីក្នុងវេទិកាសាធារណៈនៅឃុំជីវោទ៍ទី ១ ដោយបាននាំយកម៉ាស៊ីនបូមទឹកចំនួន ៣ គ្រឿង និងបំពង់ទីបជ័រជាង ៩០០ ម៉ែត្រ ដើម្បីបូមទឹកសង្គ្រោះដំណាំ និងសត្វពាហនៈរបស់ប្រជាពលរដ្ឋដែលជួបប្រទះកង្វះទឹកប្រើប្រាស់ ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

*ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ លោកជំទាវ **ហាន សំអាន** សមាជិកាគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មការទី ៨ នៃព្រឹទ្ធសភា និងឯកឧត្ដម **ទឹម ផន** សមាជិកគណៈកម្មការទី៩ ព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋចំនួន ៤០០ នាក់ នៅភូមិព្រៃទឹង និងភូមិឈើទាល ឃុំព្រៃទឹង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ដោយបានឧបត្ថម្ភថវិកាក្នុងម្នាក់ចំនួន៥,០០០ រៀល ។*

ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកឧត្ដម **ស្សោ ឌាវ៉ាត់** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជាប្រធានគណៈកម្មាធិការគណបក្សខេត្តព្រៃវែង និងសហការី បានអញ្ជើញពិនិត្យសកម្មភាពសាងសង់ផ្ទះដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឧបត្ថម្ភជូនលោកយាយ ចាន់អូន នៅភូមិហាប់ ឃុំគោខ្ជក ស្រុកកំពង់ត្រាំបែក ខេត្តព្រៃវែង ដែលមកដល់ពេលនេះសាងសង់បាន ៥0% ហើយ ។

ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មការទី ៣ នៃព្រឹទ្ធសភា បានអញ្ជើញពិនិត្យការងារជីកស្រះទឹកជូនប្រជាជននៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ សម្រាប់ផ្ដល់ទឹកជូនប្រជាជននៅភូមិព្រៃដងទឹកប្រមាណជាង ១៥៩ គ្រួសារស្មើនឹង ៦០០នាក់ និងសិស្សានុសិស្សអនុវិទ្យាល័យពន្លឺកុលបុត្រ បឋមសិក្សាពន្លឺកុលបុត្រ ប្រមាណជាង ១២០០ នាក់ និងប្រជាពលរដ្ឋជាង ១ ៣ន់ គ្រួសារផ្សេងទៀតនៃភូមិព្រៃខ្លា និងភូមិទួលធ្នង់ ស្រុកគងពិសី ដែលកំពុងប្រឈមមុខនឹងការខ្វះខាតទឹកស្អាតដើម្បីទទួលទាន និងប្រើប្រាស់ប្រចាំថ្ងៃ ។

*ថ្មីៗនេះ ឯកឧត្ដមបណ្ឌិត **ហ៊ុន ម៉ាណែត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្ដម **លន់ ឈីមថៃ** អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម បានអញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះខណ្ឌសីមានិងសម្ពោធសមិទ្ធផលនានាក្នុងវត្តពោធិព្រឹក្ស ហៅវត្តក្រូចក្នុងភូមិក្រូច ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។*

ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៦ ឯកឧត្ដម **ហ៊ុន ម៉ានី** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ បានអញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងសម្ពោធឆ្លងសមិទ្ធផលនានា ក្នុងវត្តបទុមវ៉ត (ហៅវត្តក្រាំងក្រូច) ស្ថិតនៅឃុំស្ទុំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តម **សាយ សំអាល់** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមការងារចុះជួយស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងជួយដោះស្រាយបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋនៅភូមិស្វាយពក ឃុំមៀន ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ។

*ថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១៦ ឯកឧត្តម **ម៉ា សុជាតិវង្ស** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជាអភិបាលរាជធានីភ្នំពេញនិងប្រតិភូរដ្ឋបាលខណ្ឌទាំង ១២ មន្ទីរ សាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ និងថវិការបស់សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ទៅ ឧបត្ថម្ភជូននាយទាហាន ពលទាហាន នៃទីបញ្ជាការកងពលតូចអន្តរាគមន៍លេខ ៩ ស្ថិត នៅតំបន់អូរជុញ ភូមិសែនរុងរឿង ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។ ក្រៅពីអំណោយខាងលើនេះលោកអភិបាលក្រុងក៏បានផ្ដល់ម៉ាស៊ីនច្រូត ស្រូវ ១ គ្រឿង និងគ្រាក់ទ័រ ២ គ្រឿង ជូនកងពលសម្រាប់បង្កបង្កើនផលក្នុងអង្គភាពផងដែរ ។*

ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ឯកឧត្តម **ហ៊ៅ ធនិន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងសម្របសម្រួលជម្លោះរវាងបងប្អូនអាជីវ-ករក្នុងផ្សារថ្មីពោធិ៍សាត់ដែលក្នុងឱកាសនោះ ឯកឧត្តម **ហ៊ៅ ធនិន** បានសំណូមពរដល់បងប្អូនអាជីវករដែលមានមុខរបរទទួលទានក្នុងផ្សារថ្មីពោធិ៍សាត់ ជាពិសេសប៉ែកខាងមុខ ត្រូវស្រុះស្រួលអធ្យាស្ស័យគ្នាទៅវិញទៅមក កុំបង្កឲ្យមានជម្លោះ និងត្រូវចូលរួមសហការគ្នារៀបចំជួរលក់ដូរឲ្យមានសណ្ដាប់ធ្នាប់ និងមានសោភណ្ឌភាព ។

*ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តម **ចន្ធ័ សុផល** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជាអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបងអមដំណើរដោយលោកអភិបាលក្រុង និងសហការី បានអញ្ជើញពិនិត្យការស្តារប្រឡាយមេគយ ធ្លាក់ និងការជួសជុលស្តារប្រពន្ធ័លូរ៉ូដោះទឹកដើម្បីកុំឱ្យទឹកលិចភូមិនារដូវវស្សាខាងមុខនេះ ។សូមបញ្ជាក់ថាប្រឡាយនេះមិនអាចចូលស្តារបានទេទើបតែបច្ចុប្បន្ននេះអាចយកគ្រឿងចក្រចូលស្តារដើម្បីឱ្យទឹកពីផ្សារបឹងឈូកមានមុខចេញពីទួលតាឯក ក៏បង្ហូរតាមប្រឡាយនោះដែរ ។*

ថ្ងៃទី ៨ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តម **ហ៊ុន ម៉ានិត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា នាយករងខុទ្ទ-កាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋ-មន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្ដាល ចុះជួយស្រុកចំការលើ ខេត្តកំពង់ចាម បានអញ្ជើញជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋនៅក្នុងឃុំចម្ការអណ្ដូង ស្រុកចំការលើ ក្នុងឱកាសនៃពិធីបុណ្យផ្កាមហាសាមគ្គី ដើម្បីប្រមូលបច្ច័យកសាងឧបដ្ឋានសាលានៅក្នុងវត្តអម្ពវនារ៉ាម ទួលស្វាយជ្រុំ ហៅវត្តចំការអណ្ដូង ស្រុកចម្ការលើ ខេត្តកំពង់ចាម ។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

*ក្នុងឱកាសបំពេញទស្សនៈកិច្ចសិក្សា នៅសាធារណរដ្ឋប្រជាមានិតចិន គណៈប្រតិភូគណបក្សប្រជាជនកម្ពុជាដឹកនាំដោយឯកឧត្តម **កែ ប៊ុនខៀង** ជាប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាលឯកឧត្តម **ហ៊ីន ម៉ាណែត** អនុ-ប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងសមាជិកសមាជិកាដែលមកពីរាជធានី-ខេត្តទាំង ២៥ និងក្រសួង-ស្ថាប័ន សរុប ៥៧ រូប ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ មីនា ឆ្នាំ២០១៦។ តំណាងប្រតិភូចំនួន ៨ រូបបានចូលជួបសម្ដែងការគួរសមជាមួយឯកឧត្តម **សុង ចាវ** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិមជ្ឈិមបក្សកុំមុយនីស្ដចិននៅទីស្ដីការក្រសួងនៅថ្ងៃទី១៥ខែមីនាឆ្នាំ២០១៦ បន្ទាប់មកឯកឧត្តមរដ្ឋ-មន្ត្រីបានរៀបចំពិធីអាហារសាមគ្គីជូនគណៈប្រតិភូក្នុងបរិយាកាសរីករាយនិងស្និទ្ធស្នាលជាទីបំផុត។*

នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៦ លោក **អ៊ីន ចាន់ជា** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារយុវជនគណបបក្ស ខេត្តព្រះវិហារ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារនៃយុវជនគណបក្ស ខេត្តព្រះវិហារ ក្រោមអធិបតីភាពឯកឧត្តម **គឹម រិទ្ធី** ប្រធានក្រុមការងារយុវជនតំបន់ ១ និងឯកឧត្តម **ឡុង សុវណ្ណ** អនុប្រធានគណបក្សខេត្ត ។

*នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ក្រុមការងារយុវជនគណបក្សប្រជា-ជនកម្ពុជាថ្នាក់កណ្ដាល និងគ្រប់ខេត្តចំនួន ៥៧រូប បានចូលរួមក្នុងពិធីចុះអនុ-សារណៈយោគយល់គ្នារវាងក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា ជាមួយសម្ព័ន្ធយុវជនបក្សកុម្មុយនីស្ដចិន នៅស្នាក់ការយុវជនបក្សកុម្មុយនីស្ដ រដ្ឋធានីប៉េងកាំង ក្រោមអធិបតីភាព ឯកឧត្តម **កែ ប៊ុនខៀង** ប្រធានក្រុមការងារយុវ-ជនគណបក្សថ្នាក់កណ្ដាល និងឯកឧត្តម Qin Yizhi លេខាទី១ នៃគណៈកម្មាធិ-ការកណ្ដាលរបស់សម្ព័ន្ធយុវជនបក្សកុម្មុយនីស្ដចិន ។*

ព្រឹកថ្ងៃទី២៧ខែកុម្ភៈឆ្នាំ២០១៦នេះ ឯកឧត្តម**សុខ លូ**សមាជិក ក្រុមការងារ យុវជនគណបក្សថ្នាក់កណ្ដាលនិងជាប្រធានក្រុមការងារ យុវជនគណបក្សខេត្ត កំពង់ធំ បានរៀបចំបោះឆ្នោតជ្រើសរើសសកម្មជនយុវជនគណបក្សចំនួនពីរភូមិ គឺភូមិសណ្ដាន់ និងភូមិជរ នៃឃុំសណ្ដាន់ ស្រុកសណ្ដាន់ នៅទីស្នាក់ការបក្សស្រុក សណ្ដាន់ ហើយក៏មានការចូល រួមផងដែរពីគ្រប់បណ្ដាគណបក្សឃុំនានា និងក្រុមការងារតាមបណ្ដាឃុំក្នុងស្រុកសណ្ដាន់ផងដែរ ដើម្បីយកពិសោធន៍នេះទៅអនុវត្តន៍តាម បណ្ដាភូមិ ឃុំរៀងៗខ្លួនអោយបានជោគជ័យ ។

*ព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៦នេះ ឯកឧត្តម **សុខ លូ** សមាជិក ក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាលនិងជាប្រធានក្រុមការងារ យុវជនគណបក្ស ខេត្តកំពង់ធំ បានរៀបចំបោះឆ្នោតជ្រើសរើសសកម្មជនយុវជនគណបក្សចំនួនពីរភូមិគឺភូមិសណ្ដាន់ និងភូមិជរ នៃឃុំសណ្ដាន់ ស្រុកសណ្ដាន់ នៅទីស្នាក់ការបក្សស្រុកសណ្ដាន់ ហើយក៏មានការចូលរួមផងដែរពីគ្រប់បណ្ដាគណបក្សឃុំនានា និងក្រុមការងារតាមបណ្ដាឃុំក្នុងស្រុកសណ្ដាន់ផងដែរ ដើម្បីយកពិសោធន៍នេះ ទៅអនុវត្តន៍តាម បណ្ដាភូមិ ឃុំរៀងៗខ្លួនអោយបានជោគជ័យ ។*

នៅរសៀលថ្ងៃទី៥ខែមីនាឆ្នាំ២០១៦ក្រុមការងារយុវជនគណបក្សខេត្តប៉ៃលិន បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងលើកទិសដៅអនុវត្ត សកម្មភាពការងារបន្តខែមីនា ឆ្នាំ២០១៦ ។ កិច្ចប្រជុំ នេះក៏មានការចូលរួមពីសំណាក់លោកជំទាវ **ជាន ស្រីមុំ** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងប្រធានយុវជនគណបក្សខេត្ត និងប្រធានយុវជនតាមបណ្ដាឃុំ សង្កាត់ទាំង ៨ ក្នុងខេត្តប៉ៃលិន សរុបចំនួន ៣៦នាក់ ។ កិច្ចប្រជុំប្រព្រឹត្តទៅតាមរបៀបវារៈ នីមួយៗរួមមាន ពិនិត្យរបាយការណ៍ប្រចាំខែកុម្ភៈ ពង្រឹងសមត្ថភាពការងារយុវជន និងអោយក្រុមការងារទាំង អស់បញ្ជូលរបាយការណ៍រាល់សកម្មភាពដែលបានអនុវត្តប្រចាំ ។

*នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកឧត្តម **ជាប ដារ៉ុត**សមាជិកក្រុមការងារ យុវជនគណបក្សថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារយុវជនគណបក្ស ស្រុកខ្សាច់កណ្ដាល បានធ្វើការរៀបចំវេទិកាសាធារណជាមួយយុវជន នៅ ឃុំចាក់ដាវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ដោយមានការចូលរួមពីយុវជន និងយុវតីយ៉ាងច្រើនកុះករផងដែរ ។*

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកឧត្តម **ស៊ូនី រង្សីសិដ្ឋ** ប្រធានក្រុមការ-ងារតំបន់៤ នៃក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅប្រទេសអូស្ត្រាលី-ណូវែលហ្សេឡង់ បានប្រារព្ធកម្មវិធីប្រកាសបញ្ចូលសមាជិកបក្សថ្មី ក្រោមអធិបតីភាព ឯកឧត្តមឯកអគ្គរាជទូត **ពុយ ឆួង** ។ ក្រុមការងារបានរៀបចំកម្មពិធីសំណេះសំណាលនិងអាហារសាមគ្គីជាមួយមហាគ្រួសារខ្មែរនិងនិស្សិតដែលកំពុងសិក្សានៅទីក្រុងប្រិសបិន ប្រទេសអូស្ត្រាលី ។

*នៅរសៀលថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១៦ នេះ ឯកឧត្តម **ហេង សួរ** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល បានជួបប្រជុំជាមួយថ្នាក់ដឹកនាំក្រុមប្រឹក្សាឃុំ ប្រធានមជ្ឈមណ្ឌលសុខភាព នាយកវិទ្យាល័យ បឋមសិក្សា មេភូមិ និងយុវជនមកពីឃុំចុងជាច នាងទើត និងទឹកជ្រៅ ។ តាមរយៈការពិភាក្សាគ្នាត្រង់ទៅត្រង់មកក្នុងនាមគ្រួសារ គណបក្សប្រជាជនដូចគ្នាសំដៅរកវិធីរក្សាបេះដូង និងទាក់យកបេះដូងប្រជាពលរដ្ឋក្នុងឃុំទាំង ៣ ថែមទៀត យើងបានរកឃើញនូវចំណុចប្រឈមរួមមាន ដូចជាម៉ូតូអត់ពន្ធក្នុងឃុំទាំង ៣ គឺមានរហូតដល់ទៅជាង ៤ ពាន់គ្រឿង មណ្ឌលសុខភាព មានការខ្វះខាតថ្នាំ និងឧបករណ៍ចាំបាច់មួយចំនួន ។ ចំនួនសិស្សក្នុងថ្នាក់រៀននីមួយៗ គឺច្រើនរហូតដល់ជាង ៦០ នាក់ក្នុង១ថ្នាក់ រីឯអគារ ជាពិសេសដំបូលសាលាមួយ ចំនួនក៏មានភាពទ្រុឌទ្រោម ។ កង្វះគ្រូវិទ្យាល័យ បណ្ដាញអគ្គីសនីភូមិខ្លះអត់មានរឿងលិខិតបញ្ជាក់កំណើត និងជួយសម្រួលសូវនាំរឿងបច្ចេកទេសធ្វើអត្តសញ្ញាណប័ណ្ណ ដោយឲ្យយុវជនភូមិ មេភូមិ យុវជនឃុំ និងក្រុមប្រឹក្សាឃុំ ធ្វើសំបុត្រកំណើត ហើយយកទៅប្រគល់ជូនគាត់តែម្តង ។*

នៅខេត្តបន្ទាយមានជ័យ ៖ នៅថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តម **ឡាយ គឹមលី** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល លោក **សូន បវរ** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារយុវជនខេត្ត បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារយុវជនគណបក្សខេត្ត និងត្រៀមរៀបចំសន្និបាតយុវជនខេត្ត ។

*នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តមបណ្ឌិត **ហ៊ីន ម៉ាណែត** អនុប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល បានចូលរួមពិធីប្រកាសទទួលស្គាល់សកម្មជនយុវជនគណបក្សប្រជាជនកម្ពុជា នៅស្រុកកោះសូទិន ខេត្តកំពង់ចាម។*

ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០១៦ ក្រុមការងារយុវជនគណបក្សខេត្ត បានចូលរួមពិធីប្រកាសសេចក្ដីសម្រេចកែសម្រួលក្រុមការងារយុវជន គណបក្សក្រុងព្រៃវែង និងក្រុមសកម្មជនយុវជនសង្កាត់ទាំង ៣ ចំនួន ៣៥ នាក់ ។ ពិធីនេះស្ថិតក្រោមអធិបតីភាពឯកឧត្តម **យ៉ាក់ ង៉ុយ** ប្រធានក្រុមការងារចុះជួយក្រុងព្រៃវែង ឯកឧត្តម **ង៉ិន ចាណាល់** ប្រធានក្រុមការងារយុវជនបក្សខេត្ត និងឯកឧត្តម **អ៊ុ ប៊ុនឡេង** អនុប្រធានគណបក្ស ។

*នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកឧត្តម **ក្ងន សារពេជ្រ** សមាជិកយុវជនគណបក្សថ្នាក់កណ្ដាល និងប្រធានក្រុមការងារយុវជនគណបក្សខេត្តកំពត បានដឹកនាំការប្រជុំប្រចាំខែកុម្ភៈ ដើម្បីត្រួតពិនិត្យផែនការ សកម្មភាពការ-ងារទាំងបីផ្នែក ។*

នៅព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកឧត្តម **ជាម ច័ន្ទសោភ័ណ** សមាជិកយុវជនគណបក្សថ្នាក់កណ្ដាល ប្រធានក្រុមការងារយុវជន គណបក្សខេត្ត និងជាប្រធានក្រុមការងារចុះជួយសង្កាត់ព្រែកព្រះស្ដេច ព្រមទាំងក្រុមការងារបានចុះសួរសុខទុក្ខ និងនាំអំណោយចែកជូនដល់ បងប្អូនប្រជាពលរដ្ឋដែលមានជំងឺប្រចាំកាយចំនួន ៥ គ្រួសារ ។ បន្ទាប់ពីជូនអំណោយដល់ប្រជាពលរដ្ឋ ឯកឧត្តមប្រធានបានជួបសំណេះសំណាលជាមួយសកម្មជនយុវជនគណបក្ស នៅទីស្នាក់ការគណបក្សសង្កាត់ ព្រែកព្រះស្ដេច ក្រុងបាត់ដំបង ។

លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

ចំណូលគយឆ្នាំ ២០១៥ និង ២ ខែដើមឆ្នាំ ២០១៦

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានឲ្យដឹងថា នៅក្នុងឆ្នាំ២០១៥ កន្លងមកនេះគយប្រមូលចំណូលពន្ធគយបានចំនួន ៥.៤៥៥ពាន់លានរៀល ឬប្រមាណ ១.៥៨១ លានដុល្លារអាមេរិក ពោលមានកំណើនប្រមាណ ១៧,៤% បើប្រៀបធៀបតួលេខឆ្នាំ ២០១៤ ។ ប្រាក់ចំណូលដែលសម្រេចបាននៅក្នុងឆ្នាំ ២០១៥ នោះគឺស្មើនឹង ១២១% នៃផែនការកំណត់ ។

ដោយឡែកចំណូលពន្ធគយរយៈពេល ២ ខែឆ្នាំ ២០១៦ សម្រេចបាន ២៩៣ លានដុល្លារ មានកំណើន ២៥%បើប្រៀបធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ ២០១៥ ។

សម្រាប់ទិសដៅការងារឆ្នាំ២០១៦ក៏ដូចជាយុទ្ធសាស្ត្រនិងកម្មវិធីការងារកំណែទម្រង់ និងទំនើបកម្មរដ្ឋបាលគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន៨គឺលើកកម្ពស់អភិបាលកិច្ចក្នុងអង្គភាពគយតាមក្រមសីលធម៌និងត្រូវប្រកាន់ខ្ជាប់នូវអភិក្រមទាំង៨ចំណុចរបស់ក្រសួង។ ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពនានា។ បន្តពង្រឹងសមត្ថភាពផ្នែកគោលនយោបាយគយ ការងារបច្ចេកទេសគយ និងកិច្ចសម្រួលពាណិជ្ជកម្ម រួមទាំងជំរុញគម្រោងបញ្ជីតែមួយ ។ ការបណ្តុះផ្នត់គំនិតវប្បធម៌រស់នៅ និងអាកប្បកិរិយាថ្មីដោយត្រូវបំពេញភារកិច្ចក្នុងនាមជាអ្នកផ្តល់សេវា និងចាត់ទុកអ្នកបង់ពន្ធជាអតិថិជន ។ បន្តពង្រឹងការបង្ក្រាបអំពើរត់ពន្ធនៅគ្រប់ភូមិសាស្ត្រ និងមុខសញ្ញាឲ្យបានជាប់ជាប្រចាំជាពិសេសការពង្រឹងនៅដើមទី ។ ពង្រឹងកាតព្វកិច្ចពន្ធអាករលើទំនិញគ្រប់ប្រភេទ ជាពិសេសលើទំនិញចម្រុះ ផលិតផលតេសិលា សម្ភារៈសំណង់ និងយានយន្ត។ បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរាល់ភាគីពាក់ព័ន្ធ។ ពង្រឹងអង្គភាពទំនាក់ទំនងជាមួយសាធារណជន តាមរយៈការឆ្លើយបំភ្លឺ និងដោះស្រាយកង្វល់ធុរជន និងប្រជាជនឲ្យទាន់ពេលវេលា ។

ចំណូលពន្ធដារខែកុម្ភៈ

នៅក្នុងខែកុម្ភៈកន្លងមកនេះ ពន្ធដារប្រមូលបានចំណូលពន្ធប្រមាណ ៣៨៣,៧ ពាន់លានរៀល ឬប្រមាណ ៩៦ លានដុល្លារអាមេរិក។ តួលេខនេះធ្វើឲ្យប្រាក់ចំណូលពន្ធដារសរុបរយៈពេល ២ ខែដើមឆ្នាំនេះសម្រេចបានជិត ៨៥០ ពាន់លានរៀល ឬប្រមាណ ២១២ លានដុល្លារ ស្មើនឹង ១៤,៩% នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ។

ចំណូលពន្ធខាងលើ បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៥ ឃើញថា ការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៦ កើនឡើងប្រមាណ ១៤,៩% ។

ក្នុងរយៈពេលពីរខែនេះដែរ មានការកើនឡើងនូវចំណូលពន្ធ-អាកតាមប្រភេទពន្ធសំខាន់ៗមួយចំនួន ដូចជាពន្ធលើប្រាក់ចំណេញកើនឡើងប្រមាណ ៩,៨%។ ពន្ធលើប្រាក់បៀវត្ស៍កើន១៥%។ អាកករលើតម្លៃបន្ថែមកើន ១៤,៩%និងអាករពិសេសកើន ១៩,៣%។ ទន្ទឹមនេះចំណូលពន្ធតាមសកម្មភាពអាជីវកម្មក៏មានការកើនឡើងស្ទើរតែទាំងអស់ដែរ ។

ទុនវិនិយោគពីប្រទេសជប៉ុនពីរខែដើមឆ្នាំ ២០១៦

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបង្ហាញថា រយៈពេល ២ ខែដើមឆ្នាំ ២០១៦ នេះ កម្ពុជាទទួលបានអ្នកវិនិយោគទុនជប៉ុនចំនួន១០ក្រុមហ៊ុន ដែលបានធ្វើការវិនិយោគគិតជាទុនសរុប ៧៣០ លានដុល្លារអាមេរិក។

បន្ថែមលើការវិនិយោគពីក្រុមហ៊ុនជប៉ុនធំៗទាំងនេះ ចំនួនភោជនីយដ្ឋានជប៉ុននៅកម្ពុជាបានកើនឡើងដល់២០០កន្លែង។ កំណើននៃក្រុមហ៊ុនជប៉ុនទាំងនេះបង្ហាញឲ្យឃើញពីភាពទាក់ទាញរបស់កម្ពុជាចំពោះវិនិយោគិនជប៉ុនក្នុងការធ្វើពាណិជ្ជកម្ម និងពង្រីកផលិតកម្ម ព្រមទាំងឆ្លុះបង្ហាញពីជំនឿទុកចិត្តរបស់វិនិយោគិនជប៉ុនចំពោះកម្ពុជា ។

ការវិនិយោគជប៉ុន បាននិងកំពុងរួមចំណែកដល់ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា បន្ថែមលើមូលដ្ឋានផលិតកម្មដែលមានស្រាប់ ដូចជាឧស្សាហកម្មផលិតសម្លៀកបំពាក់ និងស្បែកជើង, វិស័យកសិកម្ម រោងម៉ាស៊ីនកិនស្រូវ, វិស័យសំណង់ និងអចលនទ្រព្យ, វិស័យទេសចរណ៍ ដោយបញ្ចូលឧស្សាហកម្មថ្មីៗដូចជាការដំឡើងធុំសម្ភារៈបរិក្ខាអេឡិកត្រូនិក និងអគ្គិសនី,ការផលិតគ្រឿងបន្លាស់រថយន្ត និងការធ្វើដំឡើងមធ្យោបាយដឹកជញ្ជូនជាដើម ។

ពលករខ្មែរដែលកំពុងបំពេញការងារស្របច្បាប់ នៅក្រៅប្រទេសឆ្នាំ ២០១៥

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបង្ហាញថា ឆ្នាំ ២០១៥ កន្លងមក និងមកដល់បច្ចុប្បន្ន ពលករកម្ពុជាដែលកំពុងធ្វើការនៅក្រៅប្រទេសមានចំនួន ៦១៩ ៣៥៩ នាក់ ក្នុងនោះ ប្រទេសថៃចំនួន ៥៣៣ ៧០៧ នាក់, ប្រទេសម៉ាឡេស៊ី ៣៨ ៦៣៣ នាក់, ប្រទេសកូរ៉េខាងត្បូង ៤៤ ៣៣០ នាក់ ,ជប៉ុន ២ ២៨៨ នាក់ និងប្រទេសសឹង្ហបុរី ៤០១ នាក់។ ក្នុងនោះចំណូលជាមធ្យមក្នុងមួយឆ្នាំប្រមាណជាង ១ ០០០ លានដុល្លារអាមេរិក ។

នៅឆ្នាំ ២០១៥នេះដែរក្រសួងបានផ្តល់សេវាមុខរបរនិងរកការងារជូនប្រជាពលរដ្ឋចំនួន ៩៩ ៧០៨ នាក់ (ស្ត្រី ៦៦ ៥០៨ នាក់) ក្នុងនោះការងារក្នុងប្រទេសបានចំនួន ៧៣ ៤០៨ នាក់ (ស្ត្រី ៥៦ ៥៣០ នាក់) និងការងារក្រៅប្រទេសបានចំនួន ២៦ ៣០០ នាក់ (ស្ត្រី ៩ ៩៧៨ នាក់) រួមមាន : ប្រទេសថៃចំនួន ១៦ ១៦៣ នាក់ (ស្ត្រី ៦ ៥៣៧ នាក់), កូរ៉េខាងត្បូង ៧ ៨៣២ នាក់ (ស្ត្រី ១ ៨៤២ នាក់), ជប៉ុន ១ ៣៩៩ នាក់ (ស្ត្រី ៩១៥ នាក់),ម៉ាឡេស៊ី ៨០៧ នាក់ (ស្ត្រី ៥៤៥ នាក់) និងប្រទេសសឹង្ហបូរីចំនួន ៩៩ នាក់ (ស្ត្រី ៩៩ នាក់) ។

ចំនួនយានយន្ត

ក្រសួងសាធារណការ និងដឹកជញ្ជូនបានឲ្យដឹងថានៅឆ្នាំ ២០១៥ កន្លងមកនេះ មានយានយន្តដែលបានមកចុះបញ្ជីសរុបមានចំនួន ៣៩៨៥០២ គ្រឿង ក្នុងនោះម៉ូតូមានចំនួន ៣៤២០៧៦ គ្រឿងចំនួននេះកើនឡើង ២០,២៦% ធៀបនឹងឆ្នាំមុន ។ ដោយឡែករថយន្តគ្រប់ប្រភេទមានចំនួន ៥៦៤២៦ គ្រឿងកើនឡើង ៤២,៧៤% ធៀបនឹងឆ្នាំ ២០១៤។ បើគិតពីឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០១៥ យានយន្តបានចុះបញ្ជីសរុបមានចំនួន ៣២១០២២៣ គ្រឿង (ម៉ូតូ ២៧២៦១១៣ គ្រឿង និងរថយន្តចំនួន ៤៨៤១១០ គ្រឿង)។

ក្នុងឆ្នាំ ២០១៥ នេះដែរការងារផ្តល់អាជ្ញាប័ណ្ណយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនបានចំនួន ៤៣៩៧៥ គ្រឿង ។ ចំនួននេះកើនឡើង ២០,៤៨% ធៀបនឹងឆ្នាំ ២០១៤ ។ ដោយឡែកការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តធ្វើបានចំនួន ១៩៧០៤៣ គ្រឿង និងរថយន្តគ្រប់ប្រភេទចំនួន ១៩៧០៤៣ គ្រឿងកើនឡើង ៤១,៧៨% ។ ចំពោះការងារផ្តល់ប័ណ្ណបើកបរនៅឆ្នាំ ២០១៥ បានចេញប័ណ្ណបើកបរចំនួន ៩៧៥៨៧ ប័ណ្ណក្នុងនោះម៉ូតូ ៥០៦៧ ប័ណ្ណកើនឡើង ២០,២៦% និងរថយន្តគ្រប់ប្រភេទចំនួន ៩២.៥២០ ប័ណ្ណកើនឡើង ៤៧,៣៩% ធៀបនឹងឆ្នាំ ២០១៤ ។

ការចូលរួមដោះស្រាយទុនសម្រាប់ប្រជាកសិករប្រើប្រាស់ ក្នុងការបង្កបង្កើនផលកសិកម្ម

ដោយបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខែមីនា ឆ្នាំ២០១៦

I. សេចក្ដីផ្ដើម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបេសកកម្មក្នុងការចូលរួមកែលម្អជីវភាពរស់នៅរបស់ប្រជាកសិករតាមរយៈការលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្មលើគ្រប់ផ្នែក ។ ក្រោមការដឹកនាំ និងការចង្អុលបង្ហាញជាបន្តបន្ទាប់ប្រកបដោយគតិបណ្ឌិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែងបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងភាពជាដៃគូជាមួយអង្គការជាតិ និងអន្តរជាតិ បង្កើនថែមលើសមត្ថភាព និងលទ្ធភាពដែលមានស្រាប់ ដើម្បីបម្រើឲ្យឧត្តមប្រយោជន៍របស់ប្រជាជនកម្ពុជា ស្របតាមបេសកកម្មខាងលើ ។ ភាពជាដៃគូនេះមានគោលដៅក្នុងការបង្កើនផលិតភាពកសិកម្ម បង្កើនប្រភពចំណូលរបស់ប្រជាជន ផ្ដល់ភាពអង់អាច និងភាពជាម្ចាស់ដល់សហគមន៍នៅជនបទ ។

ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមដោះស្រាយបញ្ហាប្រឈមរបស់ប្រជាកសិករ តាមរយៈការអនុវត្តគម្រោងនានានៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា ។ ក្នុងចំណោមបញ្ហាប្រឈមចម្បង ។ បញ្ហាប្រឈមដ៏ជាក់ស្ដែងមួយត្រូវបានប្រជាកសិករលើកឡើងជាញឹកញាប់នោះគឺការខ្វះទុនសម្រាប់ការប្រកបរបរទទួលទាននៅក្នុងវិស័យកសិកម្ម ។ បញ្ហានេះបាននាំឲ្យមានការផ្ដួចផ្ដើម ក្នុងការសហការបង្កើតគម្រោងជាមួយអង្គការមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (International Fund for Agricultural Development-IFAD) ដើម្បីផ្ដល់ទុនជូនកសិករ សម្រាប់ទ្រទ្រង់ការងារបង្កបង្កើនផលកសិកម្មដែលជាប្រភពបង្កើតចំណូលដ៏សំខាន់ ។

II. ចក្ខុវិស័យនៃគម្រោង PADEE

នៅក្នុងឆ្នាំ ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ដល់ហិរញ្ញប្បទានជាមួយអង្គការ IFAD ដើម្បីអនុវត្តគម្រោងមួយដែលមានឈ្មោះថាគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (Project for Agricultural Development and Economic Empowerment -PADEE) ។ គម្រោងនេះ ត្រូវបានដឹកនាំសម្របសម្រួលអនុវត្ត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមអនុវត្ត ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មន្ទីរកសិកម្មខេត្ត មន្ទីរកិច្ចការនារីខេត្ត និងអង្គការអន្តរជាតិមួយចំនួន ។ ដោយផ្អែកលើបទពិសោធន៍ នៃការអនុវត្តគម្រោងផ្សេង ។ កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការ IFAD ក្នុងការសម្រួចទស្សនទាននៃការអនុវត្ត សំដៅធានាឲ្យបាននូវឥទ្ធិពលជាវិជ្ជមានធំធេងទៅលើកម្រិតជីវភាពរស់នៅរបស់ប្រជាកសិករ ។

III. សកម្មភាពនៃការអនុវត្តគម្រោង

គម្រោង PADEE បានកំណត់យកខេត្តចំនួន ៥ គឺខេត្តកណ្ដាល តាកែវ ស្វាយរៀង ព្រៃវែង និងកំពត ជាខេត្តគោលដៅ និងមានរយៈពេលអនុវត្ត រហូតដល់ឆ្នាំ ២០១៨ ។ ជាមួយនឹងការគាំទ្រពីអង្គការ IFAD ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងដឹកនាំអនុវត្តគម្រោង ដោយផ្អែកលើការផ្ដល់ទុនជូនកសិករសម្រាប់ប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម ។

គំនិតសំខាន់ក្នុងការជួយកសិករ តាមរយៈការអនុវត្តគម្រោងនេះ គឺការធានាឲ្យបាននូវប្រសិទ្ធភាព និងនិរន្តរភាពនៃការប្រើប្រាស់ទុនដែលគម្រោងផ្តល់ជូនកសិករ មានន័យថាកសិករអាចទទួលបានផលប្រយោជន៍ច្រើន ហើយសមិទ្ធផលអាចរក្សាបាននៅគង់វង្សនៅក្រោយពេលគម្រោងបញ្ចប់។

ក្នុងន័យនេះ គម្រោងបាន និងកំពុងខិតខំរៀបចំនូវរបៀបរបប និងប្រព័ន្ធការងារច្បាស់លាស់មួយជូនកសិករ ដើម្បីជួយឲ្យកសិករមានភាពជាម្ចាស់លើការប្រើប្រាស់ និងគ្រប់គ្រងទុន ដែលឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែងយូរអង្វែងរបស់កសិករ។ គម្រោងបានចាប់ផ្តើមជាមួយនឹងការចងក្រងក្រុមកសិករប្រើប្រាស់ទុន ដែលមានរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលសម្រាប់គ្រប់គ្រង និងដឹកនាំក្រោមលក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុម។

គម្រោងបានរៀបចំបង្កើតក្រុមចំនួន ៩៨៤ នៅក្នុងខេត្តគោលដៅទាំង ៥ ដោយក្នុងមួយក្រុមមានសមាជិកចំនួន ៥០នាក់។ ក្រុមនីមួយៗត្រូវទទួលបានទុនសរុបចំនួន ៤៨ លានរៀល (១២ ០០០ ដុល្លារអាមេរិក) ដោយគម្រោងផ្តល់ជូនជា ៣ ដំណាក់កាល គឺមួយដំណាក់កាល ១៦ លានរៀល (៤ ០០០ ដុល្លារអាមេរិក) ជូនក្រុមកសិករទាំងអស់ ហើយកសិករចំនួន ៤៩ ២០០ គ្រួសារដែលជាសមាជិកបាននិងកំពុងទទួលផលប្រយោជន៍។ ទុនដែលផ្តល់ដោយគម្រោងចំនួន ៤៨ លានរៀល ក្នុងមួយក្រុម ត្រូវបានបែងចែកជាភាគទុនចំនួន ៩៦០ ០០០ រៀល សម្រាប់សមាជិកម្នាក់។ ប៉ុន្តែភាគទុននេះ សមាជិកមិនអាចដកបានទេ បើទោះបីជាគាត់លាឈប់ពីក្រុម ឬត្រូវបណ្ឍិតពីក្រុមក៏ដោយ ។ ក្រៅពីទុនដែលផ្តល់ជូនដោយគម្រោង ប្រភពថវិការបស់ក្រុមអាចទទួលបានពីការស្ម័គ្រចិត្តចូលភាគទុនបន្ថែមរបស់សមាជិកម្នាក់ៗ ហើយសមាជិកអាចដកភាគទុននេះវិញបាន ។

សមាជិកអាចខ្វីប្រាក់ពីក្រុមសម្រាប់គោលបំណង ២ សំខាន់ គឺ(១) ការប្រកបមុខរបរផ្សេងៗ ជាពិសេសនៅក្នុងវិស័យកសិកម្ម និង(២)ការដោះស្រាយបញ្ហាសង្គ្រោះបន្ទាន់។ សមាជិកអាចទទួលបានប្រាក់សម្រាប់គោលបំណងទី ១ នៅក្រោយពេលដែលក្រុមប្រឹក្សាភិបាលបានពិនិត្យ និងសម្រេចលើសំណើសុំខ្វីប្រាក់របស់សមាជិកដែលមានភ្ជាប់មកជាមួយនូវផែនការមុខរបរច្បាស់លាស់ ។ ផែនការមុខរបរនេះ គឺជាផែនការវិនិយោគរបស់សមាជិកសម្រាប់បង្កើតប្រាក់ចំណូលជូនគ្រួសារ ដែលអាចរៀបចំទៅតាមតម្រូវការជាក់ស្តែងរបស់គាត់ ដើម្បីស្នើសុំឥណទានពីក្រុម ។ ឥណទានមុខរបរ អាចផ្តល់ជូនសមាជិករហូតដល់ ៥ លានរៀលក្នុងកម្រិតអតិបរមា ដោយត្រូវមានអ្នកធានាចំនួន០៨នាក់ដែលជាសមាជិកក្នុងក្រុម និងស្របទៅតាមតម្រូវការសាច់ប្រាក់ក្នុងផែនការមុខរបរ ។ ដោយឡែកប្រាក់កម្ចីសម្រាប់ការងារសង្គ្រោះបន្ទាន់ អាចផ្តល់ជូនសមាជិកម្នាក់ៗបានច្រើនបំផុតចំនួន ៦០០ ០០០ រៀល ។

អត្រាការប្រាក់សម្រាប់ប្រាក់កម្ចីទាំង ២ ប្រភេទ ត្រូវបានកំណត់យ៉ាងតិចចំនួន ២% ក្នុងមួយខែ រីឯអត្រាដែលលើសពីនេះ ក្រុមអាចឯកភាពគ្នាកំណត់នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួន។ចំពោះឥណទានសង្គ្រោះបន្ទាន់ដែលមានរយៈពេលតិចជាង១ខែ ក្រុមពុំយកការប្រាក់នោះទេ។ ការប្រាក់ត្រូវបង់ចូលក្រុមដោយចាត់ទុកថាជាប្រាក់ចំណូលរបស់ក្រុម ហើយក្រុមប្រឹក្សាភិបាលអាចចាត់ចែងចំណូលការប្រាក់នេះសម្រាប់ចំណាយផ្សេងៗ។ ចំពោះប្រាក់ចំណេញដែលក្រុមទទួលបាន ក្រុមប្រឹក្សាភិបាលអាចចាត់-ចែងទៅតាមលក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុម ដូចជា ផ្តល់ប្រាក់ឧប-ត្ថម្ភលើកទឹកចិត្តជូនសមាជិកក្រុមប្រឹក្សាភិបាល និងផ្តល់ប្រាក់ភាគលាភជូនសមាជិកជាដើម ។ ផ្នែកតាមលក្ខន្តិក: ប្រាក់របស់ក្រុមត្រូវយកតម្កល់ទុកនៅក្នុងធនាគារ និងអាចដកសម្រាប់ឲ្យសមាជិកខ្វី និងរក្សាទុកក្នុងហិបក្រៅធនាគារបានច្រើនបំផុតចំនួន ៨០០ ០០០រៀល។ ក្រោយចប់គម្រោងមូលនិធិទាំងអស់នឹងត្រូវប្រគល់ជូនក្រុមសម្រាប់ចាត់ចែងបន្តនៅក្នុងក្រុមស្របទៅតាមលក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុម ។

ក្រុមប្រឹក្សាភិបាលត្រូវបានកំណត់តួនាទី និងការទទួលខុសត្រូវលើកិច្ចការផ្តល់ឥណទានជូនសមាជិកដែលក្នុងនោះរួមមាន ពិនិត្យ និងសម្រេចលើសំណើសុំខ្វីប្រាក់របស់សមាជិក តាមដាន និងត្រួតពិនិត្យសកម្មភាពមុខរបរ ដែលបានលើកឡើងនៅក្នុងផែនការមុខរបររបស់សមាជិកនីមួយៗ ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗរបស់ក្រុម។ ហិរញ្ញិកដែលជាសមាជិក១ រូបក្នុងក្រុមប្រឹក្សាភិបាល ត្រូវបានប្រគល់ភារកិច្ចជាអ្នករក្សាទុកដាក់ប្រាក់របស់ក្រុម ធ្វើប្រតិបត្តិការជាមួយធនាគារ កត់ត្រាលំហូរសាច់ប្រាក់ និងរក្សាទុកឯកសារបញ្ជីស្នាមផ្សេងៗ ។

ជារួម គម្រោងPADEE បាននាំមកនូវអត្ថប្រយោជន៍ដល់ក្រុម និងសមាជិកក្រុម ដែលរួមមានជាអាទិ៍ ភាពជាម្ចាស់ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិការបស់ក្រុម អាចរៀបចំខ្លួនដើម្បីក្លាយជាសហគមន៍កសិកម្ម ការខ្វីសងមានលក្ខណៈសាមញ្ញ ងាយស្រួល ពុំចាំបាច់មានរបស់បញ្ចាំ និងស្ថិតនៅក្នុងភូមិរបស់សមាជិកផ្ទាល់តែម្តង ។

ពាក្យគន្លឹះនៅក្នុងការងារនៃគម្រោង PADEE ដែលយើងឃើញកន្លងមករួមមាន ៣ គឺផលប្រយោជន៍ ប្រសិទ្ធភាព និងនិរន្តរភាព ។ តើការផ្តល់ត្រឹមតែមូលនិធិដែលជាទុន និងការបង្កើតក្រុមកសិករទទួលទុនដែលមានក្រុមប្រឹក្សាភិបាលគ្រប់គ្រង និងដឹកនាំមានលក្ខណៈគ្រប់គ្រាន់សម្រាប់ធានាឲ្យសម្រេចបានតាមពាក្យគន្លឹះទាំង ៣ នេះដែរឬទេ? នេះគឺជាសំណួរដែលត្រូវបានពិចារណាក្នុងដំណាក់កាលដំបូង នៃការកសាងឯកសារគម្រោង ។

ចម្លើយនាពេលនោះគឺពុំទាន់គ្រប់គ្រាន់ទេ ចាំបាច់ត្រូវផ្តល់ការជួយឧប-ត្ថម្ភគាំទ្រមួយកញ្ចប់ ដែលរួមមាន (១)ការផ្តល់ទុន (២)ការចងក្រងក្រុមទុនបង្វិលដែលមានរចនាសម្ព័ន្ធដឹកនាំត្រឹមត្រូវ (៣) ការអភិវឌ្ឍសមត្ថ-ភាពតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ការបង្រៀនកសិករអំពីការរៀបចំផែនការមុខរបរទាំងក្នុង និងក្រៅវិស័យកសិកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការងារយេនឌ័រ និងអាហារូបត្ថម្ភ និង(៤)ការផ្តល់សេវាគាំទ្រដោយភ្នាក់ងារផ្សេងៗរបស់គម្រោង ។ ការជួយគាំទ្រស្របតាមទស្សនទានេះអាចឲ្យយើងសង្ឃឹមបានថាកសិករមានទុនសម្រាប់ប្រើប្រាស់យូរអង្វែងក្នុងការងារផលិតកម្ម និងអនុវត្តផលិតកម្មបានសមស្របតាមបច្ចេកទេស ហើយឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ។

ក្នុងការអនុវត្តគម្រោងកន្លងមក អង្គភាពជំនាញពាក់ព័ន្ធចំណុះក្រសួង

កសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានដឹកនាំការកសាងសមត្ថភាពលើផ្នែកបច្ចេកទេសផលិតកម្មកសិកម្ម ដែលរួមមានការដាំដុះដំណាំស្រូវ បន្លែ ការចិញ្ចឹមសត្ត និងវារីវប្បកម្មជាដើម ។ ជាមួយនឹងការរៀបចំកម្មវិធីបណ្ដុះបណ្ដាលច្បាស់លាស់ កសិករទទួលបាននូវចំណេះដឹង និងចំណេះធ្វើ និងយល់ដឹងកាន់តែច្បាស់អំពីបច្ចេកទេស ដូចជា ការជ្រើសរើសពូជ ការគ្រប់គ្រងជីជាតិដី ការគ្រប់គ្រងទឹក ការគ្រប់គ្រងសមាសភាពចង្រៃ វិធីសាស្ត្រដាំដុះ វិធីសាស្ត្រចិញ្ចឹមសត្ត បច្ចេកទេសប្រមូលផល ។ល។ ក្រៅពីនេះ មន្ត្រីនៃអគ្គនាយកដ្ឋានកសិកម្ម ត្រូវបានចាត់តាំងឲ្យតាមដានអំពីដំណើរការនៃការបណ្ដុះបណ្ដាល និងការទទួលយកទៅអនុវត្តរបស់កសិករទៅតាមបច្ចេកទេស ។ ដូច្នេះចំណុចខ្វះខាត និងចំណុចចន្លោះប្រហោងនៅក្នុងការអនុវត្តត្រូវបានតាមដាន និងជួយកែសម្រួលជាប់ជាប្រចាំ ។

ជាសក្ខីភាពគ្រប់សមាសភាគរបស់គម្រោង បានបំពេញឲ្យគ្នាទៅវិញទៅមក ដែលប្រការនេះអាចឲ្យកសិករទទួលបានទុន ចំណេះដឹង និងប្រព័ន្ធការងារគ្រប់គ្រងមួយ ដែលអាចជួយធានានូវនិរន្តរភាពនៃការប្រើប្រាស់ទុនបង្វិលនៅក្នុងក្រុមនីមួយ។ និងឥទ្ធិពលជាវិជ្ជមានលើការបង្កបង្កើនផលកសិកម្ម និងជីវភាពរស់នៅរបស់កសិករ ។ លទ្ធផលនៃការវាយតម្លៃកន្លងមកបានបង្ហាញថា ការផ្ដល់ទុន និងចំណេះដឹងបច្ចេកទេសកសិកម្មបានជួយជំរុញពិពិធកម្មនៃផលិតកម្មកសិកម្មគ្រួសារ ពិពិធកម្មនៃប្រភពចំណូលនិងកំណើនប្រាក់ចំណូលក្នុងគ្រួសារ។ កត្តានេះបានធ្វើឲ្យមានការប្រែប្រួលជាវិជ្ជមានលើសូចនាករសំខាន់ពីរ គឺ ទ្រព្យសម្បត្តិរបស់គ្រួសារកសិករមានការកើនឡើង និងអត្រាប្រេវ៉ាឡង់នៃកុមារខ្វះអាហារូបត្ថម្ភដែលមានអាយុក្រោម ៥ ឆ្នាំ ត្រូវបានកាត់បន្ថយ ។

ជាសក្ខីភាព ក្រុមកសិករទុនបង្វិលមួយក្រុម ក្នុងភូមិទួលវិហារ ឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ត្រឹមឆ្នាំ ២០១៥ បានទទួលទុនគ្រប់ចំនួន ៤៨លានរៀលពីគម្រោង។ ការរៀបចំឲ្យសមាជិកខ្ចីដោយយកការប្រាក់ ២% ក្នុង ១ ខែ កន្លងមក បានធ្វើឲ្យទុនសរុបរបស់ក្រុមបានកើនឡើងដល់ ៥៩ ២៦៣ ១០០ រៀល គិតត្រឹមខែធ្នូ ឆ្នាំ ២០១៥ ។ សមាជិកបានខ្ចីប្រាក់តិច ឬច្រើនទៅតាមតម្រូវការជាក់ស្ដែងក្នុងចន្លោះពី ១ លានរៀល ទៅ ៣ លានរៀល ដើម្បីយកទៅប្រកបរបរដាំបន្លែ ចិញ្ចឹមមាន់ចិញ្ចឹមជ្រូក ដាំដំណាំស្រូវ ធ្វើស្ករត្នោត និងលក់ចាប់ហួយជាដើម ដោយទទួលបានលទ្ធផលជាវិជ្ជមាន បើទោះបីជាកសិករត្រូវប្រឈមជាមួយបញ្ហាមួយចំនួន ដូចជាការប្រែប្រួលអាកាសធាតុជាដើម ។ កសិករឈ្មោះ ប៉ោ ចេង ដែលជាសមាជិកមួយរូបនៅក្នុងក្រុមបានបង្ហាញចំណាប់អារម្មណ៍ថា គាត់មានការសប្បាយចិត្តយ៉ាងខ្លាំង ដោយគាត់អាចរកប្រាក់ចំណូលបានច្រើនលើសពីការរំពឹងទុកពីការលក់បន្លែ មាន់ និងត្រី ។ គាត់បានបញ្ជាក់ថា គាត់ឈប់ធ្វើចំណាកស្រុកចេញទៅធ្វើការសំណង់ ដែលត្រូវបែកឆ្ងាយពីគ្រួសារ ។ គាត់នឹងខិតខំពង្រីកមុខរបរដាំបន្លែ ស្រូវ ចិញ្ចឹមមាន់ និងត្រី ឲ្យទទួលបានជោគជ័យ ដោយបន្តអនុវត្តតាមបច្ចេកទេសដែលបានរៀនសូត្រពីសាលារៀនស្រែកសិករ ។ កសិករ ***ប៉ោ ចេង*** បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងមន្ត្រីគម្រោងទាំងអស់ដែលបានផ្ដួចផ្ដើមបង្កើតគម្រោងនេះឡើង និងយកចិត្តទុកដាក់ជួយកសិករក្រីក្រឲ្យមានជីវភាពប្រសើរឡើង ។

ដោយឡែក ក្រុមកសិករនៅក្នុងភូមិបឹងវែង ឃុំដំរីពួន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង មកដល់ឆ្នាំ២០១៥ នេះ ក៏ទទួលបានផលប្រយោជន៍ ដូចក្រុមក្នុងខេត្តស្វាយរៀងខាងលើដែរ ដោយកសិករឈ្មោះ សោម ចាន់ឌី លៃជា សមាជិកក្រុមបានគូសបញ្ជាក់ថា ជីវភាពគ្រួសាររបស់គាត់មានភាពប្រសើរឡើងបន្ទាប់ពីគាត់បានចូលគម្រោង PADEE ។ គាត់បានថ្លែងអំណរគុណដល់គម្រោង ដែលបានផ្ដល់ទុន និងចំណេះដឹងបច្ចេកទេសកសិកម្ម ដែលអាចឲ្យគាត់មានលទ្ធភាពអភិវឌ្ឍមុខរបរក្នុងវិស័យកសិកម្ម សម្រាប់បង្កើនចំណូលក្នុងគ្រួសារ ។

IV. សេចក្ដីសន្និដ្ឋាន

ជោគជ័យដែលសម្រេចបានប្រកបដោយក្ដីសង្ឃឹមខាងលើនេះ ពិតជាបានឆ្លុះបញ្ចាំងឲ្យឃើញពីលទ្ធផលនៃការខិតខំជួយគាំទ្រដល់កសិករ ឲ្យជម្នះបាននូវបញ្ហាប្រឈមក្នុងការបង្កបង្កើនផលកសិកម្ម ។ ប៉ុន្តែ ការខិតខំនេះពុំបានកម្រិតត្រឹមការផ្ដល់ទុន និងការបណ្ដុះបណ្ដាលបច្ចេកទេសសម្រាប់តែខេត្តគោលដៅទាំង ៥ នេះប៉ុណ្ណោះទេ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ធ្វើការកែលម្អជាបន្តបន្ទាប់នូវទស្សនទានៃការអនុវត្តគម្រោង ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់កសិករ ។ ជាក់ស្ដែង ការគិតគូរអំពីបញ្ហាទីផ្សារ និងការប្រែប្រួលអាកាសធាតុ ក៏ត្រូវបានដាក់បញ្ចូលនៅក្នុងយុទ្ធសាស្ត្រនៃកិច្ចសហការបង្កើត និងអនុវត្តគម្រោងនានាផងដែរ។ ដូច្នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិតជាមានមោទនភាពណាស់ក្នុងការសហការធ្វើជាដៃគូជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអង្គការ IFAD ដើម្បីចូលរួមអនុវត្តតាមបណ្ដាគំនិតផ្ដួចផ្ដើមនានា ប្រកបដោយការច្នៃប្រឌិតខ្ពស់ សំដៅជួយប្រែក្លាយជនបទឲ្យទៅជាតំបន់ដែលមានការរីកលូតលាស់ប្រកបដោយចីរភាព គ្មានភាពក្រីក្រធ្ងន់ធ្ងរ ប្រជាជនមានប្រាក់ចំណូលមានស្បៀង និងអាហារូបត្ថម្ភគ្រប់គ្រាន់ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ដ៏ត្រចះត្រចង់របស់រាជរដ្ឋាភិបាលកម្ពុជា ។

ឆ្នាំ ២០១៥ កងកម្លាំងនគរបាលជាតិសម្រេចបានលទ្ធផលដ៏ល្អប្រសើរក្នុងការបម្រើប្រជាជន

*សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្លែងសុន្ទរកថាក្នុងសន្និបាតប្រចាំឆ្នាំ ២០១៦ របស់ក្រសួងមហាផ្ទៃ*

ឆ្នាំ ២០១៥ កន្លងទៅនេះ កងកម្លាំងនគរបាលជាតិគ្រប់លំដាប់ថ្នាក់នៃក្រសួងមហាផ្ទៃបានខិតខំប្រឹងប្រែងបំពេញការងារ សម្រេចបានលទ្ធផលធំៗជាច្រើនក្នុងភារកិច្ចថែរក្សា ការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារ-ណៈ និងសុវត្ថិភាពសង្គម រាំងស្ដាត់បាននូវអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ព្រមទាំងសកម្មភាពទាំងឡាយ ដែលប៉ុនប៉ងបង្កឲ្យមានអសន្តិសុខ និងចលាចលក្នុងសង្គម ។

យោងតាមរបាយការណ៍ស្ដីពីលទ្ធផលការងារឆ្នាំ ២០១៥ និងលើកទិសដៅឆ្នាំ ២០១៦ របស់ក្រសួងមហាផ្ទៃដែលបានលើកឡើងក្នុងសន្និ-បាតប្រចាំឆ្នាំកាលពីខែកុម្ភៈឆ្នាំ ២០១៦ បានបង្ហាញថាក្នុងឆ្នាំ ២០១៥ កន្លងទៅសមត្ថកិច្ចបង្ក្រាបបទល្មើសព្រហ្មទណ្ឌបាន ២ ១៤១ ករណី ស្មើនឹង ៧៩% ឃាត់ខ្លួន ៣ ០៥២ នាក់(បទឧក្រិដ្ឋ ៤៩៧ ករណី ឃាត់ខ្លួន ៧០៥ នាក់ និងមជ្ឈិម ១ ៦៤៤ ករណី ឃាត់ខ្លួន ២ ៣៤៧ ករណី)ក្នុងនោះ បង្ក្រាបជាក់ស្ដែង ១ ៩២៣ ករណីស្មើ ៩០%ឃាត់ខ្លួន ២ ៧០៦ នាក់(ឧក្រិដ្ឋ ៤០៦ ករណី ឃាត់ខ្លួន ៥៣៤ នាក់ និងមជ្ឈិម ១ ៥១៧ ករណីឃាត់ខ្លួន ២ ១៧២ នាក់), បង្ក្រាបដោយស៊ើបអង្កេត ២១៨ ករណី ស្មើ ១០% ឃាត់ខ្លួន ៣៤៦ នាក់(ឧក្រិដ្ឋ ៩១ ករណី ឃាត់ខ្លួន ១៧១ នាក់ និងមជ្ឈិម ១២៧ ករណី ឃាត់ខ្លួន ១៧៥ នាក់) ,បង្ក្រាបដោយស៊ើបអង្កេតបណ្ដារឿងហេតុដែលកើតឡើងរយៈពេលមុនឆ្នាំ ២០១៥ បាន ២៦២ ករណីស្មើ ១២,២៦% ឃាត់ខ្លួន ៣៦២ នាក់(ឧក្រិដ្ឋ ៣១ ករណី ឃាត់ខ្លួន ៥៥ នាក់ និងមជ្ឈិម ២៣១ ករណី ឃាត់ខ្លួន ៣០៧ នាក់)។ រឹបអូសវត្ថុតាងបាន : អាវុធវែង ១៥ ដើម អាវុធខ្លី ៤៦ ដើម អាវុធកែច្នៃ ១០ ដើម គ្រាប់បែក ១៣ គ្រាប់ ម៉ូតូ ៧៧៨ គ្រឿង រថយន្ត ២៤ គ្រឿង និងឧបករណ៍ផ្សេងៗព្រមទាំងសម្ភារៈមាស ប្រាក់មួយចំនួន ។

កងកម្លាំងនគរបាលបានបង្ក្រាប និងបញ្ជូនមុខសញ្ញាក្មេងទំនើងទៅមណ្ឌលអប់រំ ៦៤១ នាក់ និងបញ្ជូនទៅសាលាដំបូងរាជធានីខេត្ត ៧១៩ នាក់ ស្រី ២៧ នាក់(ពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌនិងគ្រឿងញៀន)។ បង្ក្រាបល្បែងស៊ីសង ៣២៤ ករណី ឃាត់ខ្លួន ១៣២៦ នាក់(ស្រី ៤០០ នាក់)ក្នុងនោះ កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ១៣៧ ករណី មនុស្ស ៥២៧ នាក់(ស្រី ២០២ នាក់)រួមនឹងវត្ថុតាង ម៉ាស៊ីនហ្វាក់ ២១ គ្រឿង ម៉ាស៊ីនព្រីនធ័រ ២ គ្រឿង កុំព្យូទ័រ ២១៦ គ្រឿង ម៉ូតូ ៨៧ គ្រឿង រថយន្ត មួយគ្រឿង ទូហ្គេម ១០៧ គ្រឿង និងវត្ថុតាងបទល្មើសមួយចំនួនទៀត។ សមត្ថ-កិច្ចបានអប់រំ ធ្វើកិច្ចសន្យា ១៨៧ ករណី ស្មើនឹង ៧៩៩ នាក់ (ស្រី ១៩៨ នាក់) ។

ការងារស្រាវជ្រាវបង្ក្រាបបទល្មើសគ្រឿងញៀនបាន ២ ៣៥៦ ករណី ឃាត់ខ្លួន ៥ ០៣២ នាក់(ស្រី ៥៦៤ នាក់)ក្នុងនោះជនបរទេស ១២៧ នាក់ (ស្រី ៣០ នាក់)និងបង្ក្រាបតាមដីកា ១៥៨ ដីកា ឃាត់ខ្លួន ១៥២ នាក់(ស្រី ១០ នាក់)។ ជនល្មើស និងវត្ថុតាងត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត។ ក្នុងចំនួនរួមនៃការបង្ក្រាបខាងលើលេចធ្លោមាន ២ ករណីធំៗដែលមន្ទីរប្រឆាំងគ្រឿងញៀនបង្ក្រាបបានគឺ ដកហូតវត្ថុ-តាងគ្រឿងញៀនជិត ៥៥ គ.ក្រ ឃាត់ខ្លួនមនុស្ស ៣ នាក់ និងបង្ក្រាបករណីនាំកញ្ឆាស្ងួតមកពីប្រទេសឡាវទម្ងន់ ១ ៤៨៧ គ.ក្រ ប្រេងកញ្ឆា ១,៥០ គ.ក្រ ឃាត់ខ្លួន ៣ នាក់ ។

ការងារស្រាវជ្រាវបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ បាន ៩៤ ករណី ឃាត់ខ្លួន ១២៥ នាក់(ស្រី ៦២ នាក់)ជនបរទេស ១៧ នាក់, កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត និងរំដោះជនរងគ្រោះ ៣២៥ នាក់(បញ្ជូនទៅក្រសួងសង្គមកិច្ច ១០២ នាក់ អង្គការ ២ នាក់ គ្រួសារ ២២១ នាក់)រួមមាន:បទល្មើសអាជីវកម្មផ្លូវភេទ ៤៨ ករណី ឃាត់ខ្លួន ៦៩ នាក់(ស្រី ២០ នាក់)ជនបរទេស ១២ នាក់ រំដោះជនរងគ្រោះ ១៣៨ នាក់ និងបទល្មើសជួញដូរមនុស្ស ៤៦ ករណី ឃាត់ខ្លួន ៥៦ នាក់ (ស្រី ២០ នាក់) ជនបរទេស ៥ នាក់ រំដោះជនរងគ្រោះ ១៨៧ នាក់ ។

សហការជាមួយស្ថាប័នពាក់ព័ន្ធ បង្ក្រាបបទល្មើសសេដ្ឋកិច្ចបាន ៥០៣ ករណី រួមមានបទល្មើសព្រៃឈើ ជលផល កម្មសិទ្ធិបញ្ញា ជួញដូរសត្វព្រៃ ទំនិញខូចគុណភាព គ្មានស្លាកសញ្ញា និងហួសកាលបរិច្ឆេទ ចរាចរណ៍ ឱសថគ្មានច្បាប់ខូចគុណភាព ហួសកាលបរិច្ឆេទ និងគ្មានចុះបញ្ជី...។ វត្ថុតាង និងជនល្មើស:បញ្ជូនទៅរដ្ឋបាលជលផល ៥២ នាក់(វៀតណាម ៣ នាក់) រដ្ឋបាលព្រៃឈើ ៥៥ នាក់(វៀតណាម ៥ នាក់)សាខាកាំ-

ក្នុងត្រូល ៣ នាក់ ការិយាល័យអន្តោប្រវេសន៍ម្នាក់(រៀតណាម) សាលាដំបូងរាជធានីខេត្ត ៣៨ នាក់(រៀតណាមម្នាក់)និងអប់រំ ២៤ នាក់ ។

ដោយឡែក តាមរយៈការវាយតម្លៃរបស់ក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ "ភូមិឃុំមានសុវត្ថិភាព" ឆ្នាំ ២០១៥ បានបង្ហាញថាបទល្មើសព្រហ្មទណ្ឌជារួមថយចុះ ១០៥ លើក ស្មើនឹង ៤ % បើប្រៀបធៀបឆ្នាំ ២០១៤ (២.៧០៩/២.៨១៤ លើក) កើនឡើងលើ ៩៣៦/១.៦៣៣ ឃុំសង្កាត់នៅទូទាំងប្រទេស។ ក្នុងនោះមាន ១៥រាជធានី ខេត្ត ដែលបទល្មើសថយចុះ និងមាន ១០ ខេត្ត ដែលបទល្មើសមិនទាន់មានការថយចុះ ។

ចំណុចវិជ្ជមានដែលឆ្លុះបញ្ចាំងអំពីភាពជោគជ័យជាបន្តបន្ទាប់ក្នុងការអនុវត្តគោលនយោបាយ "ភូមិឃុំមានសុវត្ថិភាព" នោះគឺ : ១.បទល្មើសរួមទូទាំងប្រទេសថយចុះ ៤ % ស្របពេលដែលអត្រានៃការបង្ក្រាបមានកម្រិតខ្ពស់ស្មើនឹង ៧៩% (ក្នុងនោះបង្ក្រាបជាក់ស្តែង ៩០% នៃលទ្ធផលបង្ក្រាបរួម)។ ២.ឃុំសង្កាត់ ដែលជាប់ចំណាត់ថ្នាក់ប្រឡងប្រណាំងខ្ពស់និងមធ្យមកើនឡើង ១៤ ឃុំសង្កាត់ (លេខ១ កើនឡើង ១២ ឃុំសង្កាត់ ,លេខ ២ កើនឡើង ២ ឃុំសង្កាត់) ។ រីឯឃុំសង្កាត់ ដែលមានចំណាត់ថ្នាក់ទាប និងគ្មានចំណាត់ថ្នាក់ក៏បានថយចុះ ១៤ ឃុំសង្កាត់ (លេខ ៣ ថយចំនួន ៥ ឃុំសង្កាត់ និងគ្មានចំណាត់ថ្នាក់ថយចុះចំនួន ៩ ឃុំសង្កាត់) ។

ពិនិត្យតាមស្ថានភាពបទល្មើសទូទាំងប្រទេសឃើញថា ឆ្នាំ ២០១៤ ឃុំសង្កាត់ដែលគ្មានបទល្មើសមានចំនួន ៧០១ឃុំសង្កាត់។ តែនៅឆ្នាំ២០១៥ នេះឃុំសង្កាត់ដែលគ្មានបទល្មើសមានចំនួន ៦៩៧ ឃុំសង្កាត់ថយចុះចំនួន ៤ ឃុំសង្កាត់។ ផ្ទុយទៅវិញបើពិនិត្យលើលទ្ធផលប្រឡងប្រណាំងឃើញថា ឃុំសង្កាត់ដែលជាប់ចំណាត់ថ្នាក់លេខ ១ កើនឡើង ១២ ឃុំសង្កាត់ និងចំណាត់ថ្នាក់លេខ ២ កើនឡើងចំនួន ២ ឃុំសង្កាត់ ស្របពេលដែលចំណាត់ថ្នាក់លេខ ៣ ថយចំនួន ៥ ឃុំសង្កាត់ និងគ្មានចំណាត់ថ្នាក់ថយចុះចំនួន ៩ ឃុំសង្កាត់ ។

ក្នុងឆ្នាំ ២០១៥ នេះដែរ គ្រោះថ្នាក់សង្គមកើតឡើងចំនួន ៨ ០០៧ លើក(ស្លាប់ ៤ ៥៧១ នាក់ របួស ៨ ៥០៩ នាក់)ក្នុងនោះគ្រោះថ្នាក់ចរាចរណ៍ ៤ ៥៩៥/ ៤ ៨៤០ លើក ថយ ២៤៥ លើកស្មើ ៥%(ស្លាប់ ២ ២៦៥ នាក់/២ ១៤៨ នាក់ កើន ១១៧ នាក់,របួស ៧ ៥១០ នាក់/៨ ០៧៥ នាក់ ថយ ៥៤៧ នាក់),គ្រោះថ្នាក់ដោយអាវុធជាតិផ្ទុះ ៦០ លើក(ស្លាប់ ១៤ នាក់ របួស ៧០ នាក់),អគ្គិភ័យ ៥០៩ លើក(ស្លាប់ ៣៥ នាក់ របួស ២៨ នាក់ ឆេះផ្ទះ ៥៩៥ ខ្នង ឆេះតូប ៣ ១៧ តូប) ខ្យល់ព្យុះ ៤៣០ លើក(ស្លាប់ ១៤ នាក់ របួស ៩៥ នាក់ របើកដំបូល ៧ ១៣៥ ខ្នង រលំផ្ទះ ១ ៧៦០ ខ្នង), រន្ទះបាញ់ ១៧១ លើក (ស្លាប់ ១៣២ នាក់ របួស ៧៨ នាក់), អត្តឃាត ៧៥៦ លើក(ស្លាប់ ៧៤៣ នាក់ របួស ១៥ នាក់) ,ទឹកជន់ន់ ៦ លើក និងគ្រោះថ្នាក់ផ្សេងៗ ១ ៣៩៩ លើក(ស្លាប់ ១ ៣៦៨ នាក់ របួស ៧១ ១ នាក់)។

ចំពោះការងារពង្រឹង និងអនុវត្តនូវច្បាប់ស្តីពីអន្តោប្រវេសន៍ចាប់តាំងពីបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍រហូតមកដល់ចុងឆ្នាំ ២០១៥ ប៉ូលីសអន្តោប្រវេសន៍បានបណ្តេញចេញជនបរទេសខុសច្បាប់ សរុបចំនួន ៨.០៧៦ នាក់ (ស្ត្រី ១.២៨៣ នាក់) មាន ៦៨ សញ្ជាតិ ។

ចំពោះការងារផ្តល់អត្តសញ្ញាណប័ណ្ណជូនពលរដ្ឋក្នុងឆ្នាំ ២០១៥ កន្លងទៅនេះដែរ បានផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មីបាន ២ ៩១៤ ១៧៦ សន្លឹក។ បើសរុបពីដើមគ្រា គឺពីឆ្នាំ ២០១២ មកដល់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ ផលិតបាន ៦ ៧៥៥ ៦០៥ សន្លឹក ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាបច្ចុប្បន្នភាពអ្នកបោះឆ្នោតក្រសួងបានខិតខំជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណគំរូថ្មីតាមរយៈកិច្ចការនានាជាអាទិ៍ រៀបចំផែនការជំហានទី ៣ សម្រាប់ដំណើរការជំរុញផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ជូនដល់ប្រជាពលរដ្ឋគ្រប់អាយុទទួលបានប្រើប្រាស់គ្រប់ៗគ្នានៅក្នុងឆ្នាំ ២០១៦ លើផែនការ ១០ ៩៤៤ ១០១ នាក់ ។

ជាទិសដៅសម្រាប់ឆ្នាំ ២០១៦ លើការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ក្រសួងបានកំណត់ទិសដៅប្រមូលផ្តុំក្តាប់សភាពការណ៍ប្រែប្រួលនៃសកម្មភាពភេរវកម្មអន្តរជាតិ និងអង្គការចាត់តាំងភេរវកម្មទាំងក្នុង និងក្រៅតំបន់ ដោយធ្វើការវិភាគឲ្យបានល្អិតល្អន់តាមដំណាក់កាលនីមួយៗ នូវប្រភពព័ត៌មានដែលមានការពាក់ព័ន្ធដល់សន្តិសុខជាតិ និងចាត់វិធានការទប់ស្កាត់ឲ្យមានប្រសិទ្ធភាព ។

ពង្រឹងវិធានការជំនាញក្តាប់ព័ត៌មាន អំពីនិន្នាការប្រឆាំងគ្រប់ផ្នែកទាំងក្នុង និងក្រៅប្រទេស សំដៅរកឲ្យឃើញឧបាយកលញុះញង់បំបែកបំបាក់សាមគ្គីភាពប្រជាជាតិទាំងនៅក្នុងវិស័យសង្គម សាសនា និងវប្ប្ធម៌ ដែលមានគោលបំណង បង្កភាពច្របូកច្របល់ខាងនយោបាយគ្រប់រូប

សកម្មភាពបង្ក្រាបបទល្មើសជួញដូរគ្រឿងញៀនរបស់ សមត្ថកិច្ចនៃក្រសួងមហាផ្ទៃ

សកម្មភាពត្រួតពិនិត្យចរាចរណ៍របស់ ប៉ូលិសចរាចរណ៍

ភាព ប៉ះពាល់ដល់សុវត្ថិភាព សន្ដិសុខ សណ្ដាប់ធ្នាប់សង្គម ជាពិសេស សកម្មភាពភេរវកម្ម ដើម្បីមានវិធានការទប់ស្កាត់ និងដោះស្រាយឲ្យបានទាន់ពេលវេលា ។

-លើកកម្ពស់សមត្ថភាពខាងវិស័យបច្ចេកវិទ្យាព័ត៌មានវិទ្យា សំដៅចាត់វិធានការបង្ការ ទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសបច្ចេកវិទ្យា និងការយកបច្ចេកវិទ្យាធ្វើការវាយប្រហារ បង្កចលាចលសង្គម ។

- ខិតខំពុះពារកាត់បន្ថយបទល្មើសព្រហ្មទណ្ឌទូទៅ និងអំពើល្មើសច្បាប់ផ្សេងៗទៀតឲ្យមានការថយចុះ សម្រាប់បម្រើដល់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យឲ្យកាន់តែមានប្រសិទ្ធភាព ។ កិច្ចការនេះគឺសំដៅទៅលើការចូលរួមពីគ្រប់ថ្នាក់ គ្រប់ផ្នែកទៅតាមជំនាញ ក្នុងនោះការលើកវិធានការពង្រឹង និងបង្កើនសមត្ថភាព ។

-បន្តសកម្មភាពរឹតបន្ដឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មីនៅទូទាំងប្រទេស ។ ចាត់វិធានការតឹងរ៉ឹងចំពោះការបើកបរដោយគ្រឿងស្រវឹង បើកបរលើសល្បឿនកំណត់ ការដឹកជញ្ជូនសំពីងសំពោង ជិះលើសចំណុះ និងការប្រើប្រាស់រថយន្ដខុសបទដ្ឋានបច្ចេកទេស។ បន្ដជំរុញការផ្សព្វផ្សាយអប់រំច្បាប់ និងបទដ្ឋានសុវត្ថិភាពចរាចរណ៍តាមគ្រប់រូបភាពដើម្បីបង្កើនការយល់ដឹងដល់មន្ដ្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករ សិស្ស និស្សិត អ្នកបើកបររថយន្ដអាជីព ពិសេសអ្នកបើកបររថយន្ដដឹកកម្មករ ក្រុមហ៊ុនដឹកអ្នកដំណើរ ដឹកទំនិញ និងប្រជាពលរដ្ឋក្នុងសហគមន៍ ។

ដោយឡែក ចំពោះការងារអត្ដសញ្ញាណកម្មបានដាក់ជូនរាជរដ្ឋាភិ-បាលអនុម័តផែនការយុទ្ធសាស្ដ្រជាតិរយៈពេល ១០ឆ្នាំ(២០១៥-២០២៤) ស្ដីពីការងារអត្ដសញ្ញាណកម្ម និងកៀងគរដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រទាំងបច្ចេកទេស និងហិរញ្ញទាន ក្នុងការចាត់ចែងអនុវត្ដយុទ្ធសាស្ដ្រជាតិនេះ។ ទន្ទឹមនោះ រៀបចំក្រុមការងារចុះសិក្សារៀបចំទិន្នន័យដើមគ្រានៃការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដែលជាមូលដ្ឋានរៀបចំឲ្យមានសូចនា-ករជាក់លាក់ សម្រាប់វាស់វែងអំពីការលើកកម្ពស់ការងារអត្រានុកូលដ្ឋានស្របតាមសេចក្ដីព្រាងផែនការយុទ្ធសាស្ដ្រជាតិស្ដីពីអត្ដសញ្ញាណកម្ម ។

-សិក្សា និងអនុវត្ដសាកល្បងការផ្ដល់សេវាអត្ដសញ្ញាណកម្មទាំងអស់តាមរយៈការិយាល័យច្រកចេញចូលតែមួយ ដោយរៀបចំផែនការចម្លងយន្ដការការិយាល័យច្រកចេញចូលតែមួយ នៅតាមរដ្ឋបាលមូលដ្ឋាននានា ។

-សិក្សា ស្រាវជ្រាវកំណត់ឲ្យបានអំពីមូលហេតុដែលបណ្ដាលឲ្យអត្រានៃការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទមានការថយចុះ។

មន្ដ្រីទទួលបន្ទុកផ្នែកកិច្ចការអត្ដសញ្ញាណកម្ម ផ្ដល់អត្ដសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ

-តាមដាន ត្រួតពិនិត្យការអនុវត្ដប្រកាសស្ដីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅជូនប្រជាពលរដ្ឋ និងសហការជាមួយក្រុមបច្ចេកទេសគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប.) ពិនិត្យសម្រេចលើសេចក្ដីណែនាំរួមស្ដីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់អត្ដសញ្ញាណជូនប្រជាពលរដ្ឋ ក្នុងគោលដៅចុះឈ្មោះ និងការបោះឆ្នោត ។ ទន្ទឹមនោះ បន្ដបញ្ជូនទិន្នន័យពីប្រព័ន្ធអត្ដសញ្ញាណប័ណ្ណសញ្ញាតិខ្មែរជូនគ.ជ.ប.។

លើការងារអន្ដោប្រវេសន៍ បន្ដជំរុញកិច្ចសហការជាមួយដៃគូជាតិ និងអន្ដរជាតិ សំដៅលើកកម្ពស់ការងារគ្រប់គ្រងជនអន្ដោប្រវេសន៍នៅកម្ពុជាឲ្យមានប្រសិទ្ធភាព និងតាមលក្ខណៈបច្ចេកវិទ្យា ដោយលើកកម្ពស់ស្មារតីបំពេញការងាររបស់មន្ដ្រីក្រោមឱវាទ ។ បណ្ដុះបណ្ដាលជំនាញភាសាបរ-ទេស និងចំណេះដឹងលើការប្រើប្រាស់សម្ភារបច្ចេកទេសជំនាញ។ ពង្រឹងការគ្រប់គ្រង និងកែលម្អទីតាំងត្រួតពិនិត្យបែបបទអន្ដោប្រវេសន៍នៅតាមបណ្ដាច្រកទ្វារអន្ដរជាតិ និងច្រកទ្វារព្រំដែនអន្ដរជាតិ។ បន្ដអនុវត្ដផែនការលេខ ០១០ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៥ ស្ដីពីការបន្ដអនុវត្ដការងារគ្រប់-គ្រងជនបរទេសអន្ដោប្រវេសន៍ក្នុងព្រះរាជាណាចក្រកម្ពុជា និងបូកសរុបទិន្នន័យវត្ដមានជនបរទេសដែលរស់នៅមិនមានឯកសារត្រឹមត្រូវ ដើម្បីរៀបចំបែបបទបណ្ដេញចេញតាមនីតិវិធីច្បាប់ជាតិ និងអន្ដរជាតិ ។

សកម្មភាពបង្ក្រាបបទល្មើស និងការដុតបំផ្លាញទំនិញខូចគុណភាពរបស់សមត្ថកិច្ចនៃក្រសួងមហាផ្ទៃ

សកម្មភាពរបស់សមត្ថកិច្ចក្រសួងមហាផ្ទៃ ចាប់បញ្ជូនជនអន្ដោប្រវេសន៍ខុសច្បាប់ទៅកាន់ប្រទេសដើមវិញ

កំណែទម្រង់ក្នុងវិស័យ ឧស្សាហកម្ម និងសិប្បកម្ម បានណាំមកនូវការរីកចម្រើនថ្មី

រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ ដឹកនាំដោយសម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាកំពុងបោះជំហានឈានទៅមុខប្រកបដោយមោទនភាព ក្នុងស្ថាន-ភាពដែលសេដ្ឋកិច្ចកម្ពុជាកាន់តែមានភាពរឹងមាំ និងបន្តឆ្ពោះទៅសម្រេចគោលដៅកំណើនសេដ្ឋកិច្ច ៧ % ក្នុងមួយឆ្នាំក្នុងរយៈពេលមធ្យមខាងមុខទៀត ។

ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការបានថ្លែងនៅក្នុងអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៥និងលើកទិសដៅអនុវត្ត-ការងារឆ្នាំ ២០១៦ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មកាលពី ថ្ងៃទី ១ កុម្ភៈថា ក្នុងរយៈពេល២ទសវត្សរ៍មកនេះ កម្ពុជាសម្រេចបានកំណើនសេដ្ឋ-កិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ប្រមាណ ៧,៧%បើទោះបីត្រូវប្រឈមនឹងភាពមិនប្រាកដប្រជា និងហានិ-ភ័យច្រើន ទាំងនៅក្នុង និងក្រៅប្រទេសក៏ដោយ។ ឯកឧត្តម **គាត ឈន់** បានបញ្ជាក់ថា ប្រការនេះបានធ្វើឱ្យប្រទេសកម្ពុជាត្រូវបានស្ថាប័នហិរញ្ញ-វត្ថុអន្តរជាតិផ្តល់ចំណាត់ថ្នាក់ជាប្រទេសឯកទគ្គកំណើនទាំង ៨ នៅក្នុងពិភពលោក(Olympians of Growth) ។ នៅឆ្នាំ ២០១៣ កម្ពុជាសម្រេចបានកំណើន ៧,៤% និង ៧,១% នៅឆ្នាំ ២០១៤ ហើយតាមការគណនាកំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០១៥ សម្រេចបានក្នុងរង្វង់ ៧% ទៀត។ បើគិតនៅក្នុងផ.ស.សឆ្នាំ ២០១៥ ឧស្សាហកម្មបានរួមចំណែកប្រមាណជិត ២៧% ហើយក្នុងនោះឧស្សាហកម្មកាត់ដេរ និងសំណង់នៅតែជាកត្តាសំខាន់ក្នុងការរក្សាបានកំណើននេះ។ ការរីកចម្រើនលូតលាស់ផ្នែកសេដ្ឋ-កិច្ចនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បាននិងកំពុងជំរុញឲ្យអ្នកវិនិ-យោគទុនទាំងនៅក្នុងស្រុក និងបរទេសកាន់តែហ៊ានធ្វើការបណ្តាក់ទុនក្នុងការសាងសង់នូវរោងចក្រថ្មីៗជាច្រើនបន្ថែមទៀត នៅក្នុងប្រទេសកម្ពុជា ។

*ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការថ្លែងនៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៥ និងលើកទិសដៅអនុវត្តការងារឆ្នាំ ២០១៦ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម*

តាមរបាយការណ៍របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានឲ្យដឹងថា ក្រោយកំណែទម្រង់ក្នុងឆ្នាំ ២០១៥ កម្ពុជាបានចេញប្រកាសបង្កើតរោងចក្រថ្មីចំនួន ១៦០ រោងចក្រ និងបានបង្កើតការងារថ្មីចំនួន ៨០.៦៦៨ កន្លែង ។ ចំណែកសហគ្រាសធុនតូច និងមធ្យមបានចុះបញ្ជីសរុប ៣៧២ មូលដ្ឋាន និងបានបង្កើតការងារចំនួន ៤.៧៩៣ កន្លែង។ សរុបចំនួនរោង-ចក្រចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្មមានចំនួន ១.៤៥០ រោង-ចក្រ និងសហគ្រាសធុនតូច និងមធ្យម បានចុះបញ្ជីសរុប ៣៨.៨៣១ មូលដ្ឋាន ដែលមានបង្កើតការងារសរុប ១.០៥៣.៥៩៩ កន្លែង ។

ឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុកដែលលេចធ្លោក្នុងឆ្នាំ ២០១៥ មានផលិតទឹកស្អាតដោយនៅទូទាំងប្រទេសផលិតបានជាង ២២០ លានម៉ែត្រគុប កើនឡើង ១១,៨៧ % ។ តាមរបាយការណ៍បានអោយដឹងទៀតថានៅឆ្នាំ ២០១៥ តម្លៃសរុបបរិមាណផលិតផលនៃវិស័យឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជាដែលចេញពីការវិនិយោគក្នុងស្រុក និងពីបរទេសមានចំនួន ៨,៨៧៣ ពាន់លានដុល្លារអាមេរិកដោយបានកើនឡើង ២០%បើធៀបនឹងតួលេខកាលពីឆ្នាំ ២០១៤ ។

កម្មករ កម្មការិនីនៃរោងចក្រកាត់ដេរមួយកន្លែងក្នុងរាជធានីភ្នំពេញ

របាយការណ៍បានឲ្យដឹងថា ក្នុងចំណោមទឹកប្រាក់ទាំងនោះ គឺផ្នែកឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុកមានតម្លៃ ១,៨២២ ពាន់លានដុល្លារ និងឧស្សាហកម្មនាំចេញមានផ្នែកកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផ្សេងទៀតមានតម្លៃ ៧,១០២ ពាន់លានដុល្លារ ។ តម្លៃសរុបបរិមាណផលិតផលមានកំណើន ២០ % ហើយឧស្សាហកម្មនាំចេញមានកំណើន ១៧ % ចំណែកឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុកវិញមានកំណើន ៣៦%បើធៀបនឹងតួលេខកាលពីឆ្នាំ ២០១៤ ។

របាយការណ៍របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានឲ្យដឹងទៀតថាមកទល់បច្ចុប្បន្ន នៅកម្ពុជាមានពលករសរុប ៨៥៩.៥៤៦ នាក់ កំពុងបម្រើការងារក្នុងវិស័យឧស្សាហកម្ម ក្នុងនោះពលករបម្រើការក្នុងផ្នែក

អនុស្ថានីយ៍សម្រាប់បែងចែកចរន្តអគ្គិសនីបន្តទៅ
បណ្ដាខេត្ដនានាក្នុងព្រះរាជាណាចក្រកម្ពុជា

ឧស្សាហកម្មតម្បាញ កាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូបមានចំនួន ៧៥៤.១៨៨ នាក់ ។ ចំនួនពលករថ្មីដែលត្រូវបានរាប់បញ្ចូលក្នុងឆ្នាំ ២០១៥ មានចំនួន ៨០.៦៦៨ នាក់ ។

មន្ដ្រីក្រសួងឧស្សាហកម្ម និងសិប្បកម្មបានឲ្យដឹងថា ការសម្រេចបាននូវសមិទ្ធផលថ្មីៗទាំងនេះ គឺជាការរួមចំណែកដ៏ធំធេងដល់ដំណើរការអភិ-វឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ក្នុងការឈានទៅសម្រេចជោគជ័យនូវយុទ្ធសាស្ដ្រ-កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ពីព្រោះថា ការបង្កើតឡើងនូវ-រោងចក្រថ្មីទាំងនេះ វាមិនត្រឹមតែជួយធ្វើឲ្យប្រជាពលរដ្ឋមានការងារធ្វើ-ច្រើនប៉ុណ្ណោះទេ តែវាក៏នៅអាចជួយធ្វើឲ្យតម្លៃសរុបនៃបរិមាណផលិត-ផលឧស្សាហកម្មប្រចាំឆ្នាំមានកំណើនកាន់តែខ្ពស់ផងដែរ ។

បច្ចុប្បន្នប្រទេសកម្ពុជា ដែលមានការអភិវឌ្ឍ មានបរិស្ថានវិនិយោគល្អ-ហើយកម្លាំងពលកម្មនៅមានតម្លៃទាបនៅឡើយ បើធៀបជាមួយនឹង-បណ្ដាប្រទេសនៅក្នុងតំបន់ ដែលជាកត្តាធ្វើឲ្យក្រុមហ៊ុននានា មានទំនុក-ចិត្ដនៅក្នុងការបង្កើតរោងចក្រថ្មីៗកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំ ។

របាយការណ៍ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មក៏បានឲ្យដឹងថា-នៅឆ្នាំ ២០១៤ ចំនួនរោងចក្រជាក់ស្ដែងនៅទូទាំងប្រទេសមាន ១ ២៨៥-រោងចក្រ ក្នុងនោះរោងចក្រដែលបង្កើតថ្មីមានចំនួន ១៩៧ រោងចក្រ ។-រោងចក្រទាំងនោះរួមមានដូចជា រោងចក្រផ្ដែកអាហារ ភេសជ្ជ: និងបារី-រោងចក្រផ្ដែកឧស្សាហកម្មតម្បាញ កាត់ដេរសម្លៀកបំពាក់ ស្បែកជើង និង-កាបូប រោងចក្រផ្ដែកផលិតក្រដាស រោងចក្រផ្ដែកឧស្សាហកម្មគីមី កៅស៊ូ-និងប្លាស្ទិចរោងចក្រផ្ដែកផលិតកម្មពីរ៉ែមិនមែនលោហ: រោងចក្រផ្ដែក-គ្រឿងសង្ហារិម និងរោងចក្រផ្ដែកឧស្សាហកម្មផ្សេងៗមួយចំនួនទៀត ។-រោងចក្រទាំងអស់នេះ បានផ្ដល់ការងារឲ្យពលរដ្ឋកម្ពុជាធ្វើសរុបបាន-ចំនួនរាប់សែននាក់ហើយ និងជួយធ្វើឲ្យតម្លៃសរុបបានបរិមាណផលិត-ផលឧស្សាហកម្មប្រចាំឆ្នាំមានការកើនឡើងយ៉ាងខ្ពស់ផងដែរ ដែលជា-កត្តាធ្វើឲ្យកំណើនសេដ្ឋកិច្ចរបស់ប្រទេសកាន់តែមានភាពរឹងមាំ ។

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងជំរុញលើកទឹកចិត្ដដល់អ្នក-វិនិយោគ មិនត្រឹមតែការបង្កើតឡើងនូវរោងចក្រកាត់ដេរ និងវាយនភណ្ឌ-ធំៗថ្មីៗ ដើម្បីផ្ដល់ការងារឲ្យប្រជាពលរដ្ឋនៅក្នុងប្រទេសធ្វើការលើក-កម្ពស់កម្រិតជីវភាពរស់នៅ និងបង្កើនប្រាក់ចំណូលដល់សេដ្ឋកិច្ចជាតិ-ប៉ុណ្ណោះទេ តែកំពុងលើកទឹកចិត្ដ និងជំរុញឲ្យមានការធ្វើវិនិយោគទៅលើ-ផ្ដែកឧស្សាហកម្មផ្សេងៗទៀតដូចជា កាលពីពេលថ្មីៗកន្លងទៅនេះ ក្នុង-ដំណើរទៅបំពេញទស្សនកិច្ច នៅបណ្ដាប្រទេសឧស្សាហកម្មជឿនលឿន-មួយចំនួន សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** តែងតែធ្វើការ-ស្នើសុំទៅដល់រដ្ឋាភិបាល និងបណ្ដាអ្នកធ្វើធុរកិច្ចនៅក្នុងប្រទេសទាំងនោះ-ឲ្យចូលមកធ្វើការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើត-ឡើងនូវរោងចក្រសហគ្រាស ប្រយោជន៍ផ្ដល់ការងារដល់ប្រជាពលរដ្ឋធ្វើ-បានកាន់តែច្រើន និងបង្កើតនូវផលិតផលថ្មីៗនាំចេញ សម្រាប់ធ្វើការ-ប្រគួតប្រជែងនៅលើទីផ្សារអន្ដរជាតិ ។

ជាពិសេសកាលពីខែសីហា ឆ្នាំ ២០១៥ សម្ដេចអគ្គមហាសេនាបតីតេ-ជោ **ហ៊ុន សែន** នាយករដ្ឋមន្ដ្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាស-នូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដើម្បីជំរុញការអភិវឌ្ឍ-វិស័យឧស្សាហកម្មនៅកម្ពុជា រួមចំណែកដល់ការកក្ដាក់ណើនសេដ្ឋកិច្ច-ខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយ:ការធ្វើពិពិធកម្មសេដ្ឋកិច្ច-ការពង្រឹងភាពប្រគួតប្រជែង និងការលើកកម្ពស់ផលិតភាពជាដើម ។

នៅក្នុងការអនុវត្ដគោលនយោបាយនេះ រាជរដ្ឋាភិបាលបានផ្ដល់អាទិ-ភាពខ្ពស់លើវិធានការគោលសំខាន់ៗចំនួន ៤ ក្នុងនោះរួមមាន:ទី១.ការ-បញ្ចុះតម្លៃអគ្គិសនីសម្រាប់តំបន់ឧស្សាហកម្មគោល រួមទាំងការពង្រីក-វិសាលភាពគ្របដណ្ដប់ និងការលើកកម្ពស់ភាពទុកចិត្ដ ក្នុងការផ្ដត់ផ្ដង់-ចរន្តអគ្គិសនី,ទី២.ការរៀបចំ និងការអនុវត្ដផែនការមេសម្រាប់ការអភិវឌ្ឍ-ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទិកពហុមធ្យោបាយ,ទី៣.ការពង្រឹង និងការអភិ-វឌ្ឍយន្ដការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្ដុះបណ្ដាលជំនាញ និងទី-៤. ការអភិវឌ្ឍ និងការប្រែក្លាយខេត្ដព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចគំរូ-ពហុបំណង ។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះនៅកម្ពុជាមានប្រភេទរោងចក្រផ្សេងជា-ច្រើន ក្រៅពីរោងចក្រកាត់ដេរ វាយនភណ្ឌ និងស្បែងជើង ដូចជា រោងចក្រ-ផ្ដែកផលិតអាហារ រោងចក្រតម្បាញ រោងចក្រផ្ដែកឧស្សាហកម្មគីមី កៅស៊ូ-និងប្លាស្ទិក រោងចក្រផលិតស៊ីម៉ង់ត៍ ឥដ្ឋការ៉ូ ចាន ក្បឿង គ្រឿង បរិក្ខារ-អគ្គិសនី សម្ភារ:កីឡា ពុក្ដតា ពង់ ឆត្រ បរិក្ខារពេទ្យ សំបកកំប៉ុង ភេសជ្ជ:-បំពង់ដែកទីបអ៊ីណុក រហូតដល់រោងចក្រដំឡើងទោចក្រយាន និងយាន-យន្ដជាដើម ។ សរុបមកវិស័យឧស្សាហកម្មរបស់កម្ពុជាកំពុងតែមានការរីក-ចម្រើន តែនៅមានកម្រិតទាបនៅឡើយ ហើយភាគច្រើនជារោងចក្រកាត់-ដេរ និងវាយនភណ្ឌដែលជាប្រភេទឧស្សាហកម្មអតិពលកម្ម ប៉ុន្ដែផ្ដល់តម្លៃ-បន្ថែមទាប ។ ការរីកចម្រើនក្នុងដំណើរការ អនុវត្ដគោលនយោបាយអភិ-វឌ្ឍន៍វិស័យឧស្សាហកម្ម នឹងនាំមកនូវការប្រែប្រួលខ្លាំងក្នុងរចនាសម្ព័ន្ធ-សេដ្ឋកិច្ច បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ជាពិសេសនៅក្នុងសហ-គមន៍អាស៊ាននិងធ្វើឲ្យជីវភាពប្រជាជនកាន់តែត្រូវបានលើកកម្ពស់ឡើង ។

រោងចក្រផលិតស៊ីម៉ង់ត៍នៅខេត្ដកំពត

ល្បែងទាញព្រ័ត្រត្រូវបានចុះក្នុងបញ្ជីតំណាងនៃបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

ល្បែងទាញព្រ័ត្រត្រូវបានក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

លោកជំទាវរដ្ឋមន្ត្រីតំណាងរាជរដ្ឋាភិបាលកម្ពុជាទទួលវិញ្ញាបនបត្រ ទទួលស្គាល់ការបញ្ចូលល្បែងទាញព្រ័ត្រក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ ពីតំណាងអង្គការយូណេស្កូប្រចាំកម្ពុជា

"ទាញព្រ័ត្រ" ជាល្បែងមួយប្រភេទ ដែលគេបានស្គាល់ និងនិយមលេងស្ទើរទូទាំងសាកលលោក ។

នៅប្រទេសខ្លះ ទាញព្រ័ត្រវាគ្រាន់តែជាល្បែងសម្រាប់ល្បងកម្លាំងគ្នា រវាងមនុស្សពីរក្រុមតែប៉ុណ្ណោះ ។ ប៉ុន្តែនៅប្រទេសធ្វើកសិកម្មមួយចំនួននាតំបន់អាស៊ី ល្បែងទាញព្រ័ត្រគេនិយមលេងតែក្នុងឱកាសសំខាន់ណាមួយ ដែលមានលក្ខណៈពិសេស ហើយមានន័យភ្ជាប់ទៅនឹងសង្គម-សាសនាយ៉ាងមុតមាំ។ ដោយឡែកកម្ពុជា ក៏ស្ថិតក្នុងចំណោមប្រទេសធ្វើកសិកម្ម ដែលនិយមយក ល្បែងទាញព្រ័ត្រមកលេងសម្រាប់ជាការកំសាន្តផង ហើយបង្កប់នូវជំនឿនៅក្នុងនោះផង ។ ល្បែងទាញព្រ័ត្រត្រូវបានបងប្អូនអ្នកស្រុកខ្មែរនិយមលេងស្របគ្នាជាមួយនឹងល្បែងប្រពៃណីដទៃទៀតដូចជា បោះអង្គុញ ចោលឈូង លាក់កន្សែង ជាដើម ។ ល្បែងទាញព្រ័ត្រជាល្បែងប្រពៃណី ដ៏មានសារៈសំខាន់បំផុត ។ ល្បែងទាញព្រ័ត្រ បង្ហាញពីការច្នៃប្រឌិតបង្កប់ដោយ សិល្ប:ពោលគឺ យកពីទេពកថាក្នុងរឿង"ក្ងរសមុទ្រទឹកដោះ" ឲ្យមកជាល្បែងប្រពៃណីដ៏សមស្របទៅតាមបរិបទ និងតម្រូវការរបស់កសិករខ្មែរ ។

ល្បែងទាញព្រ័ត្រត្រូវបានប្រជាជនខ្មែរនិយមចូលចិត្តលេង នៅក្នុងឱកាសបុណ្យប្រពៃណីសំខាន់ពីរគឺ ពិធីបុណ្យចូលឆ្នាំ និងបុណ្យឆ្លងចេត្រ(ឆ្លងខែចេត្រ)។ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរប្រារព្ធឡើងរយៈពេលបីថ្ងៃ គឺនៅពាក់កណ្ដាលខែមេសា ។ តាមប្រពៃណីដូនតាពីសម័យបុរាណ ល្បែងទាញព្រ័ត្រគេនិយមលេងនៅថ្ងៃទី ៣ ឬថ្ងៃផ្ដាច់ព្រ័ត្រ ថ្ងៃចុងបង្ហើយនៃបុណ្យចូលឆ្នាំ ។ ចំណែកបុណ្យឆ្លងចេត្រនោះវិញ គឺប្រារព្ធឡើងនៅក្រោយបុណ្យចូលឆ្នាំបន្តិច តែពុំមានកំណត់ថ្ងៃជាក់លាក់ឡើយពោលគឺអាស្រ័យដោយការព្រមព្រៀងគ្នាក្នុងសហគមន៍នីមួយៗ ។ ពិធីនេះច្រើនប្រារព្ធធ្វើនៅ ឯខ្ទមអ្នកតាម្ចាស់ទឹកដី កណ្ដាលភូមិ ឬជួនកាលប្រារព្ធធ្វើនៅក្នុងវត្ត តែម្តង ។ ជាធម្មតាពិធីឆ្លងចេត្រគឺ ចាប់ផ្ដើមនៅ ពេលរសៀល និងបញ្ចប់នៅមុនថ្ងៃត្រង់ នៃថ្ងៃបន្ទាប់ ភ្ជាប់ពេលរសៀល នៃថ្ងៃបញ្ចប់នោះ គឺ អ្នកស្រុក នាំគ្នាលេងល្បែងទាញព្រ័ត្រ ។

Convention for the Safeguarding of the Intangible Cultural Heritage

United Nations Educational, Scientific and Cultural Organization — Intangible Cultural Heritage

The Intergovernmental Committee for the Safeguarding of the Intangible Cultural Heritage has inscribed

Tugging rituals and games

on the Representative List of the Intangible Cultural Heritage of Humanity upon the proposal of Cambodia, Philippines, the Republic of Korea and Viet Nam

Inscription on this List contributes to ensuring better visibility of the intangible cultural heritage and awareness of its significance, and to encouraging dialogue which respects cultural diversity

Date of inscription: 2 December 2015

Director-General of UNESCO: Irina Bokova

វិញ្ញាបនបត្រទទួលស្គាល់ការបញ្ចូលល្បែងទាញព្រ័ត្រក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

សារៈសំខាន់នៃការលេងល្បែងទាញព្រ័ត្រនេះ គឺមូលមតិគ្នាសាមគ្គីគ្នា បួងសួងសុំសេចក្ដីសុខ ចម្រុងចម្រើន រួមកម្លាំងជម្នះរាល់ឧបសគ្គផងទាំងពួង និងជាពិសេសបួងសួងសុំទឹកភ្លៀង ។

សព្វថ្ងៃល្បែងទាញព្រ័ត្រ ស្ថិតក្នុងចំណោមសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីមួយ ដែលប្រឈមនឹងការបាត់បង់ដោយសារកត្តាសេដ្ឋកិច្ច ស្ថានភាពសង្គមប្រែប្រួល ដោយពុំមានការជំរុញលើកទឹកចិត្តពីចាស់ទុំ ជាពិសេសប្រឈមនឹងទំនោររបស់យុវជនងាកទៅរកការកំសាន្ត តាមបែបសម័យទំនើបវិញ ។ បច្ចុប្បន្នក្រសួង វប្បធម៌ និងវិចិត្រសិល្ប:បាន និងកំពុងប្រឹងប្រែងអភិរក្ស ថែរក្សាការពារល្បែងទាញព្រ័ត្រនេះ ឲ្យមាននិរន្តរភាពសម្រាប់មនុស្សជំនាន់ក្រោយ ។

នៅក្នុងឆ្នាំ ២០១៣ ក្រសួងវប្បធម៌ និងវិចិត្រសិល្ប:នៃប្រទេសកម្ពុជា បានផ្ដួចផ្ដើមរួមសហការគ្នាយ៉ាងជិតស្និទ្ធ ជាមួយប្រទេសបីទៀតដែលមានល្បែងទាញព្រ័ត្រនេះដែរគឺ សាធារណរដ្ឋកូរ៉េ, វៀតណាម, និងហ្វីលីពីន ដើម្បីរៀបចំឯកសារដាក់ស្នើដាក់បញ្ចូលល្បែងទាញព្រ័ត្រក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌនៃមនុស្សជាតិ។ ការរួមគ្នានេះ បានទទួលលទ្ធផលយ៉ាងត្រចះត្រចង់ គួរជាទីមោទនៈ ។

ថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៥ កន្លងទៅនេះ នៅទីក្រុងវិនឌុកប្រទេសណាមីប៊ីគណៈកម្មាការអន្តររដ្ឋាភិបាលនៃអង្គការយូណេស្កូ បានសម្រេចចុះ "ល្បែងទាញព្រ័ត្រ" ចូលក្នុងបញ្ជីតំណាងនៃបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ ក្នុងសេចក្ដីសម្រេចលេខ 10.COM 10.B.12 ។

ការចុះបញ្ជីនេះ បានធ្វើឲ្យល្បែងទាញព្រ័ត្រមានការទទួលស្គាល់ពីអន្តរជាតិ និងការលើកតម្លៃយកចិត្តទុកដាក់ ការពារឲ្យបានគង់វង្សតទៅថ្ងៃមុខទៀត ។

ដំណោះស្រាយក្នុងការទប់ទល់បម្លាស់ប្តូរអាកាសធាតុ

ការផ្លាស់ប្តូរអាកាសធាតុ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ពិសេសគឺការកើនឡើងកម្តៅដ៏ហួតហែង និងគ្រោះទឹកជំនន់បានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំង ទៅដល់អាយុជីវិតរបស់ប្រជាជនក្នុងពិភពលោក

ការផ្លាស់ប្តូរអាកាសធាតុ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ពិសេសគឺការកើនឡើងកម្តៅដ៏ហួតហែង បានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងទៅដល់អាយុជីវិត របស់ប្រជាជនក្នុងពិភពលោក ។ ការកើនកម្តៅនិងគ្រោះទឹកជំនន់បានធ្វើឲ្យកើតមានយ៉ាងគំហុក នូវកង្វះស្បៀងអាហារហើយនេះជាមូលហេតុដែលធ្វើឲ្យប្រជាជននៅប្រទេសចិន ឥណ្ឌា ព្រមទាំងបណ្តាប្រទេសមានចំណូលទាប នៅក្នុងទ្វីបអាស៊ី តំបន់ប៉ាស៊ីហ្វីក និងតំបន់ផ្សេងទៀត ជួបការអត់ឃ្លាន និងការបាត់បង់អាយុជីវិត ។ ផលប៉ះពាល់នេះ ក៏ជះទៅដល់បណ្តាប្រទេសអ្នកមានផងដែរ ។ តាមការប៉ាន់ស្មានការផ្លាស់ប្តូរអាកាសធាតុនឹងធ្វើឲ្យប្រជាជនប្រមាណ កន្លះលាននាក់ស្លាប់បាត់បង់ជីវិតនៅឆ្នាំ ២០៥០ ។ អង្គការសុខភាពពិភពលោកក៏បានព្យាករណ៍ថា បាតុភូតរលកកម្តៅ ElNinoដ៏ខ្លាំងបំផុតដែលមិនធ្លាប់មានក្នុងជំនាន់នេះអាចធ្វើឲ្យប្រជាជន ចំនួន ៦០លាននាក់ប្រឈមនឹងបញ្ហាខ្វះអាហាររូបត្ថម្ភ ព្រមទាំងជំងឺតម្កាត់ផ្សេងៗ ។

ការស្លាប់ដោយអត់អាហារ ជាមូលហេតុសំខាន់ ។ គេបានធ្វើការសិក្សារកឃើញថា ក្នុងមនុស្សម្នាក់ អាចបាត់បង់ចំណីអាហារប្រមាណ ៣,២%ក្នុងមួយថ្ងៃ ដែលក្នុងនោះមានការកាត់បន្ថយនូវផ្លែឈើ បន្លែ និងសាច់ក្រហម។ បម្លាស់ប្តូរបែបនេះ បង្កើតបានជាលក្ខខណ្ឌធ្វើឲ្យមាននូវជំងឺមិនឆ្លងមួយចំនួនដូចជាជំងឺបេះដូងជំងឺដាច់សរសៃឈាមក្នុងខួរក្បាល និងជំងឺមហារីក ។

ប្រជាជនក្នុងពិភពលោក កំពុងតែជម្នះប្រយុទ្ធតទល់នឹងផលវិបាក នៃបម្លាស់ប្តូរអាកាសធាតុនេះ ។ គ្រប់តំបន់នៅក្នុងពិភពលោកសុទ្ធតែរកវិធីដោះស្រាយ តាមស្ថានភាពជាក់ស្តែង។ ដោយឡែកនៅតំបន់ អាស៊ីយើងនេះ ពិសេសប្រទេសមួយចំនួន នៅតាមដងទន្លេមេគង្គបានទទួលរងនូវឥទ្ធិពលElNinoតាំងពីពាក់កណ្តាលឆ្នាំ២០១៥ ។ ឥទ្ធិពលនេះ ធ្វើឲ្យតំបន់ផ្ទៃរងទឹកភ្លៀងនៃទន្លេមេគង្គមានភ្លៀងធ្លាក់តិចតួចបំផុត។ ព្យុះកើតមាន នៅក្នុងតំបន់ដែលមានឥទ្ធិពលដល់អាងទន្លេមេគង្គក្នុងរដូវវស្សា ។ ទឹកទន្លេមេគង្គគ្មានជំនន់ គ្មានទឹកហូរចូលតាម ស្ទឹង បឹង ព្រៃក ធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំង ដល់ជីវិតមនុស្ស សត្វ នៅរដូវប្រាំង ។ ទឹកសមុទ្របានច្រាលឡើងមកខ្លាំងធ្វើឲ្យប៉ះពាល់ដល់ផ្ទៃដីបង្កបង្កើនផល។ ឆ្លើយតបនឹងសំណូមពររបស់ប្រជាជន នៅក្នុងតំបន់នេះ ពិសេសសំដៅដល់ការជួយសង្គ្រោះភាពរាំងស្ងួតហួតហែង ប៉ះពាល់ដល់អាយុជីវិតសត្ត និងផលដំណាំនៅតាមតំបន់ដីសណ្តរនៃទន្លេមេគង្គ នៅពាក់កណ្តាលខែមីនារដ្ឋាភិបាលចិន បានប្រកាសបើកបង្ហូរទឹកពីទំនប់វារីអគ្គីសនីជីងហុង(Jinghong hydropower station) ខេត្ត យូណាន ចូលមកទន្លេមេគង្គក្រោមសម្រាប់ការប្រើប្រាស់បន្ទាន់ ដោយចាប់ផ្តើមពីថ្ងៃទី ១៥ ខែមីនា ដល់ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៦។ កាលពីអំឡុងខែមករា និងកុម្ភៈឆ្នាំ២០១៦ រដ្ឋាភិបាលចិន បានបើកបង្ហូរទឹកម្តងរួចមកហើយ ចំនួន២៣០០លានម៉ែត្រគីបដើម្បីជួយសម្រាលផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះរាំងស្ងួតដល់បណ្តាប្រទេសក្នុងតំបន់មេគង្គក្រោម ។ ការបើកបង្ហូរទឹកចូលទន្លេមេគង្គ បានបង្ហាញជាថ្មីម្តងទៀតពីសហប្រតិបត្តិការដ៏ល្អ លើការគ្រប់គ្រងធនធានទឹករវាងបណ្តាប្រទេសមេគង្គ និងចិនដែលជាផ្នែកមួយដ៏សំខាន់ នៃយន្តការកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាន ។

ទឹកដែលបង្ហូរចេញពីវារីអគ្គិសនី ជីងហុង ប្រទេស ចិន បានជួយចិញ្ចឹមទន្លេមិនឲ្យរីងស្ងួត។ វាបានជួយរួមចំណែក ក្នុងការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត។ នេះមិនមែនជាដំណោះស្រាយយុទ្ធសាស្ត្រក្នុងក្របខណ្ឌទូទៅទេ ប៉ុន្តែការបើកបង្ហូរនេះបានធ្វើឲ្យកម្ពស់ទឹកទន្លេមេគង្គកើនឡើងបន្តិចវិញ និងផ្តល់ផលប្រយោជន៍ដល់ប្រទេស និងប្រជាជននៅតាមដងទន្លេមេគង្គ ក្រោមដូចជា ប្រទេសភូមា ថៃ ឡាវ កម្ពុជា និងវៀតណាម ដែលអាចប្រើប្រាស់ទឹកនេះបង្កបង្កើនផល ប្រកបរបរចិញ្ចឹមជីវិតតទល់ជាមួយនឹងបម្លាស់ប្តូរអាកាសធាតុដ៏ក្តៅហួតហែង ព្រមទាំងជួយដល់ជីវៈចម្រុះ ដែលមាននៅក្នុងអាងទន្លេមេគង្គផងដែរ ។

ឱ

*១. នេះគឺពួកតូ អក្សរ " **ឱ** "*
ទុកជាសម្បត្ដិ កេរដូនតា
២. ឱរៀនអត់ខ្មីនកេរដូនតា
ឱរៀនចិត្ដល្អ កុំខ្ជូវខ្ជី
៣. ឱរៀននូវច្បាប់ប្រពៃណី
ឱសង្គ្រោះញាតិមានអាសន្ន
៤. ឱចាំទំនៀមទំនងព្រេង
ឱចេះរាប់ព្រៀងលានជិតឆ្ងាយ
៥. ឱស្គាល់ខ្ពស់ទាបដរាបទៅ
ឱចងចាំចិត្ដ គិតខ្លាចហ្មង
៦. ឱមានមេត្ដាប្រយ័ត្នទោស
ឱមានមេត្រី ប្រណីគ្នា

កូនចៅខាងក្រោយត្រូវកាន
សម្រាប់តម្រាច្បាប់ចាស់ថ្មី ។
ឱរៀនវិជ្ជាការលោកិយ
ឱខំឃ្នាតខ្មីរកទ្រព្យធន ។
ឱខំរកស៊ី កុំលួចប្លន់
ឱចេះអត់ធន់ក្ដីទាំងឡាយ ។
ឱចេះចាំចែងបទបរិយាយ
ឱផ្សាយមេត្ដាដល់ជនផង ។
ឱស្ដាប់ប្រាជ្ញខ្លៅនូវរៀមច្បង
ឱគ្រាប់ឱ្យត្រង ច្បាប់ធម្ម ។
ឱមានសន្ដោសលះវេរ
ឱមានចិត្ដជាជាប់ខន្ដី ។

តែតែល្អ

ព្រឹកមួយនាង តយ បានទៅលេងផ្ទះនាង ឥង ជាមិត្ត ដែលប្ដីទើបតែរត់ចោល។ ឃើញមិត្ដនៅម្នាក់ឯងក៏សួរ ៖

- នែ..គ្នាទើបតែឮគេប្រាប់ថា ប្ដីរបស់ឯងបាននាំស្រីបម្រើរត់ទៅបាត់ តើពិតមែនទេ?

- អើ..គឺពិតមួយរយភាគរយ!

-ណ្ហើយប្រុសប្រភេទហ្នឹងមិនបាច់ស្ដាយស្រណោះទេ គេចង់ទៅណាទៅ ចុះឯងកុំពិបាកចិត្ដអីណា៎ ។

- អ្នកណាថា ខ្ញុំពិបាកចិត្ដ? តាមពិតគាត់ហ្នឹង ហើយនិងស្រីបម្រើនោះ មិនដែលជួយអ្វីខ្ញុំបានទេ ។ ខ្ញុំប្រុងដេញចោលទាំងពីរនាក់យូរហើយ។ ឥឡូវ ពួកគេពង្រត់គ្នាអញ្ចឹងរឹតតែល្អសម្រាប់ខ្ញុំតើ តយ អើយ ។

អង្គុយមើលមាត់

បានជួបគ្នាក្បែរតៀមលក់ភេសជ្ជៈ នាយ អែម និងនាយ អំ បបួលគ្នាចូលផឹកស្រាបៀរ ។ ប៉ុន្ដែពេលដើរចូលមាត់ទ្វារ ស្រាប់តែអំ ឈរអេះអុញ ពុំព្រមចូលទើបនាយ អែម សួរ ៖

- នែ..ម៉េចហ្នឹង មិនចង់ចូលតៀមហ្នឹងទេឬ?

- ថីមិនចង់!

- អើ..បើចង់នៅអេះអុញស្អីទៀត?

- ខ្ញុំភ្លេចយកលុយមកហើយ!

- មិនអីទេ ចូលជាមួយខ្ញុំ ។ គ្មានអ្នកណាបង្ខំអ៊ំឯងត្រូវតែផឹកឯណា។ បើអត់មានលុយជាប់ខ្លួនទេ អង្គុយមើលមាត់គេផឹកបានដែរតើ ។

ចងចាំចំណុចពិសេស

ក្រោយពីបានស្ដាប់ពាក្យបណ្ដឹងផ្ទាល់មាត់ភ្នាក់ងារនគរបាលចរាចរ សួរយុវជន :

- តើប្អូនមានចងចាំចំណុចពិសេសត្រង់ណាខ្លះ របស់នារីរូបស្អាត ដែលជិះម៉ូតូបុកម៉ូតូប្អូនឯងទេ ?

- បាទ ! ខ្ញុំចងចាំច្បាស់ណាស់ លោកនគរបាល ។

- អើ តើចំណុចពិសេសត្រង់ណាខ្លះ ?

- បាទ ! នាងអាយុប្រហែល ២០ ឆ្នាំ ពាក់អាវយឺតខ្លីចេញរន្ធធ្ងិត ។

- បានហើយ! ចុះខោ ?

- នាងអត់ស្លៀកខោទេ គឺស្លៀកសំពត់ហ្ស៊ីបខ្លីដល់ថ្នាក់មើលឃើញ ខោស្លីបខាងក្នុង ។

- អ៊ីចឹង គឺច្បាស់ហើយ ! តាមពិត ប្អូនឯងទេជាអ្នកបុកនាងមិនមែន នាងបុកប្អូនឯងទេ ។ រវល់តែភ្លឹក សម្លឹងមើលគេគ្រប់កន្លែងអ៊ីចឹង បានជាជិះម៉ូតូបុកគេ រួចហើយប្ដឹងនគរបាលថា គេបុកខ្លួន ។

ទៅវិញ្ញទៅ !

នាយឆ្ងីងស្រវ៉ាងខ្លាំងជ្រុលព្រោះរវល់ផឹកស៊ីរហូតយប់ជ្រៅ ទើបដើរទ្រេតទ្រោតត្រឡប់ទៅផ្ទះវិញ ប៉ុន្ដែមិនចូលចំផ្ទះខ្លួនបែរជាចូលច្រឡំ ចំប៉ុស្ដិ៍នគរបាលឃុំទៅវិញ ។ ទៅដល់គោះទ្វារផ្ទាំង ១ ស្រែក :

- ម៉ែវ៉ា បើកទ្វារឲ្យបងផងមើល៍ !

- ពេលនោះ មានភ្នាក់ងារនគរបាលម្នាក់យាមប្រចាំការ ស្រវ៉ាងទន់ខ្លួនដែរ ឮស្នូរគោះទ្វារក៏ស្រែកគំហក :

- អារ៉ាបល់យក៏ ដល់ម៉ោង ៥ ភ្លឺទើបដល់វេនឯងយាម ហេតុអ៊ីក៏ ប្រញាប់មកម្ល៉េះ? ទៅវិញទៅ អញត្រូវការដេកទៀត ។

សេចក្ដីកែតម្រូវ

សូមធ្វើការកែតម្រូវអត្ថបទដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីប្រជាជន លេខ ១៧៧ ខែកុម្ភៈ ឆ្នាំ ២០១៦ ទំព័រទី ២៣ លើពាក្យស្លោកពីលើ អត្ថបទដែលមានចំណងជើងថា "រួមគ្នាដោះស្រាយបញ្ហាប្រឈមដែលរារាំង ការអភិវឌ្ឍស្ដ្រី ដោយសូមកែដាក់ថា" អបអរសាទរខួបលើកទី ១០៥ ទិវានារីអន្ដរជាតិ" ។

សូមអរគុណ

ចោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខ័ណ្ឌទួលគោក-ភ្នំពេញ
H/P : 012 990 935 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com

អ្នកឲ្យបត្តម្ភ ទស្សនាវប្តី ប្រជាជន លេខ ១៧៨

១-	លោកជំទាវ	**ម៉ែន**	**សំអេន**	*សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច .*	៤00.000៛
២-	ឯ.ឧ	**កែ**	**គឹមយ៉ាន**	*សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ*	១00 ដុល្លារ
៣-	ឯ.ឧ	**ចិន**	**ឈិន**	*សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល*	៤00.000 ៛
៤-	ឯ.ឧ	**អ៊ុក**	**រ៉ាប៊ុន**	*សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ.*	១00 ដុល្លារ
៥-	ឯ.ឧ	**អូន**	**ពំនួមុន្នីរ៉ូ**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*	២00 ដុល្លារ
៦-	ឯ.ឧ	**ហ៊ុន**	**ណេង**	*ប្រធានគណៈកម្មការទី ៤ នៃរដ្ឋសភា*	១00 ដុល្លារ
៧-	ឯ.ឧ	**ម៉ិន**	**ឃិន**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ជួន ជួន***	១00 ដុល្លារ
៨-	ឯ.ឧ	**ត្រាំ**	**អ៊ីវតឹក**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន*	១00 ដុល្លារ
៩-	ឯ.ឧ	**ផោង**	**ខុន**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍*	១00 ដុល្លារ
១0-	ឯ.ឧ	**គង់**	**ឥន្ទ**	*ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*	១00 ដុល្លារ
១១-	ឯ.ឧ	**លន់**	**លីមថៃ**	*ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម*	១00 ដុល្លារ
១២-	ឯ.ឧ	**ជ្យើង**	**អ៊ី**	*ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង*	១00 ដុល្លារ
១៣-	ឯ.ឧ	**អូស្ថាន**	**ហាស្សាន់**	*ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា*	១00 ដុល្លារ
១៤-	ឯ.ឧ	**សរ**	**ចាំ១ង**	*ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ*	១00 ដុល្លារ
១៥-	ឯ.ឧ	**ង៉ា**	**សុជាតិវង្ស**	*ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ*	១00 ដុល្លារ
១៦-	ឯ.ឧ	**ម៉ម**	**ប៊ុនណាង**	*អនុប្រធានគណៈកម្មការទី ១0នៃព្រឹទ្ធសភា*	១00 ដុល្លារ
១៧-	ឯ.ឧ	**យូ**	**តារ៉ាម្ស**	*អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្តាល ចុះជួយរាជធានីភ្នំពេញ*	១00 ដុល្លារ
១៨-	គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង				១00 ដុល្លារ
១៩-	គណៈកម្មាធិការគណបក្សខេត្តសៀមរាប				១00 ដុល្លារ
២0-	គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ				៥0 ដុល្លារ
២១-	គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី				៥0 ដុល្លារ
២២-	ឯ.ឧ	**លីម**	**គានហោ**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក*	២00.000 ៛
២៣-	ឯ.ឧ	**ម៉ម**	**ប៊ុនហេង**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល*	៥0 ដុល្លារ
២៤-	ឯ.ឧ	**ថា**	**យ៉ាត**	*អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា*	២១៣.៤៧0៛
២៥-	ឯ.ឧ	**ជ្ញ**	**យិនស៊ីម**	*រដ្ឋលេខាធិការក្រសួងសុខាភិបាល*	៥0 ដុល្លារ
២៦-	ឯ.ឧ	**អ៊ុក**	**ង្រាន្ថា**	*រដ្ឋលេខាធិការក្រសួងព័ត៌មាន*	២00.000 ៛
២៧-	ឯ.ឧ	**ឃីម**	**សារ៉ាន្ធ**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្ប្ធម៌ និងវិចិត្រសិល្ប: .*	៥0 ដុល្លារ
២៨-	ឯ.ឧ	**ង៉ាត**	**ហាមង៉ាន**	*អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ*	៥0 ដុល្លារ
២៩-	ឯ.ឧ	**សូ**	**ជុងហ្ស**	*ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ*	៥0 ដុល្លារ
៣0-	ឯ.ឧ	**ចាយ**	**ចូរិន**	*អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម*	៥0 ដុល្លារ
៣១-	ឯ.ឧ	**សួស**	**យ៉ារ៉ា**	*អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ*	៥0 ដុល្លារ
៣២-	ឯ.ឧ	**នរ:**	**រតន:ឥណ្ឌោ**	*រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា*	២00.000 ៛
៣៣-	ឯ.ឧ	**ឃួន**	**រ៉ានីន**	*រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*	៥0 ដុល្លារ
៣៤-	ឯ.ឧ	**ក្រៅ**	**ខុនជ៉ារ៉ា**	*អនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកោះកុង*	៥0 ដុល្លារ
៣៥-	ឯ.ឧ.ឧ.សេនីយឯក		**មាស ឥន្ធី**	*អគ្គលេខាធិការនៃអជ្ញាធរជាតិប្រឆាំងគ្រឿងញៀន*	៥0 ដុល្លារ
៣៦-	ឯ.ឧ	**ឆាយ**	**ឫទ្ធិសែន**	*អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់*	២00.000៛
៣៧-	ឯ.ឧ.	**ឫទ**	**លីមហេង**	*អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី*	២00.000៛
៣៨-	ឯ.ឧ	**សេង**	**ទ្ធ្ជ**	*ជំនួយការផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន***	២00.000៛
៣៩-	ឯ.ឧ	**ម៉ៅ**	**ប៊ុនណារ៉ាន**	*សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា*	១00.000៛
៤0-	ឯ.ឧ	**ម៉ែន**	**សុំង៉ាន់**	*សមាជិកព្រឹទ្ធសភា*	១00.000៛
៤១-	ឯ.ឧ	**ង៉ាន**	**ប៊ុនធ្ជើន**	*រដ្ឋលេខាធិការក្រសួងដែនការ*	១00.000៛
៤២-	លោកជំទាវ	**ស៊ីន**	**ស៊ីយុត**		១00.000៛
៤៣-	ឯ.ឧ	**គឹម**	**ធា**	*ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង*	១00.000៛
៤៤-	ឯ.ឧបណ្ឌិត	**មាស**	**ប៊ុ**	*អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍*	១00.000៛
៤៥-	លោកជំទាវ	**ឌិត្យ**	**ចំន្ទតារ៉ា**	*អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*	១00.000៛
៤៦-	ឯ.ឧ	**ឌា**	**ចំន្ទលីដា**	*ទីប្រឹក្សាសម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរ៉ិន***	១00.000៛
៤៧-	ឯ.ឧ	**ម៉ែន**	**ឥន្ទ**	*ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង*	១00.000៛
៤៨-	ឯ.ឧ	**ជ្ជួន**	**ថេរ៉ាវ៉ាត**	*ទីប្រឹក្សាសម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរ៉ិន***	១00.000៛
៤៩-	ឯ.ឧ	**ម៉ៅ**	**ឡាំង**	*អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន*	១00.000៛
៥0-	លោក	**អោម**	**ចន**	*ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ*	១00.000៛
៥១-	លោក	**គឹម**	**ប៊ុណ្ណា**	*សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សខេត្តសៀមរាបប្រធានសាខាគណបក្សមន្ទីរសាធារណការ និងដឹកជញ្ជូន*	១00.000៛
៥២-	ឯ.ឧ. ឧកញ៉ា	**សន**	**ឈុសល**	*អនុប្រធានគណបក្សស្រុកកំពង់សិលា*	២0 ដុល្លារ
៥៣-	លោក	**សារ**	**រដ្ឋជាតិ**	*មន្ត្រីក្រសួងមហាផ្ទៃ*	៧0.000៛
៥៤-	លោក	**សារ**	**រដ្ឋបណ្ណា**	*មន្ត្រីសាលាខេត្តប៉ៃលិន*	៧0.000៛
៥៥-	លោក	**សារ**	**រតនា**	*មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តមណ្ឌលគិរី*	៧0.000៛
៥៦-	លោកជំទាវ	**ខេង**	**សំវ៉ាដា**	*រដ្ឋលេខាធិការក្រសួងកិច្ចការនារី*	៥0.000៛
៥៧-	ឯ.ឧ	**អ៊ុន**	**ឆាលី**	*សមាជិកក្រុមប្រឹក្សាខេត្តកោះកុង*	៥0.000៛
៥៨-	ឯ.ឧ	**ពត**	**ចាន់នី**	*សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម*	៥0.000៛
៥៩-	ឯ.ឧ	**ហេង**	**ឥណ្ណា**	*សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ*	៥0.000៛

អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៧៨

៦០-	ឯ.ឧ	ផ្ទាង	ចាន់	សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ	៥០.០០០រ
៦១-	លោក	ឃួន	សំបូរ	សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ	៥០.០០០រ
៦២-	លោកជំទាវ	ស្សឿ	ចំន្ទីថា		៥០.០០០រ
៦៣-	លោក	ជ	ភុន្ធី	សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ	៥០.០០០រ
៦៤-	កញ្ញា	ផ្ទាង	និតជ្ជៀរ	មន្ត្រីក្រសួងទេសចរណ៍	៦៦.៦៦៦រ
៦៥-	លោក	ផ្ការ	រាត្រី	ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ	៥០.០០០រ
៦៦-	លោក	ចាប	ឌីណា	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ ប្រធានគណៈកម្មការផ្សារកណ្ដាល	៥០.០០០រ
៦៧-	លោក	ហាង	ឫ	ប្រធានក្រុមការងារចុះ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ	៥០.០០០រ
៦៨-	គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម				៤០.០០០រ
៦៩-	ឯ.ឧ	ទេព	សាឧុន	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	៤០.០០០រ
៧០-	លោក	ណី	សារ៉ា	អភិបាលវង ខេត្តបន្ទាយមានជ័យ	៤០.០០០រ
៧១-	លោក	គឹម	សុវណ្ណ	ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ	៤០.០០០រ
៧២-	ឯ.ឧ	ស៊ុន	ភុន្ធី	សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក	៣០.០០០រ
៧៣-	ឯ.ឧ	ឈុំ	វណ្ណារិទ្ធ	អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល	៣០.០០០រ
៧៤-	ឯ.ឧ	សារ៉ាង	សាវ៉ាត	សមាជិកក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ	៣០.០០០រ
៧៥-	លោក	ម៉ៅ	សុខលីម	អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ	៣០.០០០រ
៧៦-	លោក	ចាន់	សុណាត	សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក	៣០.០០០រ
៧៧-	លោក	ឃុ	ពៅ	អភិបាលស្រុកស្វាយចេក	៣០.០០០រ
៧៨-	លោក	ទេព	ទិសិដ្ឋ	អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ	៣០.០០០រ
៧៩-	កញ្ញា	កែវ	សុជាតា	អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា	៣០.០០០រ
៨០-	លោក	ភាត	ហ៊ីល	ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ	៣០.០០០រ
៨១-	លោក	ឈា	ប៊ុនរិទ្ធ	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	២០.០០០រ
៨២-	លោក	ម៉ៅ	ហាក់	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	២០.០០០រ
៨៣-	លោក	លីម	ទីរក្ស	សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម	២០.០០០រ
៨៤-	លោក	លីម	ថេង	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	២០.០០០រ
៨៥-	លោក	ឃ្លោក	សំអាង	សមាជិកក្រុមការងារចុះខេត្តកំពង់ចាម	២០.០០០រ
៨៦-	លោក	ម៉ី	ភុជ្ជា	មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង	២០.០០០រ
៨៧-	លោក	អ៊ីត	សំអាន	អគ្គការរងនៃអគ្គាធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	២០.០០០រ
៨៨-	លោក	ភ្ជួ	ចាន់ទិត្យ	អាជីវករ ខេត្តបន្ទាយមានជ័យ	២០.០០០រ
៨៩-	លោក	អ៊ីម	សាវន	អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ	១៥.០០០រ
៩០-	ឯ.ឧ	សេង	សុមុនី	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា	១០.០០០រ
៩១-	ឯ.ឧ	ប៉ូญ	សម្ផះ	អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម	១០.០០០រ
៩២-	លោក	ម៉ី	លីហ្ជត	សមាជិកក្រុមការងារចុះខេត្តកំពង់ចាម	១០.០០០រ
៩៣-	លោក	ជួន	វណ្ណារិទ្ធ	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
៩៤-	លោក	ឌួន	ពោធ្ស	ប្រធានាយកដ្ឋានទឹកស្អាត ក្រសួងធនធានទឹក និងឧតុនិយម	១០.០០០រ
៩៥-	លោក	ម៉ម	ឃ្ម្ញស	អនុប្រធានាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធនធានទឹក និងឧតុនិយម	១០.០០០រ
៩៦-	លោក	សៅ	សម្ផស្ស	អនុប្រធានាយកដ្ឋានបរិញ្ញវត្ថុនៃក្រសួងនៃក្រសួងធនធានទឹក និងឧតុនិយម	១០.០០០រ
៩៧-	លោក	ណ៊ាវ	មុយថុង	អនុប្រធានគណៈកម្មាធិការសាខាបក្សមជ្ឈមណ្ឌលផ្ដល់ឈាមនៃមន្ទីរពេទ្យព្រះអង្គឆ្លូង	១០.០០០រ
៩៨-	លោក	ឈុន	ប៊ុនឈ្ឿន	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
៩៩-	លោក	ថេង	ប៊ុនតេង	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១០០-	លោក	ស្វាយ	សុគន្ធី	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១០១-	លោក	សុខ	ចំណាន	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១០២-	លោក	សៅ	សម្ភារ	ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធនធានទឹក និងឧតុនិយម	១០.០០០រ
១០៣-	លោក	ទិត	ចរិយា	ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានបរិញ្ញវត្ថុ នៃក្រសួងធនធានទឹក និងឧតុនិយម	១០.០០០រ
១០៤-	លោក	សែម	សំណាង	ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធនធានទឹក និងឧតុនិយម	១០.០០០រ
១០៥-	លោក	សុខ	តារា	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១០៦-	លោក	ស	ផល្លី	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១០៧-	លោក	ហ្ជត	ធាន	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១០៨-	លោក	ធីម	ភុជ្ជារ៉ា	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១០៩-	លោក	ណុប	ម្ឿមណី	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១១០-	លោក	សារុន	សម្បត្ដិ	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១១១-	លោក	សរ	ទិចិត្ត	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១១២-	លោក	ឆុប	សុផល្លា	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១១៣-	លោក	ជ	ឌ្ឍណ	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១១៤-	លោក	ឈ្លាង	ចុយ	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.០០០រ
១១៥-	លោក	យស់	ឆុល	សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង	១០.០០០រ
១១៦-	លោក	ឆ្ជូ	ចន្ធា	សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង	១០.០០០រ
១១៧-	លោក	ឆ្ជាច	ឌីរ៉ាត់	សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង	១០.០០០រ
១១៨-	លោក	ឈាង	សុវណ្ណារ៉ា	មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង	១០.០០០រ

និពន្ធនាយក :

លោក តាក ស៊ុនអ៊ី

គណៈកម្មការនិពន្ធ

១. លោក ខ្យៀ ណារី

២. លោក អ៊ីម សុន្ទរ:

៣. លោក រ៉ង្ស សារ៉ុធ

៤. លោក ទាវ សារ:មុនី

៥. លោក សុខ សុធន

លេខានិពន្ធ

១. លោក ជុំ សម្បត្តិ

២. លោក ម៉ាក់ ឈិន

អ្នកបកប្រែភាសា

១. លោកស្រី ម៉ែន នារីសោភ័ត

អ្នកថតរូប

១. លោក សុផាត រ៉ី:មុនី

វិចិត្រករ

១. លោក ធា សារ៉ុធ

អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

Address :

No 203 Preah

Norodom Bld.

Phnom Penh Cambodia

Tel : 023 219 065

*សម្តេចចក្រី **ហេង សំរិន** ក្នុងដំណើរទស្សនកិច្ចជាមិត្តភាពនៅប្រទេសអូស្ត្រាលី* ៥

កិច្ចប្រជុំកំពូលមេគង្ค-ឡានឆាង លើកទី ១ និងវេទិកាប៊ីអាវ បានផ្តល់សារប្រយោជន៍យ៉ាងសំខាន់ដល់កម្ពុជា ៦

***សម្តេចតេជោ** : កម្ពុជាមានមហិច្ឆតាក្នុងការបញ្ជូនកម្លាំងទៅចូលរួមក្នុង ...*

** អំពាវនាវឲ្យប្រើប្រាស់អ៊ីបិល.....* ៩

*សម្តេចក្រឡាហោម **ស ខេង** ការតែងតាំង និងប្រគល់ការកិច្ចដឹកនាំជូនមន្ត្រីវ័យក្មេងដែលមាន .....* ១២

*សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលា ...* ១៣

ក្រៅមុខ

*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការភូមិកុមារ អេស អូ អេស នៅខេត្តកំពត (ថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១៦)*

មាតិកា
Contents

វិចារណកថា : ភាពសុខដុមរមនា និងការអភិវឌ្ឍគឺជាផ្លែផ្កាដ៏ត្រចះត្រចង់នៃសន្តិភាព .....

Editorial : Harmony and Development – Precious Fruits of Peace ៣

- *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ១៤*
- *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ១៨*
- *លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ២០*
- *ការចូលរួមដោះស្រាយទុនសម្រាប់ប្រជាកសិករប្រើប្រាស់ ក្នុងការបង្កបង្កើនផលកសិកម្ម ២១*
- *ឆ្នាំ ២០១៥ កងកម្លាំងនគរបាលជាតិសម្រេចបានលទ្ធផលដ៏ល្អប្រសើរក្នុងការបម្រើប្រជាជន ២៤*
- *កំណែទម្រង់ក្នុងវិស័យ ឧស្សាហកម្ម និងសិប្បកម្ម បាននាំមកនូវការរីកចម្រើនថ្មី ២៧*
- *វប្បធម៌ : ល្បែងទាញព្រ័ត្រត្រូវបានចុះក្នុងបញ្ជីតំណាងនៃបេតិកភណ្ឌវប្បធម៌អរូបីនៃ ២៩*
- *ចំណេះដឹងទូទៅ : ដំណោះស្រាយក្នុងការទប់ទល់បម្លាស់ប្តូរអាកាសធាតុ ៣០*
- *កំណាព្យ : ឲ្យ.....សំណើច..... ៣១*

ទស្សនាវដ្ដី

ប្រចាំសប្តាហ៍

THE PRACHEACHUN MAGAZINE

ឆ្នាំទី១៥ លេខ ១៧៨ ខែមីនា ឆ្នាំ ២០១៦

អគារថ្មីនៃទីស្តីការក្រសួងបរិស្ថាន
(អគារមេកកេដា)
សម្ពោធនៅ
ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦

ចែកចាយដោយឥតគិតថ្លៃ